ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម

ORIGINAL/ORIGINAL

ថ្ងៃ ខែ ឆ្នាំ (Date): 15-Dec-2011, 08:13

CMS/CFO: Sann Rada

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១**

**ម៉ោង ០៩: ០២នាទី**

**សវនាការលើកទី៩**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍ *(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ *(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធួ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង) *(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ម៉ាតេអូ គ្រីប៉ា *(Mr.Matteo CRIPPA)*

លោក ឌុច ផារី

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក អាន់ឌ្រូ ខេលី *(Mr.Andrew CAYLEY)*

លោក សេង ប៊ុនឃាង

លោក ដេល លីសាក់ *(Mr. Dale LYSAK)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ម៉ៃខល ផេសមិន

*(Mr. Michiel PESTMAN)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកគែន

*(Mr. Arthur VERCKEN)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវ៉ាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោកស្រី ម៉ុច សុវណ្ណារី

លោក វ៉ែន ពៅ

លោក ហុង គីមសួន

លោកស្រី គ្រីស្ទីន ម៉ាទីណូ

*(Ms. Chritine MARTINAU)*

លោកស្រី នូស៊ីន សាកាវ៉ាទី

*(Ms.Nushin SARKARATI)*

កញ្ញា ហ្វីលីពីន ស៊ុតហ្ស៍ *(Ms. Philipine SUTZ)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក អាង ឧត្តម | ខ្មែរ |
| លោក ម៉ៃខល ផេសមិន | អង់គ្លេស |
| លោក អាកទួរ វែកគែន | បារាំង |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក ខៀវ សំផន | ខ្មែរ |
| លោក នួន ជា | ខ្មែរ |
| លោក អៀង សារី | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅជនជាប់ចោទ នួន ជា**

សួរដោយចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ផ្ដើមពី ...................................................... ទំព័រ ០២
សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្ដើមពី ...................................................... ទំព័រ ២២

**ការសួរសំណួរទៅជនជាប់ចោទ អៀង សារី**

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ...................................................... ទំព័រ ៣៧

**ការសួរសំណួរទៅជនជាប់ចោទ ខៀវ សំផន**

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ...................................................... ទំព័រ ៤២

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០១:៣៨]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

[០៩:០២:២១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

ដូចដែលយើងខ្ញុំបានជម្រាបជូនដល់ភាគី និងសាធារណជនជ្រាបហើយកាលពីថ្ងៃសុក្រ នៅក្នុងខណៈពេលដែលអង្គជម្រះ មិនអាចដំណើរការសវនាការបាន គឺដោយមូលហេតុបញ្ហាសុខភាពរបស់សាក្សីមួយរូបដែលអង្គជម្រះកំពុងតែដំណើរការស្តាប់សក្ខីកម្ម តាមរយៈប្រព័ន្ធសោតទស្សន៍ ហើយសម្រេចលើកមកធ្វើនៅថ្ងៃនេះ ប្រសិនបើយថាហេតុនៃបញ្ហាសុខភាពរបស់គាត់ហ្នឹង មិនមានបញ្ហា។ ប៉ុន្តែនៅថ្ងៃនេះ ដោយយថាហេតុនៃបញ្ហាសុខភាពរបស់សាក្សីរូបនេះ នៅតែមានបញ្ហាមិនអាចដំណើរការក្នុងការឆ្លើយផ្តល់សក្ខីកម្មបន្តឲ្យចប់ចុងចប់ដើមនោះ។ អង្គជម្រះសម្រេចសួរចម្លើយជនជាប់ចោទជាបន្ត ដូចអ្វីដែលអង្គជម្រះបានជម្រាបជូនភាគីនិងសាធារណជនជ្រាបកាលពីថ្ងៃសុក្រ។ ដូច្នេះ នៅព្រឹកនេះអង្គជម្រះចាប់ផ្តើមបន្ត ការសួរចម្លើយជនជាប់ចោទ នួន ជា។

អនុរក្សមន្ទីរឃុំឃាំង នាំជនជាប់ចោទ នួន ជា មកកាន់ឈើរាងវង់ក្រចកសេះនៅពីមុខអង្គជម្រះនេះ។

**ប្រធានអង្គជំនុំ៖**

បាទ, សួស្តីលោក នួន ជា។

សូមអញ្ជើញលោកចង់មានប្រសាសន៍អី? សូមអញ្ជើញបាទ!

**លោក នួន ជា៖**

លោកប្រធាន ប៉ុន្មានថ្ងៃដែលសម្រាកនេះ សុខភាពខ្ញុំវាមិនស្រួល ចេះតែញ័របេះដូង ហើយវិលមុខ។ ដូច្នោះ បើកាលណាសុខភាពខ្ញុំ អំណោយខ្ញុំចេះតែខំ បំពេញភារកិច្ចជាមួយតុលាការឲ្យបានល្អ។

ប៉ុន្តែបើកាលណាខ្ញុំអស់កម្លាំង ខ្ញុំអនុញ្ញាតលោកប្រធាន សូមសម្រាកប្អូនដប់នាទី។ សូមអនុញ្ញាត។ សូមអរគុណលោកប្រធាន។

[០៩:០៦:៤៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក នួន ជា ដែលបានផ្តល់ព័ត៌មានជាមុនដល់អង្គជំនុំជម្រះ ហើយអង្គជំនុំជម្រះក៏សូមជម្រាបលោកផងដែរ ថាអង្គជំនុំជម្រះនឹងដំណើរការសួរដេញដោលចំពោះរូបលោក នៅក្នុងថ្ងៃនេះតែមួយព្រឹកទេ។ ហើយរសៀលអង្គជំនុំជម្រះសម្រេចបន្ត នូវការសួរដេញដោលទៅជនជាប់ចោទផ្សេងទៀតមានលោក អៀង សារី និង លោក ខៀវ សំផន។ នេះជាការគិតគូរអំពីបញ្ហាលទ្ធភាព បញ្ហាសុខភាព និងវ័យ។ ដូច្នេះ ដើម្បីរៀបចំនូវការសួរដេញដោលនេះ ឲ្យវាប្រព្រឹត្តទៅបានល្អ ហើយបានលឿនឆាប់រហ័សតាមដែលអាចធ្វើទៅបាន។ ហើយជាក់ស្តែងឃើញអំមិញគឺជាការលំបាកដែរ នៅពេលដែលជូនគាត់មកកាន់នៅកន្លែងនេះ អ៊ីចឹងខាងអនុរក្សមន្ទីរឃុំឃាំងគប្បីរៀបរយនូវកៅអីរុញដែលអាចធ្វើទៅបាន ដើម្បីរុញគាត់ពីកន្លែងនុំងមកកាន់ទីនេះ ឬក៏ត្រឡប់ទៅវិញជាការងាយជាង មើលទៅវាសមរម្យ។

[០៩:០៧:៥៦]

ជាបន្តសូមប្រគល់វេទិកាទៅលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ដើម្បីបន្តសំណួរចំពោះជនជាប់ចោទ នួន ជា។ សូមអញ្ជើញលោកស្រីចៅក្រម!

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។

**ស៖** លោក នួន ជា កាលពីសប្តាហ៍មុននៅថ្ងៃទី ៦ ខែវិច្ឆិកា លោកបានផ្តល់នូវសេចក្តីលម្អិតដ៏មានប្រយោជន៍ជាការវិភាគ នៅថ្ងៃទី១២ ខែ១២ នេះគឺអំពីយុទ្ធសាស្ត្ររបស់បក្សកុម្មុយនីស្តកម្ពុជា។ ខ្ញុំនឹងសង្ខេបចំណុចមួយពីរពីចំណុចនោះ មុននឹងខ្ញុំសួរសំណួរលោកពីបញ្ហានេះ។ លោកបានប្រាប់តុលាការការថា តាមសំណើរបស់លោកតា ទូ សាមុត លោក និងលោក ប៉ុល ពត បានចំណាយពេលបួន ឬក៏ប្រាំឆ្នាំ រវាងឆ្នាំ១៩៧៥ ហើយនិងឆ្នាំ១៩៥៩ ក្នុងការពិភាក្សា និងបង្កើតយុទ្ធសាស្ត្រនេះ។ លោកក៏បានប្រាប់យើងផងដែរ នេះមានន័យថា យើងវិភាគអំពីស្ថានភាពរបស់ប្រជាជនកម្ពុជា ហើយ

យើងរកឃើញថា កសិករនៅតំបន់ជនបទត្រូវបានគាបសង្កត់ដោយពួកអាណានិគម ពួកនាយទុន ហើយនិងពួកសក្តិភូមិ។ ហើយការវិភាគរបស់លោក គឺថាការសម្រេចថា ការធ្វើបដិវត្តន៍ជាតិគឺជាការសំខាន់ដើម្បីប្រឆាំងនឹងអំណាចរបស់ពួកនាយទុននិយម ហើយនិងប្រឆាំងការរំខានពីពួកបរទេស។

[០៩:០៩:៥២]

ឥឡូវនេះ ខ្ញុំសូមសួរលោកឱ្យលោកបញ្ជាក់មើលថា តើគោលនយោបាយទាំងស្រុង ហើយនិងមាគ៌ាយុទ្ធសាស្ត្របក្សនោះ ត្រូវបានពិភាក្សានៅក្នុងកិច្ចប្រជុំដំបូងរបស់បក្សនៅទីនោះដែរឬទេ? តើនេះជាចំណុចដែលលោកបានប្រាប់តុលាការពីពេលនោះដែរឬទេ? ជាយុទ្ធវិធីនោះ?

**ឆ៖** សូមគោរពលោកប្រធាន, ខ្ញុំសូមបញ្ជាក់បន្តិចអំពីមតិរបស់ខ្ញុំពេលនោះ។ ខ្ញុំថា ធាតុពិតរបស់សង្គមកម្ពុជាជាសង្គមពាក់កណ្តាលអាណានិគម ពាក់កណ្តាលសក្តិភូមិ។ ដូច្នោះភារកិច្ចបដិវត្តន៍របស់កម្ពុជាប្រជាធិបតេយ្យពេលនោះ គឺកម្ចាត់ ឬបំបាត់ចោលនូវកម្អែល សំណល់ពាក់កណ្តាលអាណានិគម និងប្រឆាំងទប់ទល់របបពាក់កណ្តាលសក្តិភូមិ។ គឺបានសេចក្តីថា រំដោះជាតិ និងប្រជាធិបតេយ្យ បានសេចក្តីថា រំដោះជាតិ គឺបំបាត់នូវកម្អែលអាណានិគមនិយមកាលនោះ។ ហើយបំបាត់របបសក្តិភូមិជាបណ្តើរៗ គឺមិនមែនកម្ទេចរបបនាយទុនទេ។ ខ្ញុំសូមបញ្ជាក់។

ពីព្រោះមិនមែនបដិវត្តន៍សង្គមនិយមឯណា ជាបដិវត្តន៍ប្រជាជាតិ ប្រជាធិបតេយ្យ។ ពាក្យថាប្រជាធិបតេយ្យក្នុងទីនេះ បានន័យថា រំដោះកសិករក្រ កសិករដែលគ្មានដី ឲ្យមានជីវភាពរស់នៅសមរម្យ មានការរស់នៅសមរម្យ ស៊ីចុក ស្លៀកពាក់។ ជាក់ស្តែងគឺបន្ថយឈ្នួលស្រែ ការប្រាក់ ខ្ចីបុលបណ្តាក់ ឈ្នួលគោ ឈ្នួលក្របីជាដើម ដើម្បីឲ្យកសិករមានហូប មានចុក មានស្លៀក មានពាក់។

[០៩:១៣:១៦]

ដូច្នោះវាមានភារកិច្ចពីរហ្នឹងជាសំខាន់។ នេះខ្ញុំសូមបញ្ជាក់ម្តងទៀតលោកចៅក្រម សូមជម្រាបលោកប្រធាន។

**ស៖** សូមអរគុណលោក ដែលលោកបានបំភ្លឺ។ សំណួររបស់ខ្ញុំនោះគឺថា ថាតើយុទ្ធវិធី ហើយនិងមាគ៌ាយុទ្ធសាស្ត្ររបស់លោកហ្នឹង គឺបានត្រូវពិភាក្សានៅក្នុងការប្រជុំដំបូងរបស់បក្ស ដែលរៀបចំឡើងនៅក្នុងខែកញ្ញា ឆ្នាំ១៩៦០ ដែរឬទេ?

**ឆ៖** មាគ៌ាយុទ្ធសាស្ត្រ និងយុទ្ធវិធីនេះ គឺធ្វើពីក្រោមទៅលើ លើកបញ្ហាឲ្យសាខាបក្ស ឃុំ វិភាគ ពិភាក្សាគ្នាឲ្យហ្មត់ចត់។ លើកបញ្ហាឲ្យប្រឹក្សា ហើយឡើងមកគណៈកម្មាធិការស្រុក ពីស្រុក

ពិភាក្សាហើយឲ្យតំបន់ពិភាក្សាទៀត។ បានសេចក្ដីថា អនុវត្តនូវប្រជាធិបតេយ្យប្រមូលផ្ដុំពីក្រោមមកលើ។ ដល់ប្រមូលមតិទាំងអស់មកហើយនេះ គណៈមជ្ឈិមបក្សពិនិត្យពិចារណា ហើយធ្វើមហាសន្និបាតដើម្បីសម្រេចនូវមាគ៌ាយុទ្ធសាស្ត្រ យុទ្ធវិធីនេះជាផ្លូវការ។ ដូច្នោះមិនមែនតែជនមួយក្រុមធ្វើទេ គឺធ្វើពីក្រោមមកលើជាលំដាប់លំដោយ។ ខ្ញុំសូមជម្រាបលោកប្រធាន។

[០៩:១៥:៤០]

**ស៖** ចាស៎ សូមអរគុណ។ ឥឡូវនេះខ្ញុំយល់ច្បាស់ហើយ អំពីមាគ៌ាយុទ្ធសាស្ត្រ ហើយនិងមាគ៌ានយោបាយដែលត្រូវធ្វើឡើងហ្នឹង គឺត្រូវបានដាក់ប្រជុំនៅក្នុងកិច្ចប្រជុំនៅក្នុងដំបូង នៅសន្និបាតរបស់បក្សហ្នឹងនៅឆ្នាំ១៩៦០។ លោកបានបញ្ជាក់ថា មានការសម្រេចថា បដិវត្តន៍ជាតិនោះ គឺជាការសំខាន់ ហើយខ្ញុំចង់សួរលោកតទៅទៀត ថាតើបដិវត្តន៍ជាតិនុំងត្រូវបានអនុវត្តដូចម្ដេច? ថាតើត្រូវដាក់បញ្ចូលទាំងការតស៊ូប្រដាប់អាវុធដែរឬទេ?

**ឆ៖** សូមជម្រាប អនុញ្ញាតលោកប្រធានឆ្លើយ។ កាលណោះ នៅតស៊ូនយោបាយនៅឡើយ មិនទាន់តស៊ូនយោបាយរួមផ្សំអាវុធទេ។ ដូច្នោះការតស៊ូនយោបាយរួមផ្សំអាវុធចាប់ផ្ដើមតស៊ូអាវុធនេះ តាំងពីឆ្នាំនៅឆ្នាំ១៩៦៨ បើចាំមិនខុសទេ ៦៨។ ឯពីឆ្នាំ១៩៦០, ៦១, ៦២, ៦៣, ៦៤, ៦៥, ៦៦, ៦៧ នៅធ្វើបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យនៅឡើយ។ ប្រជាជាតិហ្នឹង គឺដូចថា ពួកកម្ពែលអាណានិគមតែម្ដង វាដូចការជិះជាន់សង្កត់សង្កិន ជួនណានៅមាន១កម្ពែលអាណានិគមហ្នឹង តាំងពីក្រាបលុតសំពះអីឡើងទៅ គឺអំណាចនេះនៅមាន រួមទាំងអំណាចសក្ដិភូមិផង។ ទាំងពីរនេះធ្វើព្រមជាមួយគ្នា មិនមានធ្វើបដិវត្តន៍ណាមុន បដិវត្តន៍ណាក្រោយទេ គឺបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យធ្វើព្រមទៅជាមួយគ្នា ដោយយកបដិវត្តន៍ប្រជាធិបតេយ្យធ្វើជាគន្លឹះ ដើម្បីកែប្រែជីវភាពប្រជាជនជាសំខាន់។ ខ្ញុំសូមជម្រាបលោកប្រធាន។

**ស៖** នៅក្នុងទស្សនាវដ្ដីទង់បដិវត្តន៍ច្បាប់ទី៨ ខែសីហា ឆ្នាំ១៩៧៥ ឯកសារ D243/2/1.1 មានចំណុចមួយមានផ្នែកមួយដែលនិយាយលម្អិតអំពីប្រវត្តិការកសាងបដិវត្តន៍ ហើយការកសាងកងទ័ពបដិវត្តន៍កម្ពុជា ហើយនិងមាគ៌ាដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជាផងដែរ។ នេះមានចែងនៅក្នុងអត្ថបទខ្មែរនៅទំព័រ ERN លេខ 00063328។ នៅក្នុងអត្ថបទអង់គ្លេស ERN005386966។ សុំទោសនេះជាអត្ថបទជាភាសាបារាំងទេ គឺបើអង់គ្លេស គឺលេខ 00401491 ហើយខ្ញុំនឹងសូមសួរលោកឲ្យលោកបញ្ជាក់យោបល់នៅក្នុងផ្នែកមួយនេះ។

ទីមួយ ទស្សនាវដ្ដីនោះនិយាយថា "យុទ្ធសាស្ត្រ ហើយនិងមាគ៌ារបស់បក្សកុម្មុយនីស្តកម្ពុជានោះ គឺយ៉ាងច្បាស់ហើយជាគោលការណ៍ដ៏ត្រឹមត្រូវ គឺធ្វើឡើងនៅឆ្នាំ១៩៦០ នៅក្នុងមហាសន្និបាតបក្សលើកទីមួយ"។ ទោះបីជាការណ៍ហ្នឹងជាការពិតក៏ដោយ បក្សនោះត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៥១ មកម្ល៉េះ។ ទស្សនាវដ្ដីនោះក៏បានបន្តនិយាយទៅទៀតថា "កម្មាភិបាលដែលធ្វើការនៅក្នុងទីក្រុងនានាដូចជាក្រុងភ្នំពេញ រៀបចំចាត់តាំង និងកងទ័ពបដិវត្តន៍របស់យើង" ហើយក៏បាននិយាយតទៅទៀតថា "យើងបានសម្រេចយកឈ្មោះកងទ័ពឲ្យបានត្រឹមត្រូវ ហើយឆ្លើយតបទៅតាមកាលៈទេសៈទាំងអស់នេះ"។ យើងមានឈ្មោះច្រើន ប៉ុន្តែឈ្មោះមួយដែលខ្ញុំនៅចាំនោះ គឺជាអង្គភាព គឺថាក្រុមសម្ងាត់ គឺកងការពារសម្ងាត់។ តើលោកនៅចាំពីការពិភាក្សានោះទេ? ហើយនិងការប្រើពាក្យថា "យើងមានកងការពារសម្ងាត់ តាំងពីចំណុចចាប់ផ្ដើមនៃការកសាងកងទ័ពបដិវត្តន៍កម្ពុជា" ដែរឬទេ?

[០៩:២១:៣៨]

**ឆ៖** គោរពលោកប្រធាន ខ្ញុំស្នើអនុញ្ញាតលោកចៅក្រមសួរខ្លីៗបន្តិច ពីព្រោះវែងពេកខ្ញុំស្ដាប់មិនចប់ទេ ហើយភ្លេចមុខភ្លេចក្រោយ ពីព្រោះវាយូរណាស់មកហើយ។ សូមសួរខ្លីៗ សួរច្រើនអ៊ីចឹង សួរច្រើនបញ្ចាចុះ ប៉ុន្តែឲ្យខ្លីៗបន្តិចដើម្បីខ្ញុំស្រួលឆ្លើយ។ បើមិនអ៊ីចឹង ខ្ញុំឆ្លើយមិនអស់ទេ។

**ស៖** ខ្ញុំនឹងសួរលោកដោយសង្ខេប បើដូច្នោះ។ តើកងទ័ពបដិវត្តន៍នោះពីដំបូងហ្នឹងយើងហៅថាជាកងការពារសម្ងាត់ដែរឬទេ?

**ឆ៖** សូមជម្រាបលោកចៅក្រម ពេលនោះពួកវណ្ណៈកាន់អំណាចប្រតិកិរិយា លន់ នល់ ចាប់ចងជិះជាន់ សង្កត់សង្កិនកសិករតាមអំពើចិត្ត។ ចាប់កម្មាភិបាលយកទៅដាក់គុក ដាក់ច្រវាក់ ដោយគ្មានហេតុគ្មានផល។ តាំងពីក្រោយកិច្ចព្រមព្រៀងហ្សឺណែវមករហូតដល់ឆ្នាំដែលលោកចៅក្រមបានលើកមកនេះ។ ដោយពិនិត្យឃើញថា បើកាលណាយើងបណ្ដោយឲ្យវណ្ណៈកាន់អំណាចប្រព្រឹត្តអំពើយង់ឃ្នងឃោរឃៅបែបនេះ មកលើកម្លាំងបដិវត្តន៍ ជាពិសេសមកលើកសិករក្រ បក្សយើងនឹងរលាយ។ ព្រោះយើងគ្មានស្អីទប់ទល់ទេ យើងមានតែបាតដៃទទេ។ ដូច្នោះយើងតស៊ូនយោបាយទទេមិនបានទេ ក៏ប៉ុន្តែវាមិនទាន់ដល់ដំណាក់កាលនៃការតស៊ូអាវុធទេ តែត្រូវមាន គេហៅថាដូចជាលោកមានមតិអ៊ីចឹង កងការពារសម្ងាត់ ដែលជ្រើសរើសយកមកពីកូនចៅកសិករ ដើម្បីការពារ និងជូនកម្មាភិបាលដើរធ្វើការពីភូមិមួយទៅភូមិមួយ ឃុំមួយទៅឃុំមួយ។ បើមិនដូច្នោះទេ ទាហាន ប៉ូលិស មេឃុំ ជំទប់ ចាប់ចងតាមចិត្ត។ ឯកងការពារសម្ងាត់នេះ គ្មានកាំភ្លើង គ្មានអីទេ មានតែដំបងធម្មតា គេហៅថាកាន់ដំបង

ស្របច្បាប់។ គ្មានកាំបិត ពូថៅ ដើម្បីកាប់នេះ កាប់នោះ។ តែវាមានភារកិច្ចជូនកម្មាភិបាលដើរធ្វើការ ដូច្នោះ មិនមែនទាន់ជាកងទ័ពពេញទីទេ ជាកងការពារនៅឡើយ។

[០៩:២៥:២៥]

**សៈ** តើការពារសម្ងាត់នេះ ក៏មាននៅការទទួលខុសត្រូវថែមទៀតទេ ដើម្បីសម្លាប់ខ្មាំង កម្ទេចខ្មាំងដោយសម្ងាត់ដែរឬទេ ដូចដែលមានចែងនៅក្នុងទង់បដិវត្តន៍ កាសែតទង់បដិវត្តន៍ដែលខ្ញុំបានយោងនេះដែរឬទេ?

**ផៈ** កងការពារសម្ងាត់នេះ គ្មានភារកិច្ចសម្លាប់ ឬកម្ទេចទេ មានតែភារកិច្ចការពារកម្មា-ភិបាលប៉ុណ្ណោះ។ ដូច្នោះ គឺយកការសម្ងាត់ជាសំខាន់ ក៏ប៉ុន្តែត្រូវមានអាវុធការពារខ្លួនខ្លះដែរ បើមិនដូច្នោះទេ ខ្មាំងវាធ្វើតាមចិត្ត។ ឯអាវុធនោះ ដូចជាខ្ញុំជម្រាបអ៊ីចឹង គឺថាកាំបិត ពូថៅអី ជាធម្មតា ដូចជាអ្នកស្រែ ជាកសិករ ឃ្វាលគោ ឃ្វាលក្របី ហើយធ្វើនាទីជូនកម្មាភិបាលផងប៉ុណ្ណឹងទេ មិនមានភារកិច្ចអីទៅចាប់ទៅចងទៅអី គ្មានទេ នេះសូមជម្រាប។ ប៉ុន្តែបើចាំបាច់ គេមករើកម្មាភិបាល មកចាប់ចងកម្មាភិបាល កងការពារនេះ ត្រូវតែតស៊ូការពារកម្មាភិបាលតាមលទ្ធភាព។ សូមជម្រាប អស់។

**សៈ** ខ្ញុំសូមអានឲ្យលោកបានស្តាប់អំពីឃ្លាខ្លីមួយនៅក្នុងទស្សនាវដ្តីទង់បដិវត្តន៍ ដែលនិយាយអំពីៗកងការពារសម្ងាត់នេះ បាននិយាយយ៉ាងច្បាស់ដូច្នោះថា “បេសកកម្មរបស់កងការពារសម្ងាត់នេះ គឺការពារមូលដ្ឋានបដិវត្តន៍ ការពារប្រជាជនបដិវត្តន៍ ដើម្បីការពារប្រជាជនបដិវត្តន៍ ការពារកម្មាភិបាលដើរហើរធ្វើការ ការពារសន្និបាត និងការប្រជុំផ្សេងៗ ហើយការពារអ្នកទាំងអស់នេះ ហើយនិងលុបកម្ទេចខ្មាំងជាគិញ និងពួកប្រតិកិរិយាផងដែរ ដើម្បីការពារបក្ស បដិវត្តន៍ និងប្រជាជន”។ តើលោកឯកភាពជាមួយសេចក្តីថ្លែងការណ៍នៅក្នុងទស្សនាវដ្តីទង់បដិវត្តន៍មួយនេះ ដែរឬទេ?

[០៩:២៨:៣៤]

**ផៈ** ត្រង់នេះ វាមានន័យពីរ។ ន័យទីមួយ មិនមែនកងការពារនេះ វាទៅស្វែងរកគិញ រកអីដើម្បីកម្ទេចទេ ក៏ប៉ុន្តែក្នុងករណី ឬក្នុងកាលៈទេសៈណាដែលមានការប្រជុំ ហើយមានពួកគិញ ពួកស៊ើបការណ៍សម្ងាត់ ទៅរកចាប់រកចង កងការពារនេះត្រូវមានភារកិច្ចកម្ចាត់ពួកគិញអស់នេះដែរ។ ខ្ញុំសូមទទួលអ៊ីចឹង។

**សៈ** សូមអរគុណ។ ឥឡូវនេះ ខ្ញុំចង់ចូលទៅដល់ពីចំណុចនេះ ទៅដល់កំណើតនៃកងទ័ពបដិវត្តន៍គឺកងទ័ពបដិវត្តន៍កម្ពុជា ហើយមានសេចក្តីយោងនៅក្នុងទស្សនាវដ្តីទង់បដិវត្តន៍ ឯកសារ

D243/2.1.9 នៅក្នុងអត្ថបទភាសាអង់គ្លេស ERN លេខ00491411។ ERN ជាភាសាខ្មែរ លេខ 00063021។ នៅក្នុងភាសាបារាំង 00504033។

[០៩:៣០:២៨]

នៅក្នុងទស្សនាវដ្ដីទង់បដិវត្តន៍នេះ បានចែងថានៅថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៦៨ កងការពារសម្ងាត់បានបំផ្លែងខ្លួនទៅជាទ័ពព្រៃដែលមានការរៀបចំ ហើយបានបើកការវាយប្រយុទ្ធជាលើកដំបូងដើម្បីវាយប្រហារទីតាំងខ្មាំងនៅភូមិបាយដំរាំ ជាភូមិដែលស្ថិតនៅប្រហែលជា១០ ឬ១១គីឡូម៉ែត្រ នៅខាងលើនៃក្រុងបាត់ដំបង។ តើនេះជាសេចក្តីថ្លែងការណ៍ត្រឹមត្រូវដែរឬទេ តាមអ្វីដែលលោកចងចាំទាក់ទងទៅនឹងការវាយប្រហារដំបូងនេះ គឺនៅថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៦៨?

**ឆ៖** ១២ ឬ១៧?

**ស៖** នៅក្នុងទស្សនាវដ្ដីទង់បដិវត្តន៍និយាយថានៅថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៦៨ ប្រសិនបើលោកចាំ ឬក៏លោកចង់កែកាលបរិច្ឆេទសូមលោកបញ្ជាក់?

**ឆ៖** ក្នុងបញ្ហានេះ ខ្ញុំសូមអនុញ្ញាតពីមូលហេតុបន្តិចដើម្បីឲ្យឯកសារនេះ វាពេញលេញ។ កាលណោះក្រោយពីចលនាបះបោរនៅសំឡូត ពួក លន់ នល់ បញ្ជូនកងទ័ពទាំងរយទាំងពាន់ទៅបង្ក្រាបប្រជាជននៅសំឡូត។ មានរហូតទៅកាត់ក្បាល ដោតនៅរបងផ្ទះ។ បញ្ហានេះវាចេះតែរាលដាលម្តងបន្តិចៗ។ ហើយការបង្ក្រាបក៏កាន់តែធ្ងន់ដៃឡើងៗ។ កាលណោះពួក លន់ នល់ ដែលឃោរឃៅមានដូចជា គូ រុន ខាងប៉ូលិស នេះឃោរឃៅលេខមួយ គ្មានពិចារណាទេ កាប់ សម្លាប់។

ដូច្នេះ ប្រជាជនសំឡូតទ្រាំមិនបានមួយចំនួនរត់ឡើងទៅលើភ្នំវៃចាប អត់បាយ អត់ទឹក ដើម្បីកុំឲ្យគេចាប់ គេចង។ តែមួយចំណែកទៀត ពួកនេះតាមខ្ញុំចាំ ជាកងជីវពលដែលកងរាជរដ្ឋាភិបាលចាត់តាំងឡើង។ កងជីវពលនេះ ជាកូនចៅរបស់ប្រជាជនកសិករក្រីក្រដែលត្រូវគេធ្វើបាបកាប់សម្លាប់។ ដូច្នេះ ទ្រាំមិនបាន ក៏គ្មានអ្នកណាបញ្ជាទេ ស្ម័គ្រចិត្តដោយការក្តៅក្រហាយ មានគ្នាតែ៧នាក់ទេ តាមខ្ញុំចាំ។

[០៩:៣៥:០៥]

ពេលព្រលឹមឡើងទៅវាយៗប៉ុស្តិ៍ប៉ូលិសនៅបាយដំរាំ ភូមិបាយដំរាំ។ បានកាំភ្លើងប្រាំពីរដើមយកមកធ្វើជាទុន។ នេះ ដូច្នោះ តាំងពីហ្នឹងមកចលនាតស៊ូអាវុធចាប់ផ្តើមរាលពីកន្លែងនេះមួយទៅកន្លែងមួយ ពីពាយ័ព្យមកខាងទៅខាងនិរតី។ និរតីយកកាំភ្លើងបានច្រើន ពីនិរតីទៅខាងឧត្តរ។ ដូច្នោះក្នុង

រយៈប្រហែលមួយឆ្នាំ ពេលនោះមាន តាមខ្ញុំចាំដូចមាន១៩ខេត្ត ប្រទេសកម្ពុជាយើងកាលណោះមាន១៩ ខេត្ត។ រាលដាលដល់ ១៧ខេត្តភ្លាម ពីព្រោះទ្រាំមិនបាន។

នេះមិនមែនមូលហេតុមកពីប្រជាជនកសិករឃោរឃៅ កាចសាហាវទេ គឺមកអំពីវណ្ណៈកាន់អំណាចដែលមាន លន់ នល់, សិរិមតៈ ហើយ ទីប្រឹក្សាគឺ សឹង ង៉ុកថាញ់, គួ រុន ដែលជាអ្នកបង្ករឿងបង្កហេតុ ចាប់ចងធ្វើបាបប្រជាជន។ ដូច្នេះ មូលហេតុមកពីវណ្ណៈកាន់អំណាច មិនមែនមកពីប្រជាជនទេ ប្រជាជនរកតែសេចក្តីសុខ សុំតែសេចក្តីសុខ ប៉ុន្តែមិនបានសេចក្តីសុខអស់ផ្លូវហើយ អាហ្នឹងទាល់ច្រកហើយ។ បើកាលណា យើងគ្មានអាវុធការពារខ្លួនទេ មុខតែរលាយហើយ ស្លាប់អស់ហើយ។ នេះខ្ញុំសូមជម្រាបលោកចៅក្រម។

[០៩:៣៧:៣៦]

**ស៖** សូមអរគុណលោក នួន ជា ចំពោះការពន្យល់របស់លោក។ នៅក្នុងកថាខណ្ឌ២៤ នៃដីកាដំណោះស្រាយបានលើកឡើងថានៅថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៦៨ យោងតាមការបង្គាប់បញ្ជាដោយលោក គឺនៅពេលនោះកងកម្លាំងបក្សកុម្មុយនីស្តកម្ពុជាបានធ្វើការវាយលុកទៅលើកងទ័ពរបស់រដ្ឋា-ភិបាលនៅភូមិបាយដំរាំ។ ដូច្នេះ ថាតើការបង្គាប់បញ្ជានោះគឺលោកជាអ្នកចេញឱ្យគេធ្វើដូច្នោះឬដែរឬទេ?

[០៩:៣៨:២៣]

**ជ៖** សូមជម្រាបលោកចៅក្រម ខ្ញុំសុំបដិសេធ។ ពេលនោះ ខ្ញុំមិនបាននៅសំឡូតទេ។ ខ្ញុំនៅឯតាសាញនេះទេ ចលនានេះវាផុសឡើងដោយខ្លួនឯង ពីព្រោះសង្គ្រាមឈ្លប។ អានេះខ្ញុំសូមជម្រាបបន្តិច។ គោលការណ៍សង្គ្រាមឈ្លបយ៉ាងម៉េច ខ្ញុំមិនបានរៀនសូត្រអំពីយោធាទេ ក៏ប៉ុន្តែតាមស្តាប់ពួកអ្នកដែលគេធ្លាប់ធ្វើសង្គ្រាមឈ្លប គេថាសង្គ្រាមឈ្លបនោះ បើចាំបញ្ជាពីលើនោះវាអស់ឱកាសហើយបើយើងមានឱកាសណា យើងត្រូវឆក់ឱកាសភ្លាម។ បើមិនអីចឹងទេ វាខកឱកាស គ្មានឱកាស។ ឱកាសឱ្យ ឬបើគ្មានឱកាសទេ បង្កើតឱកាសដើម្បីប្រយុទ្ធដណ្តើមយកអាវុធពីខ្មាំង។ ឯអាវុធនេះ ឯទៅៗដៃទទេតាមខ្ញុំឮសួរក្រៅ គឺថាអត់មានកាំភ្លើងទេ មានតែកាំបិត ពូថៅ ហើយពេលនោះប៉ូលិសកំពុងជូតកាំភ្លើងៗទេ មិនមែននេះទេ។ ដល់អីចឹង ពួកប្រជាជនសំឡូតនេះទៅកញ្ឆក់ដែលជូតអីៗទាំងអស់នេះយកមកផ្សំផ្គុំគ្នាបានទៅជាអាវុធប្រាំពីរដើម។ ឯខ្លះមិនទាំងស្គាល់ទាំងគ្រាប់កាំភ្លើងផង ស្មានតែគ្រាប់កាំភ្លើងហ្នឹងជានំ អីចេះទៀត។ មិនស្គាល់ទេ។ នេះខ្ញុំសូមជម្រាប។

ដូច្នោះមិនមែនបញ្ហាទេ បើបញ្ហានៃ វាត្រូវមានគ្រប់កន្លែងឲ្យព្រមគ្នា ប៉ុន្តែនេះអត់មាន បើបញ្ហាមិនមែនជាមានបញ្ហាតែជនតែប្រាំពីរនាក់ទេ ត្រូវមានយ៉ាងតិចក៏មួយកងអនុសេនាតូច អីៗដែរទៅវាយដែរ។ នេះខ្ញុំសូមជម្រាប។ ព្រោះកាលនោះខ្ញុំមិនមែននៅ ខ្ញុំអត់នៅសំឡូតទេ ខ្ញុំនៅឯតាសាញឯនេះទេ។

[០៩:៤១:២០]

**ស៖** សូមអរគុណ។ ដូច្នេះការវាយប្រហារនោះ ក្រោយមកកាន់តែមានឈ្មោះទៅល្បីល្បាញទៅ ហើយបានបង្កើតជាមូលដ្ឋាននៃបដិវត្តន៍របស់កងទ័ពបដិវត្តន៍កម្ពុជា។ តើពិតជាដូច្នោះដែរឬទេ?

**ឆ៖** ធម្មតា ពីព្រោះបើគ្មានមូលដ្ឋានបដិវត្តន៍ទេ ខ្មាំងបង្ក្រាបតាមចិត្ត។ ដូច្នោះពួកអ្នកដែលទៅយកកាំភ្លើងបាន ទៅអីបានត្រូវគេចខ្លួនចូលព្រៃ។ តាមខ្ញុំចាំទាំងខាងនិរតី ទាំងខាងអីៗមកនៅឯភ្នំនៃ ដំរីរមៀល ហៅថា ភ្នំដំរីរមៀល នៅជាប់កំពង់ឆ្នាំង និងកំពង់ស្ពឺហ្នឹង ធ្វើជាមូលដ្ឋានបង្អែក។ មូលដ្ឋានបង្អែកនេះលំបាកវេទនាណាស់ គ្មានអង្ករ គ្មានអីទេ។ កងឈ្លបត្រូវដើរទៅសុំអង្ករនៅឃុំផ្សេងៗយកមកឧបត្ថម្ភខ្លួន ហើយបង្កបង្កើនផលខ្លះ។ ខ្ញុំសូមជម្រាបលម្អិតបន្តិច គឺថាពួកកងឈ្លបនេះទៅណាៗដាក់គ្រាប់ល្ពៅទៅតាម ដាក់គ្រាប់ត្រឡាចទៅតាម ទៅដល់ណាដាំត្រង់ហ្នឹងទៅ ទៅដល់ណាដាក់ដីដាំៗទៅដល់យូរៗទៅអាផ្លែហ្នឹងវា-- គ្រាប់ហ្នឹងវាមានផ្លែមក បានហូបបានចុកទៅ ដើរទៅដើរមកបានផ្លែល្ពៅបានផ្លែត្រសក់អីហ្នឹងហូបទៅ។ មានតែប៉ុណ្ណឹងឧបត្ថម្ភខ្លួន ព្រោះកសិករនៅជនបទចុងកាត់មាត់ញកក្រណាស់ ដូចនៅភ្នំឱរ៉ាល់អីចឹង។ ខ្ញុំសូមជម្រាប ភ្នំឱរ៉ាល់នេះក្រលេខមួយហើយ។

[០៩:៤៣:៥៣]

**ស៖** ខ្ញុំចង់សួរថា ថាតើកងទ័ពបដិវត្តន៍របស់បក្សកុម្មុយនីស្តកម្ពុជា ដែលបានបង្កើតឡើងនៅក្នុងខែមករា ឆ្នាំ១៩៦៨ ដែរឬទេ?

**ឆ៖** កងទ័ពបដិវត្តន៍កម្ពុជា តាមខ្ញុំចាំហ៎ កើតនៅឆ្នាំ ដូចចាប់ផ្តើមៗ ឆ្នាំ១៩៦៨ ថ្ងៃទីដប់ៗ-- បើតាមខ្ញុំចាំដូច១២ ខែមករា កុម្ភៈ ខែមីនា យើងមិនដឹង។ ហើយពេលនោះអ្នកណា ពេលនោះ ខ្ញុំជម្រាបឲ្យត្រង់ វៀតណាម ដែលជម្លៀសខ្លួនទៅនៅក្នុងដែនដីកម្ពុជា គេបន្ទោស ទិតៀន បក្សកុម្មុយនីស្តកម្ពុជាថា ឆ្វេងនិយម។ សភាពការណ៍មិនទាន់ទុំទេ ហេតុដូចម្តេចបានជាប្រើអាវុធ។ ដូច្នោះ គេគ្មានឧបត្ថម្ភអី ឬក៏គ្មានអីទេ មានតែបន្ទោស ហើយមិនមែនត្រឹមតែបន្ទោសថែមទាំងបំភ័យទៀតផងថាមិនបានទេ ធ្វើបដិវត្តន៍បនេះ គឺបក្សកុម្មុយនីស្តកម្ពុជាផ្សងព្រេងហើយ ជាបក្សផ្សងព្រេង។ ក៏ប៉ុន្តែយើងខ្ញុំ គណៈកម្មាធិការបក្សក៏មិនបានឈរតបឆ្លើយអី អ្នកឯងចង់ថាម៉េចថាទៅយើងខ្ញុំនៅតែរក្សា

គោលជំហរឯករាជ្យ ម្ចាស់ការ ខ្លួនទីពឹងខ្លួនដដែល។ សម្រេចវាសនាជាតិខ្លួន ដោយខ្លួនឯង។ ឯវៀត-ណាមមិនមែនត្រឹមតែប្រឆាំងមាត់ទទេទេ គឺធ្វើសកម្មភាពប្រឆាំងទៀត គឺធ្វើសកម្មភាពប្រឆាំងយ៉ាងម៉េច?

[០៩:៤៦:៣៦]

ឧទាហរណ៍ ខ្ញុំសូមជម្រាប សូម្បីតែអាវុធមួយដើម ក៏គេមិនឲ្យផង ពីព្រោះមាគ៌ាវាខុសគ្នា គេមិនចង់ឲ្យកម្ពុជាប្រើអាវុធរួមផ្សំនយោបាយទេ ចង់ឲ្យប្រើនយោបាយទទេ។ ដូច្នោះ បានជាមានការជួបគណៈមជ្ឈិម នឹងគណៈមជ្ឈិម គេទទូចហើយទទូចទៀតថា អស់មិត្តនែ៎មិនទាន់ត្រូវការតស៊ូអាវុធទេ។ ចាំកាលណាវៀតណាមសម្រេចហើយនែ៎ ចាំគេទៅរំដោះភ្នំពេញឲ្យ។ នេះខ្ញុំចាំច្បាស់ ជាសម្ដីរបស់ ង្វៀន វ៉ាន់លិញ ក៏និយាយអ៊ីចឹង។ សម្ដីរបស់ ឡេ យន់ ក៏និយាយដូច្នោះដែរ គឺថាយើងធ្វើនេះធ្វើផ្សងព្រេង។ ខ្ញុំសូមជម្រាបប៉ុណ្ណឹង។ តែអ្នកឯងថាម៉េចថាទៅ បក្សកុម្មុយនីស្តកម្ពុជានៅតែរក្សាគោលជំហរ នៅតែរក្សាឯករាជ្យ អធិបតេយ្យភាព បូរណភាពដែនដីរបស់ខ្លួនដដែល។ ខ្លួនជាម្ចាស់សម្រេចវាសនាជាតិខ្លួន ដោយខ្លួនឯង។ ឯវៀតណាមគេធ្វើយ៉ាងម៉េច អាហ្នឹងសម្រេចគេ។

សូមជម្រាបលោកប្រធានប៉ុណ្ណឹង។

[០៩:៤៨:៤៥]

**ស៖** សូមអរគុណ។ វាកន្លងយូរមកហើយ ដូច្នេះហើយខ្ញុំសូមអាននូវសេចក្ដីប្រកាសមួយដែលគេបានលើកឡើងនៅក្នុងទង់បដិវត្តន៍ ដែលមានលេខ ERN 00491406 លេខខ្មែរ គឺ 0063015 លេខបារាំងគឺ 00504027។ នៅក្នុងសេចក្ដីប្រកាសនោះ គឺបានលើកឡើងថា ថ្ងៃទី១៨ ខែមករា ឆ្នាំ១៩៧៧ គឺជាថ្ងៃប្រារព្ធខួបលើទី៩ នៃថ្ងៃបង្កើតកងទ័ពបដិវត្តន៍កម្ពុជា។ ដូច្នេះ ថាតើលោកឯកភាពដែរឬទេ ថាការប្រារព្ធពិធីបង្កើតកងទ័ពនោះ គឺបានធ្វើឡើងនៅថ្ងៃទី១៧ ឬក៏ថ្ងៃទី១៨ ជារៀងរាល់ឆ្នាំ តើមែនដែរឬទេ?

[០៩:៥០:០០]

**ឆ៖** ខ្ញុំសូមជម្រាបលោកចៅក្រម។ ខ្ញុំមិនចាំ ព្រោះវាច្រើនណាស់។

**ស៖** ចំណុចមួយទៀត ដែលខ្ញុំចង់សួរដែរនោះគឺថា ថាតើកងទ័ពបដិវត្តន៍កម្ពុជាបង្កើតឡើងតាមរបៀបណា? លោកបានលើកឡើងកាលពីមុនថា កងការពារសម្ងាត់បានបង្កើតឡើង ហើយវាបានការពារទៅលើកម្មាភិបាល យើងបានដឹងថា ក្រោយពីបានវាយប្រហារនៅភូមិបាយដំរាំ គឺគេតម្រូវនូវ

អារុធ ហើយចាប់បានអារុធខ្លះ។ ដូច្នេះហើយកងទ័ពបដិវត្តន៍កម្ពុជានេះ ប្រាកដជាទទួលហិរញ្ញវត្ថុថវិកាពីប្រភពណាមួយជាមិនខាង ហើយថាតើកងទ័ពបដិវត្តន៍នេះវាបង្កើតឡើងដោយរបៀបណាដែរ?

**ឆ៖** តាមខ្ញុំចាំ ថ្ងៃកំណើតកងទ័ពបដិវត្តន៍កម្ពុជា គឺថ្ងៃ១២ ខែមករា ឆ្នាំ១៩៧៨ ជាថ្ងៃកំណើតរបស់បដិវត្តន៍ ឯការឧបត្ថម្ភខាងថវិកា អានេះគឺថវិកាខាងបក្ខជន។ ខ្ញុំសូមជម្រាបបក្ខជនបង់វិភាគទានក្នុងមួយខែបើមានបង់មួយរៀល មួយខែមួយរៀលៗ។ ដូច្នោះ កងទ័ពនេះប្រជាជនជាកូនចៅរបស់ប្រជាជន ដូច្នោះប្រជាជនគេចិញ្ចឹម ពីព្រោះកូនចៅគេមកធ្វើកងទ័ព គេមិនឲ្យកងទ័ពគេអត់ទេ។ ក៏ប៉ុន្តែឲ្យហូបបរិបូណ៌អី មិនហូបបរិបូណ៌ទេ ប៉ុន្តែខ្ញុំសូមជម្រាបក្នុងព្រៃវាសម្បូរសត្វ ដូច្នោះកាលនោះប្រើកាំភ្លើងកិប លោកចៅក្រមបែបមិនស្គាល់កាំភ្លើងកិបទេ។ កាំភ្លើងកិបនោះ គឺកាំភ្លើងច្រកពីមាត់បាញ់ដាក់រំសេវផារ កាំភ្លើងកិប ឬជួនណាដាក់អន្ទាក់ ដាក់ស្នា ដាក់ធ្នូ ដាក់ខ្នារ។ ដូច្នោះបានសត្វសាច់យកមកបរិភោគទទួលទាន ឯអង្ករយកសាច់ទៅដូរអង្ករជាមួយប្រជាជន ទៅដូរអំបិល។ ដូច្នោះ កងទ័ពនេះវាឧបត្ថម្ភខ្លួនវាបាន ជួយខ្លួនវាបាន។

[០៩:៥៣:៣៥]

**សៈ** នៅក្នុងអំឡុងពេលដ៏យូរនោះ ដែលលោកបានធ្វើការក្នុងការលាក់ខ្លួនដោយសម្ងាត់ ដើម្បីបង្កើតនូវយុទ្ធសាស្ត្រ មាគ៌យុទ្ធសាស្ត្រ និងយុទ្ធវិធីរបស់បក្ស ហើយលោកក៏បានធ្វើដំណើរទៅតាមទីជនបទផងដែរ ដើម្បីជួបជាមួយនឹង ប៉ុល ពត និង អៀង សារី និងកម្មាភិបាលដទៃទៀត។ ដូច្នេះថាតើលោកផ្គត់ផ្គង់ដល់ខ្លួនឯងតាមរបៀបណាដែរ?

**ឆ៖** ប៉ុល ពត និង អៀង សារី គាត់កម្រចុះទៅជនបទណាស់។ កាលនោះទៅតាំងមូលដ្ឋានបដិវត្តន៍នៅឯរតនគិរីឯនោះទេនៅភាគព្រៃសាននោះទេ ឯខ្ញុំនៅភ្នំពេញដើម្បីទទួលខុសត្រូវខាងភូមិភាគឯនេះ។ ឯការ-- អត់ទោសលោកចៅក្រមសួរថាម៉េចអំមិញ? ខ្ញុំភ្លេច។

[០៩:៥៤:៥៣]

**សៈ** ខ្ញុំចង់ដឹង តើលោកដែលជា នួន ជា ជាតើលោករស់រានឧបត្ថម្ភជីវិតរបស់ខ្លួនដោយរបៀបណាក្នុងអំឡុងពេលនោះ ដោយសារតែលោកមិនអាចធ្វើស្រែ មិនបានធ្វើស្រែ មិនបាន់បាញ់សត្វហូបនិងមានផ្លែឈើហូប? ដូច្នេះថាតើលោកឧបត្ថម្ភគ្រួសាររបស់ខ្លួន និងឧបត្ថម្ភខ្លួនឯងដោយរបៀបណា? ហើយធ្វើដំណើរទៅទីជនបទនោះឧបត្ថម្ភខ្លួនឯងដោយរបៀបណាដែរ?

**ឆ៖** អ្នកដែលឧបត្ថម្ភ គឺមូលដ្ឋានបដិវត្តន៍ គេឧបត្ថម្ភ។ ខ្ញុំគ្មានអីទេ មានតែខ្លួនទទេ។ ទៅបាយផ្ទះគេ សុំបាយគេ-- ដាំបាយឲ្យហូប។ មានអីគេឲ្យហូបហ្នឹង និយាយរួមប្រហុក អំបិល ជាមូលដ្ឋានរហូតដល់ប៉ុណ្ណេះទៀត ពេលទៅនៅផ្ទះណា ប្រជាជនជួយលាក់ ជួយបំពួន មិនឲ្យគិញដឹងទេ។ ជួនណាកូនយំថា ម៉ែឃ្លានបាយ ម្ដាយថា ចាំអញបបរឲ្យស៊ីហ្នា ទុកអង្ករដាំបាយឲ្យអាំឯងស៊ីទៅ។ នេះទឹកចិត្តរបស់កសិករក្រីក្រយ៉ាងនេះ។ ឯផ្លែឈើផ្លែអីអត់ខ្វះ ផ្លែគុយក៏មាន ប៉ុន្តែសុទ្ធតែផ្លែឈើព្រៃ ផ្លែគុយហៅថា ផ្លែគុយផ្លែអីហ្នឹង។ មិនមែនមាន-- ប៉ុន្តែបើគេនៅឯជនបទមកខាងកំពង់ចាមឯណេះ គឺសម្បូរប៉ុន្តែខាងខ្ញុំណោះក្រ។ ដូចនៅឱរ៉ាល់នៅអីហ្នឹងមានអីហូប? នៅសំឡូត នៅតាសាញ មានតែដំឡូង ៗន៎ែឈើ ដំឡូងជ្រៅ នេះដែលជាម្ហូបប្រចាំថ្ងៃ។ សូមជម្រាបប៉ុណ្ណឹង។

**ស៖** ត្រឡប់និយាយអំពីកងទ័ពបដិវត្តន៍កម្ពុជា តាំងពីដើមរហូតមកនៅក្នុងឆ្នាំ១៩៦៨ គឺកងទ័ពនេះបានបង្កើតវិវឌ្ឍន៍ទៅជាកងទ័ពមួយ នៅពេលដែលកងទ័ពនោះបានវាយលុកចូលភ្នំពេញនៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥។ ថាតើលោកទទួលអាវុធយុទ្ធភណ្ឌ និងសម្ភារយោធាសម្រាប់កងទ័ពរបស់ខ្លួនពីកងទ័ពផ្សេងដោយរបៀបណា?

[០៩:៥៨:២១]

**ឆ៖** ខ្ញុំសូមជម្រាបថា ពេលនោះមិនបានទទួលកងទ័ព-- អ៊ូមិនបានទទួលអាវុធពេញបរិបូរទេ។ ចិនមានជួយ ប៉ុន្តែវៀតណាមគេដឹកជញ្ជូនឲ្យៗន៎ែ បីភាគ គេយកមួយភាគនេះមួយ។ ម្យ៉ាងទៀត គេដឹកមកឲ្យហើយ គេមិនឲ្យ គេមិនប្រគល់ឲ្យ ឬគេជួនកាលគេថា ច្រឡំៗឲ្យទៅកងទ័ពរណសិរ្សវៀតណាមខាងត្បូង។ ដូច្នោះខាងខ្ញុំ ឧបត្ថម្ភខ្លួនឯងជាសំខាន់ រកខ្លួនឯង។ នេះស្មៀតវៀតណាម។ ខ្ញុំសូមជម្រាបអីចេះទៀត ពេលទៅច្បាំងណ៎ា វៀតណាមយកកូនក្មេងវៀតណាមទៅតាម។ មិនមែនកូនក្មេងតូចទេ អាយុប្រហែលប្អូនប្រាំដណ្ដប់ឲ្យលួនពីក្រោយកងទ័ពយើងខ្ញុំនេះ កងទ័ពខ្មែរ។ ពេលណាវាយបានអាវុធ អាកូនយួននេះវាទាញជើងកងទ័ពខ្មែរនេះមិនឲ្យឡើងទៅយកអាវុធទេ វាទាញជើងមកក្រោយវិញ។ ខ្ញុំសូមប្រើពាក្យអាក្រក់បន្តិចចុះ កងទ័ពខ្មែរអត់មិនបានផាក់ពីក្រោយ។ វាធ្វើដល់ម្ល៉ឹង ហើយសន្យាគ្នាថា បើបានចែកគ្នាពាក់កណ្ដាល បើរឹបាន។ ក៏ប៉ុន្តែ វៀតណាមគេយកទៅទុកឃ្លាំងគេបាត់ទៅ ហើយគេឲ្យតែអាវុធចាស់ៗ។

ខ្ញុំសូមលើកឧទាហរណ៍ ដូចជារឿប៉ុស្ដិ៍នៅអាលាក់កងជើង។ ខ្ញុំឮគេនិយាយទេ ពីព្រោះខ្ញុំមិនមែនកងទ័ពទៅរឿទេ។ សន្យាថាចែកគ្នា ដល់បានកងទ័ពវៀតណាមគេយកទុកបាត់។ មិនត្រឹមតែប៉ុណ្ណឹង

វ៉ៃនៅក្រែក អាហ្នឹងកងទ័ពខ្មែរហើយ កងទ័ពបដិវត្តន៍ខ្មែរវ៉ៃនៅក្រែកបានកាំភ្លើងធំ ង្វៀង វ៉ាន់លិញ មកនិយាយជាមួយខ្ញុំថា មិត្ត!អាកាំភ្លើងធំមិត្តហ្នឹង យកមកផ្ញើខ្ញុំមក។ ខ្ញុំនឹកសង្ស័យ ចុះវៀតណាម គ្មានដីនៅផង មកពឹងដីខ្មែរនៅទៅយកកាំភ្លើងទៅទុកឯណា? អានេះស្មៀតគេ គឺថាមិនឲ្យខ្មែរនេះ មានកាំភ្លើងតែម្តង មានអាវុធល្អទេ អត់ទេ។ អានេះជាការពិត មិនឲ្យយើងម្ចាស់ការខ្លួនឯង មិនឲ្យយើង ឯករាជ្យ មិនឲ្យយើងមានអធិបតេយ្យភាពអីខ្លួនឯង គឺសម្រេចលើគេចាត់ចែងទាំងអស់។ អាក្រក់ ដល់ម្ល៉ឹង។ នេះសូម ហើយមិនទាន់អស់ទៀត លួច។ កាលនោះខ្ញុំសូមជម្រាប ប្រេងសាំងបន្តពីចិន មកខាងរតនគិរី ដាក់ទុយោមក ដើម្បីផ្តល់ឲ្យវៀតណាម ប៉ុន្តែវៀតណាមកុហកចិន ថាដីហ្នឹងដី វៀតណាម ដូច្នោះបន្តមក។

[១០:០២:៣៣]

ប៉ុន្តែដល់ក្រោយ ប៉ុល ពត ជួបចិន ប្រាប់ថា មិនមែនទេ ដីនេះជាដីរបស់ខ្ញុំទេ។ ក៏ប៉ុន្តែ វៀតណាមគេធ្វើទុយោបន្តសាំងតាំងពីជាយដែនវៀតណាម កៅបាំង ឡាំងសឺង បន្តយកមក ហើយគេ យកទាំងអស់ ខ្ញុំគ្មានបានអីទេ ខ្ញុំអត់រវល់ទេ។ ដូច្នោះ បញ្ហាហ្នឹងវាស្មុគស្មាញ វាមិន-- វា១ៗ ខ្ញុំពិបាក និយាយណាស់ ពីព្រោះវាហួសចិត្ត បើនិយាយតាមមែនទែនទៅ វាហួសចិត្ត។ មកពឹងដីខ្មែរនៅ កងទ័ពមកពីជើង មកនៅមកវាយនៅវៀតណាមខាងត្បូង មក១០០ វាយបានតែ២០នាក់ទេ ៨០នាក់ឈឺ ដេកពេទ្យ។ ពេទ្យនៅឯណា? ពេទ្យនៅដីខ្មែរ ឯ២០នាក់ទៀត រកអីស៊ីគ្មានទេ យកគ្រាប់ទៅដូរនឹងចេក របស់បងប្អូនជនជាតិភាគតិចនៅព្លៃសាន បានតែ២០នាក់ទេ។ វាដើរមកតាមផ្លូវហូជីមិញ។

ដូច្នោះ ត្រង់នេះ ខ្ញុំសូមនិយាយឲ្យវាហូរហែ អ្នកខ្លះសង្ស័យថា វៀតណាមមានគុណលើខ្មែរ។ ក៏ប៉ុន្តែការពិត វៀតណាមទេដែលពឹងដីខ្មែរនៅ ខ្ញុំជួបហើយ ឆ្នាំដែលអាមេរិកទម្លាក់គ្រាប់បែកខ្លាំងនៅ វៀតណាម ង្វៀន ធីវប៊ីញ ១ជាមេបញ្ជាការកងទ័ពរណសិរ្ស-- កងទ័ពវៀតណាមខាងត្បូង មកជួបនឹង សោ ភឹម ហើយខ្ញុំនៅនឹង អត់និយាយរកខ្ញុំមួយមាត់ទេ។ ខ្ញុំក៏មិននិយាយ។ ដល់ត្រឡប់ទៅវិញខ្ញុំសួរ សោ ភឹម ថា មកធ្វើអី? មកសុំដីនៅ ពីព្រោះនៅខាងនោះរកដីនៅគ្មានទេ អាមេរិកទម្លាក់ខ្ទេចខ្ទីអស់ ហើយ។ ខ្ញុំប្រាប់ សោ ភឹម ថា រកកន្លែងឲ្យនៅផងទៅ ពីព្រោះគេវ៉ៃអាមេរិកដែរ។ ខ្ញុំយករឿង នេះទៅប្រាប់ ង្វៀន វ៉ាន់លិញ។ ង្វៀន វ៉ាន់លិញ ប្រាប់ខ្ញុំថា ក្រោយមិត្តកុំរវល់ ឲ្យគេរកខ្លួនគេទៅ។ ខ្ញុំមិនដឹងជា ង្វៀន វ៉ាន់ លិញ និយាយហ្នឹង និយាយយ៉ាងម៉េច ខ្ញុំក៏ប៉ាន់ស្មានមិនបាន។ រឿងរ៉ាវហ្នឹងវា ទាក់ទងនឹងវៀតណាម ហ្នឹងវាច្រើនណាស់។ នេះខ្ញុំសូមជម្រាបឲ្យដឹងការពិតនេះៗតុលាការត្រូវការ

ការពិត យុត្តិធម៌ ហើយខ្ញុំត្រូវការឲ្យមានប្រយោជន៍។ នេះខ្ញុំនិយាយនេះ ខ្ញុំឆ្លើយនេះ ដើម្បីឲ្យយុវជនខ្មែរយើងជំនាន់ក្រោយនេះ ឲ្យស្គាល់មិត្ត ស្គាល់សត្រូវ អ្នកណាជាមិត្ត អ្នកណាជាសត្រូវ អ្នកណាមានគុណលើអ្នកណា។ វៀតណាម មកពីត្បូងណ៎ា មកពីជើងណ៎ា គ្មានអីទទួលទានទេ ស្បៀងនៅលើខ្មែរ សេដ្ឋកិច្ចលើខ្មែរ ស្អីៗនៅលើខ្មែរទាំងអស់ ហើយកងទ័ព៥០.០០០នាក់ នៅលើដីខ្មែរ។ អ្នកខ្លះមិនដឹងស្មានខុស ស្មានតែវៀតណាម នេះមកជួយខ្មែរ ប៉ុន្តែការពិតខ្មែរទេ ដែលជួយវៀតណាម ជួយស្រោចស្រង់វៀតណាម ព្រោះអស់ដីនៅហើយៗ។ អាមេរិកទម្លាក់សម្បើមណាស់ នេះខ្ញុំសូមជម្រាបទាំងអស់។

ជម្រាបនៅក្នុងតុលាការនេះ ក៏ដូចជាជម្រាបឲ្យប្រជាជនខ្មែរដែលមិនដឹងការពិត ពីព្រោះមានអ្នកខ្លះមិនដឹងមែន ស្មានតែវៀតណាម នេះជួយខ្មែរ ស្មានតែវៀតណាម នេះមានគុណលើខ្មែរ ព្រោះគេអួត គេអាង ហើយមិនមែនតែអួតអាងនៅក្នុងប្រទេសសម្រាប់កម្ពុជាទេ អួតអាងលើឆាកសកលលោកទៀតផង។ តើខ្មែរកុំឲ្យតែបានវៀតណាម ជួយ អត់ទេ។ ប៉ុន្តែការពិត វៀតណាម ទេដែលមកពឹងដីខ្មែរ។ បើគ្មានដីខ្មែរនៅ គ្មានដីខ្មែរតាំងទ័ព វៀតណាមដួលហើយ។ នេះខ្ញុំសូមជម្រាបការពិតអ៊ីចឹង។ សូមគោរពលោកប្រធាន។

[១០:០៨:១៣]

**ស៖** សូមអរគុណ មុនពេលខ្ញុំបញ្ចប់ការសួរសំណួរទៅដល់លោក នួន ជា ពាក់ព័ន្ធទៅនឹងប្រវត្តិនៃបក្សនេះ ខ្ញុំចង់សួរបញ្ហាមួយចំនួនតូចទៀត មួយឬក៏ពីរទៀត ដែលយើងសួរកាលពីសប្តាហ៍មុន ដែលសំណួរនោះពាក់ព័ន្ធទៅនឹងការបង្កើតមាគ៌ាយុទ្ធសាស្ត្រនិងយុទ្ធវិធី។ កាលពីសប្តាហ៍មុន ខ្ញុំបានសួរលោកថា "ក្នុងអំឡុងពេលដែលលោក និងលោក តា ទូ សាមុត បានពិភាក្សាអំពីមាគ៌ាយុទ្ធសាស្ត្រ និងយុទ្ធវិធី ថាតើនៅពេលនោះ លោកបានពិភាក្សាគ្នាអំពីការបង្កើតលក្ខន្តិកៈ ដែលត្រូវយកមកអនុម័តនៅក្នុងឆ្នាំ១៩៦០" ដែរឬទេ? លោកមិនច្បាស់ថា តើលក្ខន្តិកៈនោះបានអនុម័តនៅពេលណា? ក៏ប៉ុន្តែខ្ញុំសូមឲ្យលោកមើលឯកសារមួយដែលខ្ញុំនឹងស្នើសុំឲ្យមន្ត្រីតុលាការផ្តល់ជូនឯកសារនេះជូនទៅលោក។ វាជាលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា គឺឯកសារលេខ D366/7.1.8.7។ ខ្ញុំសូមឲ្យលោកពិនិត្យមើលលក្ខន្តិកៈនោះ ហើយថាប្រសិនបើអាច សូមឲ្យលោកបញ្ជាក់ថា តើវាជាលក្ខន្តិកៈដែលមានពាមាត្រា ដូចដែលលោកបាននិយាយកាលពីសប្តាហ៍នោះមែនដែរឬទេ?

*(ការបង្ហាញឯកសារ D366/7.1.187)*

[១០:១១:៣៦]

**ឆ៖** ខ្ញុំសូមជម្រាបលោកចៅក្រម តាមខ្ញុំចាំ លក្ខន្តិកៈនេះ វាមានប្រាំបីជំពូក។ ហើយមាន៣០មាត្រា។ ឯលក្ខន្តិកៈ ប៉ុន្តែក្នុងនេះ ឃើញមានតែ២៩មាត្រា ប៉ុន្តែតាមខ្ញុំចាំមាន៣០មាត្រា។ ទាំងអស់មានប្រាំបីជំពូក។

**សៈ** ប៉ុន្តែខ្ញុំចង់បញ្ជាក់ថា នៅក្នុងអត្ថបទភាសាខ្មែរ ដែលលោក នួន ជា កំពុងតែមាននោះ គឺមិនពេញទាំងស្រុងទេ ពីព្រោះអត្ថបទភាសាអង់គ្លេសនោះតាមពិតគឺមានប្រាំបីជំពូក ហើយមាន៣០មាត្រា។ សូមលោកចូលទៅដល់ចំណុចខាងក្រោយដែលបង្ហាញថា នៅក្នុងអេក្រង់របស់តុលាការនេះ តើមានទំព័រផ្សេងទៀតទេ? ដូចដែលយើងឃើញនៅលើអេក្រង់នេះ។

សូមអញ្ជើញបើកមីក្រូហ្វូនពីលោក នួន ជា។ លោក នួន ជា នៅពេលដែលលោកបញ្ជាក់ពេលនោះមីក្រូហ្វូនបិទទេ។ អ៊ីចឹងសូមលោកបញ្ជាក់ម្តងទៀង។

**ឆ៖** ខ្ញុំមើលមិនឃើញទេ។ មើលអេក្រង់នេះមិនឃើញ។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយច៍៖**

មន្ត្រីតុលាការ សូមពិនិត្យមើលអត្ថបទជាមួយលោក នួន ជា ដើម្បីមើលថា តើគាត់មានទំព័រដូចដែលយើងបានបញ្ជាក់ដែរឬទេ? អ៊ីចឹងសូមជួយ។

**លោក នួន ជា៖**

មានមាត្រា៣០ នៅក្នុងជំពូកទី៨។

[១០:១៥:១១]

**សួរដោយចៅក្រម ស៊ីលវៀ ខាតវ៉ាយច៍៖**

**សៈ** សូមអរគុណ អ៊ីចឹងខ្ញុំមានបញ្ហាមួយ ឬពីរទៀត។ កាលពីសប្តាហ៍មុន យើងបានជជែកអំពីការវិវត្តន៍នៃចលនាកុម្មុយនីស្តនៅក្នុងប្រទេសកម្ពុជា ដែលរួមជាមួយការប្តូរឈ្មោះរបស់ខ្លួនមកពីបក្សពលករកម្ពុជា ទៅជាបក្សកុម្មុយនីស្តកម្ពុជាវិញ។ តើត្រឹមត្រូវដែរឬទេ ដែលលោកមិនបានប្រកាសអំពីឈ្មោះថ្មីនេះទេ រហូតទាល់តែបីបួនឆ្នាំក្រោយមកដែលថា លោកមិនបានប្រកាសជាផ្លូវការទេ ថាបក្សកុម្មុយនីស្តកម្ពុជាត្រូវបានបង្កើតឡើងមុនកាលនោះនោះ?

**លោក នួន ជា៖**

**ឆ៖** សូមជម្រាបលោកចៅក្រម លោកប្រធាន មិនមែនបុគ្គលខ្ញុំទេ ការប្រកាសមិនប្រកាស

សម្រេចលើគណៈអចិន្ត្រៃយ៍ដែលមានលេខាបក្ស ប៉ុល ពត ជាអ្នកសម្រេច។ ហេតុដូចម្ដេចមិនទាន់ប្រកាស ពីព្រោះឃើញថាសភាពការណ៍ វាមិនទាន់អំណោយឲ្យយើងប្រកាសចេញមុខបក្សកុម្មុយនីស្ដកម្ពុជានៅឡើយទេ។

[១០:១៦:៥៣]

**ស៖** ហើយតាមពិតនៅក្នុងទស្សនាវដ្ដីទង់បដិវត្តន៍នៅក្នុងច្បាប់ពិសេសខែកញ្ញា ឆ្នាំ១៩៧៧ D24 ឯកសារដូចដែលបានបញ្ជាក់នោះគឺឯកសារ D2432112 នៅក្នុង ERN ខ្មែរ 0063120 ហើយភាសាបារាំង 00492799។ ថាតើសេចក្ដីប្រកាសហ្នឹងបានធ្វើឡើង ថាបក្សបានសម្រេចប្រកាសជាផ្លូវការ ថាបក្សកុម្មុយនីស្ដកម្ពុជាទូទាំងប្រទេស ហើយទៅដល់ពិភពលោកឲ្យបានដឹង តើលោកនៅចាំពីឱកាសពេលនោះដែរឬទេ?

**ឆ៖** ខ្ញុំមិនយល់សំណួររបស់លោកចៅក្រម សូមសួរម្ដងទៀត។

**ស៖** ថាតើការប្រកាសជាផ្លូវការ ជាចំហ ហ្នឹងបានធ្វើឡើងអំពីការបង្កើតបក្សកុម្មុយនីស្ដកម្ពុជាប្រកាសទៅប្រទេស ហើយនិងប្រកាសទៅនឹងពិភពលោក ប្រហែលជា១៧ឆ្នាំ បន្ទាប់ពីបង្កើតបក្សកុម្មុយនីស្ដរួចមកនោះ។ តើដូច្នោះដែរឬទេ? តើលោកនៅចាំបែបនេះដែរឬទេ?

**ឆ៖** សូមជម្រាបលោកចៅក្រម ការចាំវាយូរហើយ ខ្ញុំមិនចាំទេ ក៏ប៉ុន្តែមូលហេតុដែលមិនទាន់ប្រកាស ពីព្រោះពេលនោះ បក្សយើងនៅកំពុងនៅតូច ហើយកំពុងកសាងខ្លួន កំពុងតស៊ូ កំពុងពង្រីកខ្លួន កំពុងចាត់ចែងឲ្យមានជារបៀបរៀបរយ។ ដូច្នោះ បើកាលណាយើងចេះតែប្រកាសទៅៗ វាមានហេតុអីកើតឡើង វាមិនចំណេញដល់បក្ស។ ដូច្នោះ ចាំកាលណាបក្សយើងមានលក្ខណៈគ្រប់គ្រាន់ មានឥទ្ធិ-ពល មានមហាជន គេឧបត្ថម្ភគាំទ្រ ហើយមានអន្តរជាតិឧបត្ថម្ភគាំទ្រ ចាំយើងប្រកាស។ ដូច្នោះ ហើយបានជាពេលនោះ ប៉ុល ពត ធ្វើដំណើរទៅបរទេស ទៅវៀតណាម ទៅចិន ដើម្បីប្រកាសអំពីមាគ៌ានយោបាយយុទ្ធសាស្ត្រ មាគ៌ានយោបាយយុទ្ធវិធីរបស់បក្សកុម្មុយនីស្ដកម្ពុជា។ ក្នុងការដែលទៅនេះ ខ្ញុំសូមជម្រាបថា ប៉ុល ពត ត្រឡប់មកវិញប្រាប់ថា បក្សកុម្មុយនីស្ដវៀតណាម គេមិនសប្បាយចិត្តទេ ដែលយើងមិនបានសួរមតិគេអំពីការធ្វើលក្ខន្តិកៈ ការធ្វើអីនេះ។ ក៏ប៉ុន្តែបក្សចិន គេថាបក្សមិត្តធ្វើមាគ៌ាត្រឹមត្រូវហើយ ដោយឈរលើមូលដ្ឋាននៃការវិភាគវណ្ណៈនៅក្នុងសង្គមកម្ពុជា។ នេះខ្ញុំសូមជម្រាប ដូច្នោះ តាំងពីនោះបក្សកុម្មុយនីស្ដកម្ពុជាក៏មានបក្សបរទេសមកទាក់ទងដូចជា បក្សមកទាក់ទងពិសោធ ដូចជា បក្សថៃ, បក្សភូមា, បក្សស៊ុយអ៊ែត ហើយបក្សណាទៀត ខ្ញុំចាំមិនអស់។ មករៀនសូត្រ

មកសុំផ្លាស់ប្តូរពិសោធន៍គ្នាអំពីបក្សកុម្មុយនីស្តកម្ពុជា។ ដូច្នេះ ឥទ្ធិពលរបស់បក្សកុម្មុយនីស្តកម្ពុជាចេះតែមានឥទ្ធិពលម្តងបន្តិចៗនៅលើឆាកអន្តរជាតិ។

[១០:២២:០០]

**ស៖** ហើយនៅទីបំផុត ខ្ញុំចង់សួរលោក នួន ជា ថាតើលោកនៅចាំទេ នៅពេលដែលមានសេចក្តីសម្រេចក្នុងជម្លៀសទីក្រុងភ្នំពេញនុ៎ង គឺសម្រេចនៅពេលណាដែរ?

**ឆ៖** តាមខ្ញុំចាំ ការសម្រេចជម្លៀសប្រជាជនពីក្រុងភ្នំពេញ នោះគឺសម្រេចច្រើនប្រជុំណាស់។ ដំបូងតាមខ្ញុំចាំដូចជាឆ្នាំ១៩៧៣ បានវិភាគឃើញថាកាលណោះ សភាអាមេរិកបានកាត់ជំនួយដែលយន្តហោះអាមេរិកប្រើទម្លាក់គ្រាប់បែកលើប្រទេសកម្ពុជា។ មជ្ឈិមបក្សកុម្មុយនីស្ត ឬក៏ហៅថា បក្សកុម្មុយនីស្តកម្ពុជាវិភាគឃើញថា បើអាមេរិកឈប់ទម្លាក់គ្រាប់បែកលើប្រទេសកម្ពុជា យើងមានលទ្ធភាពឈ្នះឆាប់ ពីព្រោះកងទ័ព លន់ នល់, សិរិមតៈ ទន់ខ្សោយណាស់ទៅហើយ។ ដូច្នោះយើងត្រូវខំវាយធ្វើម៉េចឲ្យបានឈ្នះមុនវៀតណាម។ បើវៀតណាមឈ្នះមុនខ្មែរ វៀតណាមប្រាកដជាមកឱបក្រសោបយកប្រទេសកម្ពុជាយើងហើយ។ ដល់ឯកភាពគ្នាដូច្នោះហើយបានជាសម្រេចថ្ងៃ១ មករា ១៩៧៥ ជាថ្ងៃបើកឆាកវាយផ្តាច់ព្រាត់ភ្នំពេញ។

**ស៖** ហើយលោកបាននិយាយអំពីការប្រជុំមួយចំនួនដែលឈានទៅដល់សេចក្តីសម្រេចនៅថ្ងៃទី១ ខែមករា។ តើកិច្ចប្រជុំបក្សហ្នឹងជាប្រជុំគណៈមជ្ឈិមបក្ស ឬក៏ប្រជុំអ្វីដែរ?

[១០:២៤:៤៤]

**ឆ៖** កាលណោះតាមខ្ញុំចាំ ប្រជុំមជ្ឈិមបក្សមិនពេញអង្គទេ ហើយសម្រេចៗយ៉ាងនេះ បើកាលណាយើងមានផែនការវាយផ្តាច់ព្រ័ត្រក្នុងឆ្នាំ១៩៧៥ គណៈអចិន្ត្រៃយ៍បក្សបានចាត់តាំងឲ្យគណៈប្រតិភូបក្សកុម្មុយនីស្តកម្ពុជាមាន ប៉ុល ពត មាន នួន ជា ទៅចរចាជាមួយ ង្វៀន វ៉ាន់លិញ ប្រាប់ផែនការអំពីការរំដោះភ្នំពេញ វាយផ្តាច់ព្រ័ត្ររំដោះភ្នំពេញ។ ឲ្យវៀតណាមនេះរហ័សប្រគល់ជំនួយអាវុធ ដែលចិនជួយមក ចិនជួយមកយូរហើយ ក៏ប៉ុន្តែវៀតណាមមិនទាន់ប្រគល់ឲ្យ មិនប្រគល់ឲ្យ សូមឲ្យជួយ១៣ឡានតុងហ្វឹង។ ទើបពីព្រោះពិភាក្សាជាមួយ ង្វៀន វ៉ាន់ លិញ។ ង្វៀន វ៉ាន លិញ សុខចិត្ត ហើយយកអាវុធធុនណាៗ ខ្ញុំមិនដឹងទេ ពីព្រោះខ្ញុំមិនមែនយោធា យកមកប្រគល់ឲ្យនៅភូមិមួយនៅទល់មុខនឹងឆ្លូង ទល់មុខនឹងរោងចក្រធ្វើកែវឆ្លូង។ ខ្ញុំមកពិគ្រោះជាមួយ ប៉ុល ពត ថាបើដាក់ឡានជុំគ្នាទាំង១៣ឡាននៅមួយកន្លែងអ៊ីចឹង ប្រយ័ត្នកប៉ាល់ហោះវាមកទម្លាក់។ មិនបានមួយថ្ងៃ កប៉ាល់ហោះបីគ្រឿង

មកទម្លាក់ខ្មែច អស់ៗទាំងបី អស់ទាំងបីឡានហ្នឹង អស់អាវុធទាំងបីឡានតុងហ្នឹង រហូតដល់គ្រាប់នុំង ផ្ទុះទៅដល់រោងចក្រធ្វើកែវ។ អស់រលីង។

[១០:២៧:២៧]

ក៏ប៉ុន្តែទោះបីជាយ៉ាងនេះហើយក៏ដោយ កងទ័ពបដិវត្តន៍កម្ពុជានៅតែបន្តការតស៊ូតទៅទៀត។ រហូតទាល់តែបានជ័យជម្នះ ពីជ័យជម្នះមួយទៅជ័យជម្នះមួយ។ ខ្ញុំមិនយល់ មិនដឹងថាជា គិញ ឬក៏ជាវៀតណាម ប្រាប់ឲ្យរដ្ឋអំណាច លន់ នល់ មកទម្លាក់គ្រាប់បែក ពីព្រោះគ្មានពីណាដឹង។ ហើយអ្នកដែលទទួលគ្រាប់ហ្នឹង ជាពួកកម្មាភិបាលមកពីខាងជើង ឈ្មោះ ម៉ី ផូ ដែលក្រោយកិច្ចព្រមព្រៀងហ្សឺណែវ ឆ្នាំ១៩៥៤ ទៅរៀននៅវៀតណាមខាងជើងប្រាំមួយដណ្តប់ឆ្នាំ ត្រឡប់មកវិញប្រគល់ភារកិច្ចឲ្យធ្វើឃ្លាំងទុកដាក់អាវុធ ពីព្រោះគេចេះវៀតណាម ទាក់ទងជាមួយវៀតណាមវាស្រួល។

នេះប្រវត្តិរបស់អាវុធបីដណ្តប់ឡានតុងហ្វឹងនេះអស់រលីង ឆេះអស់ខ្ទេច។ ខ្ញុំសូមជម្រាបលោកចៅក្រមប៉ុណ្ណឹង។

[១០:២៩:០០]

**សះ** តើលោកអាចបញ្ជាក់បានដែរទេ ថាលោក និង ប៉ុល ពត បានចូលនៅក្នុងគណៈមជ្ឈិមដែលរៀបបញ្ចូលទាំងកិច្ចប្រជុំវិសាមញ្ញ ដែលធ្វើសេចក្តីសម្រេចដើម្បីជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ?

**ជះ** មានប្រជុំ ខ្ញុំសូមជម្រាប។ ពីព្រោះសភាពការណ៍ការភ្នំពេញ អត់បាយ អត់ស្បៀង តាំងពីឆ្នាំ១៩៧២។ អស់ហើយស្បៀង ឆ្នាំ១៩៧៥ កើតបាតុកម្ម កូដកម្ម មនុស្សអត់ការធ្វើ អ្នកសុំទានច្រើន ទាហានអត់ប្រាក់ខែ។ ដូច្នោះ លន់ នល់ គ្រប់គ្រងស្ថានការណ៍នេះមិនបានទេ ហើយប្រជាជនក៏អត់បាយទៀត។ តាមខ្ញុំដឹង កូនក្មេងស្លាប់ច្រើន នេះតាមសេចក្តីរាយការណ៍របស់អ្នកស៊ើបការណ៍យើងនៅទីក្រុងភ្នំពេញ។ ដោយពិនិត្យសភាពការណ៍យ៉ាងនេះ គណបក្សកុម្មុយនីស្តកម្ពុជាយល់ឃើញថា បើយើងបាន-- វៀតណាមគេក៏ខំរំដោះៗព្រៃនគរដែរ ប៉ុន្តែគេមានផែនការរំដោះព្រៃនគរក្នុងឆ្នាំ១៩៥៦ ឯយើងត្រូវរំដោះភ្នំពេញមុនឆ្នាំ១៩៥៦ គឺយកឆ្នាំ១៩៥៥ ពីព្រោះបើវៀតណាមរំដោះ ហើយបើភ្នំពេញមិនទាន់បានរំដោះទេ វៀតណាមប្រាកដជាយកកងទ័ពធ្វើជាមកជួយរំដោះភ្នំពេញ ហើយគ្រប់គ្រងភ្នំពេញបណ្តោយ។ នេះហេតុផលទីមួយ។

ហេតុផលទីពីរ បើភ្នំពេញបែក ពួកទាហាន លន់ នល់ ពួកទាហាន សឹង ង៉ុកថាញ់ ពួកទាហាន

ដែលជាពួកអ្នកលេងកាប់ចាក់ស៊ីផឹក ដើរលួចដើរប្លន់ប្រជាជនយ៉ាងម៉េច? ប្រជាជនមុខតែលំបាកវេទនាហើយ។ នេះហេតុផលទីពីរ។

[១០:៣២:១៣]

ហេតុផលមួយទៀត យើងនៅជនបទពិតមែនហើយវាខ្វះខាត ក៏ប៉ុន្តែបើប្រៀបធៀបនឹងប្រជាជននៅភ្នំពេញ កាលនោះប្រជាជននៅភ្នំពេញបីលាននាក់ ការរស់នៅនៅជនបទវាមានសហករណ៍ជួយគ្នាឧបត្ថម្ភគ្នាទៅវិញទៅមក។ ដូច្នេះបានសម្រេចថា យើងត្រូវជម្លៀសភ្នំពេញ-- ជម្លៀសប្រជាជនដែលនៅក្នុងទីក្រុងភ្នំពេញបណ្ដោះអាសន្ន ហើយចាំមើលសភាពការណ៍។ តើសភាពការណ៍វាយ៉ាងម៉េច? ហើយពេលនោះអាមេរិកលូកដៃចូលមកទៀត ឬយ៉ាងម៉េច? ដូច្នោះ ដើម្បីកុំឱ្យប្រជាជនត្រូវបាត់បង់អាយុជីវិតយើងត្រូវជម្លៀសប្រជាជនមកចែកគ្នាហូបនៅតាមជនបទ នៅតាមសហករណ៍។ ដូច្នោះហើយបានជាប្រជុំគណៈកម្មាធិការភាគ តើគណៈកម្មាធិការភាគណាយកប្រជាជនប៉ុន្មានៗ កាលនោះតាមខ្ញុំចាំភូមិភាគពាយ័ព្យមានដីល្អបង្កបង្កើនផលបានច្រើន ភូមិភាគពាយ័ព្យដូចជាយកមួយលានប្រាំសែននាក់ទៅ។ ឯភូមិភាគណាដែលតូចៗមិនសូវមាន និរតីក៏យកច្រើនដែរ ខ្លះដែរ ឯភូមិភាគណាដែលមិនសូវមានដីស្រែ មិនសូវអី មិនឱ្យយកតិចណ៎ា។

[១០:៣៤:២៨]

ឯក្រៅពីនេះ ជាធម្មតាទេ អ្នកនៅទីក្រុងភ្នំពេញ គេមិនដែលធ្វើការងារពលកម្ម ហើយមកនេះរួមគ្នាធ្វើ រួមគ្នាហូប ហើយរៀនសូត្រ ពីសហករណ៍នៅតាមជនបទ ប្រែក្លាយអ្នកដែលមិនចេះធ្វើពលកម្ម ឱ្យទៅជាអ្នកពលកម្ម ឱ្យទៅអ្នកទៅធ្វើពលកម្ម។ ប៉ុន្តែធ្វើនេះឱ្យមើលផងប្រជាជនដែលជម្លៀសមកថ្មីនែ៎ ឱ្យគេធ្វើពលកម្មដូចជាយើងប្រជាជនមូលដ្ឋានមិនបានទេ ពីព្រោះគេមិនធ្លាប់ធ្វើពលកម្ម ដូច្នោះឱ្យធ្វើល្មមៗបានហើយ។ ឯរបៀបរបបហូបក៏ឱ្យខុសគ្នាដែរ ឱ្យហូបមួយថ្ងៃបីដង ព្រឹកបបរ ថ្ងៃត្រង់បាយ ល្ងាចបាយ មួយអាទិត្យឱ្យហូបបង្អែមម្ដង។ សហករណ៍ខ្លះគេធ្វើបាន ក៏ប៉ុន្តែក្នុងសហករណ៍នេះខ្ញុំសូមជម្រាបថា មានពួកខូច មានពួកក្បត់ មានពួកសមាសភាពមិនល្អវាបំផ្លាញសហករណ៍ អីវ៉ាន់ដែលដឹកយកទៅពីភ្នំពេញ ដូចជា ចាន ស្លាបព្រាស្អីៗអស់នេះ វាយកទៅចាក់ចោលទន្លេសាបឯនោះ។

[១០:៣៦:១៧]

ដូច្នោះ ធ្វើឱ្យប្រជាជនអត់មានចានហូបបាយ អត់មានអីហូបបាយ។ ខ្ញុំធ្លាប់ឃើញនឹងភ្នែកខ្ញុំ ថ្ងៃ

មួយខ្ញុំជិះឡានម៉ោង៤ទៀបភ្លឺទៅសៀមរាប។ ខ្ញុំឃើញប្រជាជនទាំងហ្វូងៗដើរ ខ្ញុំសួរថា ចុះទៅណាទាំងយប់ហ្នឹង? នែ៎ទៅស្ទូងស្រែ។ ខ្ញុំថា ស្ទូងស្រែអីទាំងយប់? ថាមេគេឲ្យធ្វើអ៊ីចឹង។ ខ្ញុំថាអត់បានទេ។ ធ្វើនេះនែ៎ខុសគោលការណ៍របស់បក្សហើយ ក៏ប៉ុន្តែបើចុះទៅកន្លែងណាដែលប្រាប់មុននែ៎ គេមិនមែនយកអ្នកស្គមស្គាំងមកឲ្យយើងមើលទេ គេយកតែអ្នកណាដែលមានសាច់មានឈាម គ្រាន់បើយកមកបង្ហាញ។ នែ៎!សមាជិកសហករណ៍ ហើយមានកន្លែងខ្លះឆ្អាត អ៊ីចេះទៀតពេលដឹងថា ថ្នាក់ដឹកនាំចុះទៅមើលកាប់មាន់កាប់ជ្រូកព្យួរទុកឲ្យមើល ថាមានហូប។ ប៉ុន្តែដល់ស៊ើបសួរមើលមែនទែនទៅ ចូលជ្រៅទៅថាអត់អីហូប។ នេះខ្ញុំសូមជម្រាបវាមានស្មៀត មានល្បិច មានអីច្រើនណាស់ក្នុងសហករណ៍ហ្នឹង ពីព្រោះដោយច្រើនសុទ្ធតែពួកចម្រុះ ពួកមិនល្អ ពួកសមាសភាពមិនល្អក៏មាន ពួកល្អក៏មានដែរមិនមែនគ្មានទេ។ ដូច្នោះហើយបានជាយើងគ្រប់គ្រងបានមួយ-- សហករណ៍ខ្លះថាហូបឆ្អែត សហករណ៍ខ្លះថាហូបមិនឆ្អែត។ នេះខ្ញុំសូមជម្រាបការពិតវាយ៉ាងនេះ មិនមែនពីព្រោះ ខ្ញុំសូមជម្រាបឲ្យអស់ចុះ។

[១០:៣៨:៤៥]

បក្សកុម្មុយនីស្តកម្ពុជាកសាងនៅក្នុងសង្គម ដែលច្របូកច្របល់ សង្គមដែលមានទំនាស់មានឯកភាពមានទំនាស់ មិនមែនបក្សដែលកសាងចុះមកពីលើមេឃទេ ល្អគ្រប់ដប់នោះមិនមែនទេ។ ដូច្នោះការសិក្សារៀនសូត្រក៏ខំជាពិសេស ខំអប់រំឲ្យសាមគ្គីគ្នា អ្នកចាស់អ្នកថ្មី កុំឲ្យមានការប្រកែប្រកាន់ថាអ្នកនេះ១៧ មេសា អ្នកនេះជាមូលដ្ឋានចាស់ អ្នកនោះជាមូលដ្ឋានថ្មី ក៏ប៉ុន្តែពួកខ្មូចវានៅតែបំផ្លាញ។ ខ្ញុំសូមជម្រាបទៀតដូចជាស្រូវពូជឲ្យរើសស្រូវពូជឲ្យល្អ ពួកខ្មូចវាមិនរើសស្រូវពូជល្អ វារើសចម្រុះស្រូវនេះដាក់ស្រូវនោះស្រូវនោះដាក់ជាមួយគ្នា ដល់ចេញមកដូចជាស្បែកខ្លាអ៊ីចឹង ប្រទូស្តប្រទើស។ ស្ទូងស្រូវទៀត ស្ទូងយកឫសឡើងលើ។ នេះបើចុះទៅឃើញនឹងភ្នែក។ ប៉ុន្តែ បើមិនបានចុះទៅឃើញនឹងភ្នែក វាលើសនេះទៀត។ ដូច្នោះ ការគ្រប់គ្រង ការដឹកនាំ ស្មុគស្មាញណាស់ មិនមែនស្រួលទេ។ ហើយមិនមែន-- ហើយចេះតែចោទ ថាកម្ពុជាប្រជាធិបតេយ្យសម្លាប់ប្រជាជនអស់រាប់លាននាក់។ ប៉ុនអ្នកណាសម្លាប់ប្រជាជន? សួរឲ្យច្បាស់មើល។

[១០:៤០:៤៦]

បក្សកុម្មុយនីស្តកម្ពុជា ជាបក្សដែលស្នេហាជាតិ លះបង់អ្វីៗទាំងអស់ដើម្បីជាតិ ដើម្បីប្រជាជនធ្វើយ៉ាងម៉េចឲ្យប្រជាជនបានឆ្អែត។ ដើម្បីកសាងសង្គមមួយដែលសម្បូរសប្បាយ មិនសម្បូរសប្បាយណាស់ណាទេ ប៉ុនសម្បូរសប្បាយ គឺអ្នកដែលធ្លាប់ក្រនោះ មានហូប មានចុក មានស្លៀក មានពាក់

ហើយចេះតែបណ្តើរៗទៅ ឈានៗម្តងមួយជំហានៗទៅ។ ក៏ប៉ុន្តែការបំផ្លាញផ្ទៃក្នុងបក្សក៏មាន ក្រៅបក្សក៏មាន ជាពិសេសនៅខាងបូព៌ា។ ហើយខ្ញុំសូមជម្រាបទៀត មិនមែនអ្វីៗខ្ញុំចេះតែទម្លាក់ទោសទៅលើវៀតណាមទេ។ វៀតណាម ប៉ុន្មានលានមកហូបចុកនៅក្នុងប្រទេសកម្ពុជា? រាប់ម៉ឺន រាប់សែននាក់ រហូតដល់វៀតណាម មានកិច្ចព្រមព្រៀងប៉ារីស សន្តិភាពហើយ បាន ង្វៀន វ៉ាន់ លិញ នេះ ស្នើសុំឱ្យជួនបញ្ជូនជនជាតិវៀតណាម ទៅវៀតណាមវិញផង ដើម្បីទៅបោះឆ្នោត ក៏ប៉ុន្តែអស់ទេ? វៀតណាមនៅតែបង្កប់ ដើម្បីបំផ្លាញមាគ៌ានយោបាយ ឯករាជ្យសន្តិភាព អព្យាក្រឹត្យភាពរបស់ប្រទេសកម្ពុជា។

ការអត់ ការឃ្លាន ក៏មកអំពីមាគ៌ានយោបាយដែលត្រូវបំផ្លាញ ត្រូវមួលបង្កាច់ ដែលមិនមានកាលណោះ ក្នុងប្រទេសមិនសូវដឹងទេ ឯក្រៅប្រទេសគាត់មិនសូវដឹង។ សូម្បីតែចិនហ្នឹង ក៏មិនដឹងដែរ ស្មានតែវៀតណាម ហ្នឹង មានគុណលើខ្មែរ។ ដូចខ្ញុំបានជម្រាបហើយ ជម្រាបទៀត និយាយតែដដែល។ ទាល់តែបក្ស ទាល់តែលេខាបក្សទៅជម្រាប បំភ្លឺឱ្យចិនយល់ បានចិនថា អំ!អ៊ីចឹងទេអ្ហេះ។ សូមអស់។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោក នួន ជា។

លោកប្រធាន ខ្ញុំពុំមានសំណួរផ្សេងទៀតនោះទេ ក៏ប៉ុន្តែខ្ញុំមានឯកសារមួយចំនួន គឺខ្ញុំសូមដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ប៉ុន្តែអាចធ្វើឡើងក្រោយពេលយើងឈប់បាន សូមអរគុណ។ ឈប់សម្រាកបាន។

[១០:៤៣:៤៨]

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណ។ ឥឡូវនេះដល់ពេលម៉ោងសមល្មមដែលនឹងឈប់សម្រាកនៅពេលព្រឹកហើយ ហើយម្យ៉ាងទៀត ស៊ីឌី ក៏អស់ហើយដែរ ដូច្នេះ អង្គជំនុំជម្រះប្រកាសសម្រាកចំនួនម្ភៃនាទី ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់មួយនិងប្រាំនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

អនុរក្សមន្ទីរឃុំឃាំងនាំលោក នួន ជា ទៅកាន់កន្លែងសម្រាប់រៀបចំទុកសម្រាប់គាត់នៅពីក្រោយមេធាវីរបស់គាត់ចុះ ហើយនិងឱ្យនាំគាត់មកកាន់ទីនេះវិញ មុនពេលអង្គជំនុំជម្រះចូលកាន់អាសនៈ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១០:៤៤ នាទី ដល់ម៉ោង ១១:០៧ នាទី)*

[១១:០៧:៤៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ អម្បាញ់មិញនេះបានស្ដាប់នូវការកត់សម្គាល់របស់លោកស្រីចៅក្រម ខាតវ៉ាយថ៍ ដែលមានបំណងដាក់ឯកសារមួយចំនួននៅចំពោះមុខអង្គជំនុំជម្រះ។ សូមអញ្ជើញលោកស្រីចៅក្រមបន្តភារកិច្ច!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន, ខ្ញុំចង់ជម្រាបដល់ភាគីថា ឯកសារ E141 ហើយឯកសារ ហើយនិងប្រភពផ្សេងៗទៀត បានយោងទៅរកលេខយោងនៅក្នុងកថាខណ្ឌមួយៗ ដែលបានលុបចោលហើយក៏ខ្ញុំចាត់ទុកថាបានដាក់ដេញដោលដែរ ហើយសូមបញ្ជាក់ផងដែរថា ទស្សនាវដ្ដីទង់បដិវត្តន៍បីច្បាប់ដែលខ្ញុំបានយោងនៅក្នុងការតាំងសំណួរលើកមុននោះ ហើយនិងត្រូវចាត់ទុកថា ដាក់ដេញដោលចំពោះមុខអង្គជំនុំជម្រះ D243/1.1 យោងទៅនៅក្នុងកថាខណ្ឌ២១ នៃដីកាដំណោះស្រាយ ទង់បដិវត្តន៍ D243/2.1.9 យោងនៅក្នុងកថាខណ្ឌ២៤ នៃដីកាដំណោះស្រាយ ដីកាបញ្ជូនរឿងមកជម្រះ។ ទង់បដិវត្តន៍ D243/2.1.2 ហើយបានយោងនៅក្នុងកថាខណ្ឌ២៣ នៃដីកាបញ្ជូនរឿងទៅជម្រះ។

បន្ថែមលើនេះដែរ ខ្ញុំសូមដាក់ជូនអង្គជំនុំជម្រះដែរនោះគឺថាលក្ខន្តិកៈទង់បដិវត្តន៍កម្ពុជា ឯកសារ D366/7.1.1 ហើយនិង187។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ,អរគុណលោកស្រីចៅក្រម។ ជាកិច្ចបន្ត តើអស់លោកចៅក្រមនៃអង្គជំនុំជម្រះមានសំណួរអ្វីត្រូវសួរដល់ជនជាប់ចោទ នួន ជា ដែរឬទេ?

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក!

[១១:១០:២៩]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។

**ស៖** សូមគោរព-- ជម្រាបសួរលោក នួន ជា ខ្ញុំមានសំណួរមួយចំនួនដើម្បីបំភ្លឺទៅលើអ្វីដែលលោកបាននិយាយអម្បាញ់មិញនេះ។ ជាដំបូង ខ្ញុំមានសំណួរមួយពាក់ព័ន្ធទៅនឹងពាក្យពេចន៍ គឺវាក្យសព្ទ

ជាច្រើនលើកច្រើនសា--

**ប្រធានអង្គជំនុំ៖**

អត់មានការបកប្រែជាភាសាអង់គ្លេស។ ខាងរដ្ឋបាលមើល ទំនាក់ទំនងខាងអង្គភាពបកប្រែ។

[១១:១១:០៥]

*(មានបញ្ហាខាងបច្ចេកទេស)*

[១១:១១:៣៨]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញចាប់ផ្ដើមលោកចៅក្រម ហ្សង់ម៉ាក រៀបសាជាថ្មី ពីព្រោះអំមិញអត់មានការបកប្រែភាសាអង់គ្លេស។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។

**ស៖** លោក នួន ជា អ្វីដែលលោកបាននិយាយនោះ គឺថាជាច្រើនលើកច្រើនសា--

**ប្រធានអង្គជំនុំ៖**

បញ្ហាដដែលភាសាអង់គ្លេស។ មន្ត្រីគ្រប់គ្រងតុលាការពិនិត្យទំនាក់ទំនងធ្វើកិច្ចការនេះឲ្យបានល្អ។

*(មានបញ្ហាខាងបច្ចេកទេស)*

[១១:១២:២៨]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ប្រសិនបើខ្ញុំផ្លាស់ប្ដូរមីក្រូ តើយើងអាចស្ដាប់ឮបានល្អប្រសើរទេ? ដូច្នេះ យើងនឹងប្រើប្រាស់មីក្រូថ្មី។

តើយើងអាចកែលម្អគុណភាពនៃការបញ្ជូនសំឡេងពីកាប៊ីនភាសាអង់គ្លេស ឬក៏មានបញ្ហាអីសំខាន់លើសពីនេះទៅទៀត?

**អ្នកបកប្រែ៖**

លោកប្រធានអនុញ្ញាតអញ្ជើញចាប់ផ្ដើមបាន បាទ។

[១១:១៣:៥៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក ហ្សង់ម៉ាក ចាប់ផ្ដើមសាជាថ្មី។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ, យើងនឹងព្យាយាមសាកល្បងម្ដងទៀត ថាតើអាចសម្រេចបានទេ ថាគុណសំឡេងវាអាចល្អទេ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** លោក នួន ជា នៅក្នុងសេចក្ដីថ្លែងរបស់លោកជាច្រើនលើកច្រើនសា គឺលោកបានហៅទីក្រុងមួយ គឺឈ្មោះថា "ព្រៃនគរ" គឺលោកបាននិយាយអំពីការរំដោះព្រៃនគរ។ តើលោកអាចជម្រាបតុលាការបានទេ ថាតើលោកចង់យោងសំដៅទៅលើទីក្រុងដែលគេហៅថា ហូជីមិញ-- ទីក្រុងហូជីមិញនេះ ឬក៏អតីតទីក្រុងសៃហ្គន។ តើវាពិតជាអ៊ីចឹងមែនទេ?

[១១:១៩:៥0]

**ឆ៖** សូមជម្រាបលោកចៅក្រម ពីដើមគេហៅ "ព្រៃនគរ" ជាដីខ្មែរ។ ដល់ក្រោយមក គេហៅតាមវៀតណាម ហៅ "សៃហ្គន" ដល់មកសម័យហូជីមិញនេះ ប្រែឈ្មោះថា "ទីក្រុងហូជីមិញ"។

**ស៖** លោក នួន ជា តើវាជាការចៃដន្យ ដែលលោកហៅថា "ព្រៃនគរ" ដែល-- រួចហើយលោកមិនហៅថា ហូជីមិញ ឬក៏ជា-- វាគឺជាឆន្ទៈរបស់លោកតែម្ដងក្នុងការហៅឈ្មោះបែបនេះ?

**ឆ៖** ខ្ញុំមិនមានចេតនាអីត្រូវហៅតាមសម័យឥឡូវ ជួនណាហៅ "ព្រៃនគរ" ជួនណាហៅក្រុង "ហូជីមិញ" តាមធ្លាប់ តាមសម័យគេហៅកាលណោះគេហៅសៃហ្គន។ ហើយមកដល់ឥឡូវទើបតែគេហៅហូជីមិញ ទីក្រុងហូជីមិញ។ ខ្ញុំគ្មានចេតនាអីទេ ព្រោះឈ្មោះនេះវាដូចតែគ្នា។

**ស៖** នៅពេលចាប់ផ្ដើមសួរចម្លើយរបស់លោកពីដំបូង លោកបានបញ្ជាក់ថាលោកមានគំនិតក្នុងការចូលរួមក្នុងជាមួយនឹងចលនាតស៊ូ ពីព្រោះថានៅក្នុងយុវភាពរបស់លោក លោកបានជួបប្រទះនូវរបបអាណានិគមបារាំង ហើយលោកបានឃើញថាតើជនជាតិបារាំងនោះបានធ្វើបាបប្រជាជនកម្ពុជាយ៉ាងណា គឺពួកគេបានចាប់ខ្លួនជនជាតិកម្ពុជា វាយធ្វើបាប ហើយនិងចាប់ញាត់គុកជាដើម។ លោកក៏បានបញ្ជាក់ផងដែរថាត្រូវបានជាសាក្សីឃើញនៅអ្នកមានដែលគាត់បានថាប្រព្រឹត្ត ចំពោះអ្នកក្រ អ្នកទន់ខ្សោយដូចចាត់ទុកពួកគេជាទាសករ ហើយបានវាយធ្វើបាបពួកគេ។ ហើយលោកក៏បានបញ្ជាក់ផងដែរថា គឺនៅពេលដែលឃើញនូវភាពអយុត្តិធម៌បែបនេះ ក្នុងឋានៈជាមនុស្សប្រុសមួយរូប គឺលោកមាន

សមានចិត្ត ហើយនិងការអាណិតអាសូរចំពោះបុគ្គលដែលត្រូវបានគេធ្វើបាបបែបនេះ។ ហើយលោកមានគំនិតក្នុងការតស៊ូ ដើម្បីលុបបំបាត់នូវការគាបសង្កត់បែបនោះ។ តើលោកអាចបញ្ជាក់ជូនបានទេថា តើអ្វីដែលខ្ញុំនិយាយហ្នឹងវាត្រឹមត្រូវនឹងការប្រកាសរបស់លោកដែរឬទេ?

[១១:១៧:៤៩]

**ឆ៖** ខ្ញុំសូមបញ្ជាក់ពេលនោះ ខ្ញុំគ្រាន់តែមាន-- ខ្ញុំមានចិត្តអាណិតអាសូរ ក៏ប៉ុន្តែមិនទាន់មានគំនិតថាទៅតស៊ូអី ដើម្បីនឹងទៅឲ្យបំបាត់អីហ្នឹង អត់នៅទេ ពីព្រោះនៅក្មេង ខ្ញុំនៅអាយុប្រហែលបីប្អូនដណ្ដប់ហ្នឹង។ ប៉ុន្តែមានចិត្តអាណិតអាសូរ មេត្តាករុណាគ្នាអ្នកក្រដែលត្រូវគេធ្វើបាប។ ដល់ក្រោយនេះបានជាខ្ញុំទៅរៀននៅប្រទេសថៃ ខ្ញុំបានអានឯកសារ-- ខ្ញុំបានអានទស្សនាវដ្ដីបក្សកុម្មុយនីស្ដថៃៗនិយាយអំពីវណ្ណៈ និយាយអំពីការជិះជាន់អីៗទៅ បានខ្ញុំភ្ញាក់រឭកម្ដងបន្តិចៗជាលំដាប់ មិនមែនទៅភ្ញាក់រឭកភ្លាមហើយ ខ្ញុំចេញមកតស៊ូភ្លាមនោះទេ អត់ទេ។ វានៅប្រទាញប្រទង់គ្នា រវាងស្នួនខ្លួន ហើយនិងបុគ្គលហើយដែលនិងស្នួនរួម។ ក៏ប៉ុន្តែទីបំផុត ខ្ញុំក៏យកស្នួនរួមជាធំ។ សូមអស់។

**ស៖** លោក នួន ជា នៅពេលដែលលោកប្រើប្រាស់ពាក្យថា អាណិតអាសូរ តើយល់ថាចំពោះលោកគឺវាមានន័យមួយថាតាមបែបសាសនាដែរឬទេ? តើវាមានការយោង ឬសំដៅទៅដល់សាសនាព្រះពុទ្ធអីដែរឬទេលោក?

**ឆ៖** ត្រូវហើយ ខ្ញុំសូមជម្រាបលោកចៅក្រម គឺទាក់ទងនឹងព្រះពុទ្ធសាសនាដែរ ដែលព្រះពុទ្ធសាសនាប្រដៅថា "កុំប្រើអំណាចអាជ្ញា មេត្តា ករុណា មុទិតា ឧបេក្ខា" អីអស់នេះ វាជាប់នៅក្នុង គំនិតរបស់ខ្ញុំអាណិតអាសូរ របៀបជាធម្មតា មិនមែនអាណិតអាសូរជារបៀបបដិវត្តន៍ ដូចជារបៀបវណ្ណៈអីជិះជាន់វណ្ណៈអីនៅឡើយទេ ខ្ញុំមិនទាន់មានអាគំនិតហ្នឹងទេ។

**ស៖** លោក នួន ជា លោកក៏បាននិយាយបែបនេះផងដែលថា ជនជាតិកម្ពុជាគឺជាអ្នកកាន់ព្រះពុទ្ធសាសនា ទោះបីជាពួកគាត់ចូលរួមនៅក្នុងបក្សកុម្មុយនីស្ដក៏ដោយ គឺគាត់នៅតែគោរពនូវសាសនាព្រះពុទ្ធដដែល ហើយនិងគោរពនូវគោលការណ៍នៃព្រះពុទ្ធសាសនា។ ដូច្នេះ ខ្ញុំចង់ដឹងថា តើលោកនិយាយគោលការណ៍នេះ គឺគោលការណ៍អី? ហើយក្នុងចំណោមគោលការណ៍ទាំងអស់នេះ តើមានគោលការណ៍មួយដែលថាយើងត្រូវបដិសេធចោលនូវរាល់អំពើហិង្សាទាំងអស់ ឬក៏គោលការណ៍ក្នុងការគោរពនៃអាយុជីវិតរបស់មនុស្ស?

[១១:២១:១៨]

**ឆ៖** តាមគំនិតខ្ញុំយល់គឺថាបដិវត្តន៍ តាមខ្ញុំយល់ប្រើទ្រឹស្តីសម្ភារៈនិយមបដិច្ចសមុប្បាទ ដូចព្រះពុទ្ធដែរ ប្រើធម៌បដិច្ចសមុប្បាទធម៌ អានេះកើត អានោះកើត អានេះរលត់ អានោះរលត់។ ដូច្នោះ ក្នុងនេះ ក្នុងបដិវត្តន៍ក៏វាប្រហាក់ប្រហែលនឹងព្រះពុទ្ធសាសនាដែរ ដែលប្រដៅឲ្យមនុស្សចេះមេត្តា ករុណា មុទិតា ឧបេក្ខា អាណិតអាសូរ ជួយសង្គ្រោះគ្នាទៅវិញទៅមក។ ក៏ប៉ុន្តែបដិវត្តន៍ បើចាំបាច់គេឈ្លានពានគេប្រើអាវុធ យើងក៏ត្រូវប្រើហិង្សាអាវុធដែរ។ ប៉ុន្តែខាងព្រះពុទ្ធសាសនា ខ្ញុំក៏ឃើញមានប្រើអាវុធដែរ ដែលគេមានពីរឿងជម្លោះ ពីរឿងទឹក រឿងអីឯណា បងប្អូនឯណា ខ្ញុំមិនចាំទេ។ ដូច្នោះមាន ខ ខ្លះប្រហាក់ប្រហែលគ្នា ប៉ុន្តែមាន ខ ខ្លះខុសគ្នា ព្រះពុទ្ធសាសនាប្រើខន្តីៗ ជាបឋម។ ឯខាងបដិវត្តន៍ ខ្ញុំសរុបទៅចុះគឺ កុំអំណាច កុំអាជ្ញា កុំស្រី កុំស្រា កុំលុយកាក់ កុំល្បែងស៊ីសង។ ឯព្រះពុទ្ធសាសនាក៏អ៊ីចឹង មានអ៊ីចឹងដែរ កុំប្រើអំណាចអាជ្ញា កុំស្រី កុំស្រា កុំលួច កុំលុយ កុំកាក់ កុំស៊ីលេងល្បែងស៊ីសង។ ដូច្នោះពីរហ្នឹង ខ្ញុំយល់ឃើញថា ចូលគ្នាបាន។ នេះតាមទស្សនៈរបស់ខ្ញុំ។

[១១:២៣:៥៦]

**ស៖** ដូច្នេះ បើតាមលោកយល់នោះ ជនបដិវត្តន៍នៃបក្សកុម្មុយនីស្តកម្ពុជាអាចគោរពនូវគោលការណ៍បក្សខាង-- ព្រះពុទ្ធសាសនាបានយ៉ាងល្អឥតខ្ចោះ។ ហើយថាតើពួកគេអាចមានអារម្មណ៍អាណិតអាសូរដូចគ្នា ចំពោះជនរងគ្រោះទាំងអស់ នៅពេលដែលពួកគេត្រូវគេធ្វើបាបនោះ ជាពិសេសជនរងគ្រោះដែលត្រូវបានគេចាប់ខ្លួនដោយតាមទំនើងចិត្ត ហើយឬក៏ជនរងគ្រោះដែរក្លាយទៅជាទាសករ ឬក៏ជនរងគ្រោះដែលទទួលរងនូវអំពើហិង្សាដោយអយុត្តិធម៌?

[១១:២៤:៥១]

**ឆ៖** សូមជម្រាបលោកចៅក្រម វាមិនដូចគ្នាទាំងអស់ទេ។ ឯការ-- ពីព្រោះខ្ញុំយល់ឃើញថា បដិវត្តន៍ គឺយកពលកម្មកម្លាំងកាយ និងពលកម្មខួរក្បាល ដើម្បីកសាងប្រទេសជាតិឲ្យចម្រើនរុងរឿង។ ឯពុទ្ធសាសនា គឺយកមេត្តា ករុណា មុទិតា ឧបេក្ខា ដូចជាខ្ញុំជម្រាបអ៊ីចឹង។ បើគ្មានពលកម្មកសាង-- គឺថាខាងបដិវត្តន៍ ពលកម្មកសាងមនុស្ស។ ឯខាងព្រះពុទ្ធសាសនា ក៏មានការទ្រឹស្តី មានការបដិបត្តិដែរ គឺថាប៉ុន្តែបដិបត្តិខាងព្រះពុទ្ធសាសនានេះ កុំច្រឡំ។ ឧទាហរណ៍ដូចជា សម្មាធិៗ នេះខ្ញុំយល់ឃើញថា ជាការកសាងខ្លួនមួយដែរ ធ្វើម៉េចឲ្យសតិអារម្មណ៍ហ្នឹងវាស្អាត វាស្អំ។ ឯខាងបដិវត្តន៍ក៏ធ្វើកម្ចាត់នូវធាតុបុគ្គល ខ្ញុំ ទីនេះខ្ញុំសូមប្រើពាក្យសាមញ្ញទៅចុះ សូមអធ្យាស្រ័យ គឺថាគ្មាន “អញ” បើមាន “អញ” វាមាន “ខ្លួនអញ” បើមាន “ខ្លួនអញ” មាន “អញនិយម” លទ្ធិអញនិយម បើមាន “អញនិយម”

មានកម្មសិទ្ធិឯកជន បើមានកម្មសិទ្ធិឯកជន វាមានទំនាស់ អានេះ។ ដូច្នោះបានជាខាងព្រះពុទ្ធសាសនា ប៉ុន្តែខាងព្រះពុទ្ធសាសនាក៏កម្ចាត់នូវសកាយទិដ្ឋិ កម្ចាត់បុគ្គលដែរ។ វាមានប្រហាក់ប្រហែលគ្នា ក៏ប៉ុន្តែក៏វាមានខុសគ្នាខ្លះដែរ វាមិនមែនត្រូវគ្នាទាំងអស់ទេ។ ឯណាត្រូវគ្នាយើងយកមកប្រើបាន ប៉ុន្តែឯណាខុសគ្នាយើងទុកដោយឡែកសិនទៅ។

[១១:២៧:៥៩]

ខ្ញុំសូមជម្រាបប៉ុណ្ណឹង។ ដូច្នោះទ្រឹស្តីខាងបដិវត្តន៍ និងទ្រឹស្តីខាងព្រះពុទ្ធសាសនាក៏វាមានដូចគ្នា ក៏មានខុសគ្នា។ ដូចជា ការរស់នៅប្រចាំថ្ងៃ ខាងព្រះពុទ្ធសាសនាយក សីល សមាធិ បញ្ញា។ ឯខាងបដិវត្តន៍ គឺខំធ្វើការងារ ក៏សីល ខំតាំងចិត្តធ្វើការងារ គឺសមាធិ ហើយកុំប្រើអារម្មណ៍ ប្រើបញ្ញា ដើម្បីដោះស្រាយបញ្ហា។ នេះវាអ៊ីចឹង ខ្ញុំយល់អ៊ីចឹង។

**សៈ** នេះជាសំណួរចុងក្រោយទៅលើប្រធានបទនេះ។ ពាក់ព័ន្ធនឹងគោលការណ៍នៃការគោរពជីវិតមនុស្ស។ តើគោលការណ៍នេះ គឺថាវាមានលក្ខណៈដូចគ្នានៅក្នុងសាសនា ហើយនិង ឬក៏នៅក្នុងបដិវត្តន៍កុម្មុយនីស្ត?

[១១:២៩:១២]

**ឆៈ** កុម្មុយនីស្តកម្ចាត់តែមនុស្សណាដែលបំផ្លាញជាតិ កែមិនឡើង។ ខ្ញុំសូមជម្រាប អ្នកដែលមិនល្អប្រើការរំឭក ដាស់តឿន ទិតៀន ស្វ័យទិតៀន ម្តង ពីរដង បីដង ហើយឲ្យធ្វើជីវទស្សនបដិវត្តន៍។ ពិនិត្យខ្លួនឯង ហើយឲ្យគេសាកសួរ បើកែប្រែហើយកែប្រែទៀតៗ ជួយកសាងហើយ កសាងទៀតនៅតែមិនកែប្រែទេ អានេះ ត្រូវបណ្តេញចេញពីបក្ស។ បក្សគ្មានសិទ្ធិទៅកម្ទេចនរណាទេ ប៉ុន្តែមានសិទ្ធិបញ្ចុះភារកិច្ចបណ្តេញចេញ ពីបក្ស ហើយរួចទៅបញ្ជូនទៅឲ្យខាងរដ្ឋអំណាច។ សម្រេចខាងរដ្ឋអំណាចគេដោះស្រាយចុះ ឬខាងតុលាការគេដោះស្រាយចុះ។ ឧទាហរណ៍ ដូចជាខូច-- ខ្ញុំដូចជាជម្រាបហើយជម្រាបទៀត បក្សកុម្មុយនីស្តកម្ពុជាវាមិនមែនស្អាតស្អំមួយភាគរយទេ ពីព្រោះវាមិនមែនចុះពីលើឋានសួគ៌ឯណា វាកើត នៅក្នុងសង្គមពុករលួយដែរ។ ដូច្នោះការកសាងបក្សនៅក្នុងដែលស្មុគស្មាញនេះ វាដូចតែគ្នាទេ អ្នកខ្លះក៏កសាងបាន អ្នកខ្លះក៏កសាងមិនបាន អ្នកណាដែលគេកសាងបានក៏គេទៅល្អទៅ អ្នកណាកសាងមិនបានក៏បណ្តេញចេញឲ្យចេញពីបក្សទៅ ឬក៏បញ្ជូនឲ្យទៅធ្វើការកន្លែងផ្សេងទៅធ្វើពលកម្ម ធ្វើអីទៅ។ នេះខ្ញុំសូមជម្រាបអ៊ីចឹង។

[១១:៣១:២៨]

ឯការដែលចោទថា សម្លាប់ ប្រល័យពូជសាសន៍អីៗអស់នេះ ខ្ញុំសូមជម្រាបទៀត តាមទស្សនៈខ្ញុំ សង្គ្រាមមានតែពីរបែបទេ គឺសង្គ្រាមឈ្លានពាន និងសង្គ្រាមការពារប្រទេសជាតិមាតុភូមិ។ អ្នកណាធ្វើសង្គ្រាមឈ្លានពាន? អ្នកណាធ្វើសង្គ្រាមការពារប្រទេសជាតិ? បរទេសកាលនោះ វៀតណាម អាមេរិក ធ្វើសង្គ្រាមឈ្លានពានប្រទេសកម្ពុជា ឯប្រជាជនកម្ពុជាធ្វើសង្គ្រាមការពារប្រទេសជាតិ ការពារមាតុភូមិ ក៏ប៉ុន្តែក្នុងសង្គ្រាមនីមួយៗវាមានច្រើនៗផ្នែកទៅទៀត មានសង្គ្រាមចារកម្ម សង្គ្រាមសន្តិសម្ព័ន្ធ សង្គ្រាមអីៗទាំងអស់ ដើម្បីអី? ដើម្បីធ្វើឲ្យស្មារតីអ្នកធ្វើសង្គ្រាមហ្នឹងវាទន់ខ្សោយ។ ខ្ញុំធ្លាប់ជួបដូចអង្កាល់សង្គ្រាមនៅកម្ពុជា បន្តិចថាមានរឿងនេះ បន្តិចថាមានរឿងនោះ វាន៎ពួកអ្នកដែលធ្វើសង្គ្រាមសន្តិសម្ព័ន្ធ ដើរឃោសនាសូម្បីក្បាលប៊ូឡុងស្ពានមួយណ៎ា ក៏បេ៥២ វាមើលឃើញដែរ។ ដូច្នោះកុំទៅធ្វើសង្គ្រាមជាមួយអាមេរិកនោះ ហើយមនុស្សនោះបីបួននាក់ទៅជ្រកក្រោមដើមឈើន៎ ចំហាយមនុស្សន៎ វាទាញអាបេ៥២ ឲ្យដឹង ហើយវាទម្លាក់កន្លែងហ្នឹង ដូច្នោះឲ្យប្រយ័ត្ន។ នេះសង្គ្រាមចិត្តសាស្ត្រ វាច្រើនបែបច្រើនយ៉ាងណាស់។ ដូច្នោះអាសង្គ្រាមឧក្រិដ្ឋកម្ម សង្គ្រាមប្រល័យពូជសាសន៍អីៗហ្នឹង វាជាផ្នែក វាជាមួយទេនៃសង្គ្រាម វាសង្គ្រាមវាមានតែពីរទេ ខ្ញុំបញ្ជាក់ សង្គ្រាមឈ្លានពាន និងសង្គ្រាមការពារជាតិ មាតុភូមិ។ អ្នកណារកឲ្យឃើញមើលមូលហេតុ អ្នកណាធ្វើសង្គ្រាមឈ្លានពាន? អ្នកណាធ្វើសង្គ្រាម ការពារប្រទេសជាតិ? រកអាហ្នឹងឲ្យឃើញ រកមូលហេតុឃើញហើយ។

[១១:៣៤:០១]

ដូច្នោះតុលាការនេះ មិនបាច់ខាតពេលយូរទេ រកឲ្យឃើញទៅ អ្នកណាធ្វើសង្គ្រាមឈ្លានពាន? អ្នកណា? ខ្មែរ? ខ្មែរតូចមួយប្រជាជនតិច មានទៅឈ្លានពាននរណាបាន ក្រទៀត។ អាមេរិកទម្លាក់គ្រាប់បែក ២០០ថ្ងៃ ២០០យប់ ២លានតោន អស់ដី អស់ភូមិអាករប្រជាជន។ យួនន៎ ចូលឈ្លានពានកម្ពុជាន៎ប្រាំសែននាក់ ថ្ងៃទី៧ មករា --

**ស៖** លោក នួន ជា ខ្ញុំសូមកាត់លោក។ ខ្ញុំគិតថាវាជាការសំខាន់ដែលលោកសុំឆ្លើយ តែទៅនឹងសំណួរដែលខ្ញុំបានចោទសួរបានហើយ។ យើងនឹងត្រឡប់មកអ្វីដែលលោកបានលើកឡើងនេះនៅពេលក្រោយ។ ខ្ញុំសូមឲ្យលោកកម្រិតការឆ្លើយរបស់លោកត្រឹមតែសំណួរ ដែលបានសួរលោកតែប៉ុណ្ណោះ។ លោក នួន ជា សូមឲ្យខ្ញុំនិយាយឲ្យចប់សិន លោក នួន ជា។ សំណួរដែលខ្ញុំបានសួរអម្បាញ់មិញនេះគឺហើយលោកក៏បាននិយាយខ្លួនឯងដែរ គឺពាក់ព័ន្ធទៅនឹងគំនិតដែលត្រូវតែកម្ទេច ឬក៏បោសសម្អាតសមាសភាពមិនល្អ គឺមិនមែនជាសង្គ្រាមទេ គឺវាជា គឺការលុបបំបាត់ចោលនូវសមាសភាពមិនល្អ។ ខ្ញុំ

ចង់ដឹងថា តើមាគ៌ានយោបាយក្នុងការបោសសម្អាតសមាភាពមិនល្អនេះ ត្រូវបានសម្រេចនៅពេលណា ហើយនៅពេលណាដែលលោកត្រូវបានគេបញ្ចុះបញ្ចូលថាត្រូវតែអនុវត្តនូវគោលនយោបាយ មាគ៌ានយោបាយនេះ? តើវាចាប់ផ្ដើមឡើងតាំងពីដំបូង នៅពេលដែលលោកមានវត្តមាននៅប្រទេសថៃ នៅពេលដែលលោកចូលនៅក្នុងបក្សកុម្មុយនីស្តថៃ ឬក៏គំនិត ឬក៏មាគ៌ានយោបាយនេះ គឺថាកើតឡើងនៅពេលក្រោយបន្តិចម្ដងៗមក។ ខ្ញុំសូមឲ្យលោកឆ្លើយតែទៅនឹងសំណួរនេះប៉ុណ្ណោះ។

[១១:៣៦:១៧]

**ឆ៖** ខ្ញុំសូមជម្រាប បដិវត្តន៍គឺកសាងមនុស្ស មិនមែនកម្ទេចមនុស្សទេ។ វៀរលែងតែ អ្នកនោះកែប្រែហើយ ជួយអប់រំកែប្រែហើយ ច្រើនដងហើយ ដូចខ្ញុំនិយាយអ៊ីចឹង មិនកែប្រែ ហើយអ្នកអស់នោះសុទ្ធតែពួកឃោរឃៅ ដែលកែមិនឡើង។ ឧទាហរណ៍ ទាក់ទងចារកម្ម ហៅកប៉ាល់ហោះ បេ៥២ មកទម្លាក់ភូមិករប្រជាជនឲ្យងាប់រាប់រយរាប់ពាន់។ ដាក់ស្លែងដែលនៅ តាប្រ៉ុក កំពង់ចាមខាងលិច ប្រជាជនកំពុងធ្វើបុណ្យ ចារកម្មខ្មែរណ៎ា ដែលជាខ្សែចារកម្មរបស់ លន់ នល់ អាមេរិក ទម្លាក់អស់ប្រជាជនស្លាប់មួយចំហៀងភូមិ។ តើយ៉ាងនេះត្រឹមត្រូវទេ? ខ្ញុំសូមប៉ុណ្ណឹង។

**ស៖** ដូច្នេះ បើតាមលោកយល់ បើតាមលោកគឺថាសមាសភាពមិនល្អត្រូវបានបោសសម្អាតចោលនៅក្នុងពេលបដិវត្តន៍ហ្នឹង គឺសុទ្ធតែពួកចារកម្ម ឬក៏អ្នកដែលថាមិនអាចអប់រំបាន។ តើវាអ៊ីចឹងមែនទេ?

[១១:៣៨:១៨]

**ឆ៖** អ៊ីចឹងមែន ប៉ុន្តែអប់រំនេះមិនមែនអប់រំតែម្ដងទេ អប់រំច្រើនដង។ អប់រំហើយអប់រំទៀតៗ ព្រោះបដិវត្តន៍ទុកមនុស្សជាទុនមួយធំណ៎ា ទុកមនុស្សដើម្បីការពារប្រទេសជាតិ សំខាន់ជាងសម្លាប់មនុស្សដើម្បីការពារប្រទេសជាតិ។ លុះត្រាតែហួសកម្រិត ដូចខ្ញុំបាននិយាយជម្រាបជូនលោកចៅក្រមអម្បាញ់មិញហើយ។

**ស៖** បើខ្ញុំសូមនិយាយរំឭកឡើងម្ដងវិញ ថាតើមាគ៌ានយោបាយនេះត្រូវបានបង្កើតឡើងនៅពេលណា? តើលោកថា គិតថាត្រូវតែបង្កើតគោលនយោបាយនេះនៅពេលណា? ថាតើចាប់ពីពេលដែលលោកចូលរួមនៅក្នុងបក្សកុម្មុយនីស្តថៃ ឬនៅពេលដែលលោកត្រឡប់មកប្រទេសកម្ពុជាវិញ ឬមួយក៏នៅពេលក្រោយ ឬមុន ឬក៏ក្រោយនៃការដួលរលំទីក្រុងភ្នំពេញ?

**ឆ៖** កាលខ្ញុំនៅបក្សកុម្មុយនីស្តថៃ ខ្ញុំមិនដែលបានធ្វើអីទេ ពីព្រោះខ្ញុំមិនមែនជាកម្មាភិបាល ហើយមិនដែលទៅមានតស៊ូទេ។ ឯបញ្ហាដែលនេះ គឺកើតឡើងពេលដែលសង្គ្រាមនៅវៀតណាម វាឆេះឆាបឆេះខ្លាំងតាំងពីឆ្នាំ-- វៀតណាមចាប់ផ្ដើមតស៊ូអាវុធ តាំងពីឆ្នាំ១៩៦០ ចាប់ផ្ដើមតស៊ូអាវុធហើយ។ ដូច្នោះ អាមេរិក ក៏ចាប់ផ្ដើមទម្លាក់គ្រាប់បែកនៅប្រទេសកម្ពុជាឆ្នាំ១៩៦៧ ទម្លាក់នៅតាមជាយដែន។ ដូច្នោះ ការខ្ទេចខ្ទី ការកំហឹងរបស់ប្រជាជនអីៗនេះ វាបង្កើតឲ្យមានស្មារតីជាតិ ស្មារតីស្នេហាជាតិ ស្មារតីស្រឡាញ់ពូជសាសន៍ វាកើតឡើងហើយ។ ដូច្នោះនៅស្ងៀមបានទេ? បើសត្រូវគេធ្វើយ៉ាងហ្នឹងហើយ។ ទម្លាក់គ្រាប់បែកទាំងតោនៗយ៉ាងនេះ ហើយពេលដែលវៀតណាមចូលឈ្លានពានកម្ពុជា ថ្ងៃទី៧ មករា ឆ្នាំ១៩៧៩។ ពេលដែលប្រជាជនជម្លៀសពីព្រៃវែង ស្វាយរៀង មកចាល់នៅទន្លេអ្នកលឿង ឆ្លងទឹកមកនេ៎ះ រថគ្រោះវៀតណាមបើកកិនប្រជាជនប៉ុន្មាន បាញ់រះប្រជាជនអស់ប៉ុន្មាន? ហើយបើកប៉ាល់ហោះទម្លាក់ វាម្យ៉ាងទេ ប៉ុន្តែវៀតណាមនេះចូលទៅដល់ព្រៃជ្រៅ នៅនឹងភ្នំ ទៅរកសម្លាប់អ្នកតស៊ូទៅដល់ហ្នឹង។ គេនិយាយប្រាប់ខ្ញុំ តាម៉ុក អ្នកនិយាយប្រាប់ខ្ញុំគាត់ធ្វើដំណើរពីនិរតី កាត់ភ្នំខ្មោចមក ឃើញនារីហើមប៉ោង រុយរោមអែងាប់មិនដឹងជាប៉ុន្មាន ដោយសារអី ដោយសារកម្លាំងកងទ័ពរបស់វៀតណាម គេចូលជ្រៅទៅតាមព្រៃភ្នំព្រៃអីៗ។ មិនមែន--ខុសពីអាមេរិក អាមេរិកអត់ចូលជ្រៅទេ អានោះគ្រាន់តែទម្លាក់គ្រាប់បែកទេ។

[១១:៤២:៥២]

**សៈ** លោក នួន ជា កាលពីព្រឹកមិញនេះ លោកបានពន្យល់ថាក្នុងពេលណាមួយនោះ គឺចលនាកុម្មុយនីស្តកម្ពុជាមិនបានទៅដល់ក្នុងជំហានតស៊ូដោយអាវុធបដិវត្តន៍ទេ គឺត្រឹមតែការតស៊ូផ្នែកនយោបាយប៉ុណ្ណោះ។ តើលោកអាចពន្យល់បានទេ ថាតើមានភាពខុសគ្នាយ៉ាងណា រវាងការតស៊ូនយោបាយ និងការតស៊ូបដិវត្តន៍ដោយអាវុធ? ហើយខ្ញុំក៏ចង់ដឹងផងដែរ ថាតើនៅក្នុងការតស៊ូដោយនយោបាយ តើមានការមិនប្រើប្រាស់អំពើហិង្សាមួយចំនួនអីដែរឬទេ?

**ឆ៖** តាមខ្ញុំចាំ ខ្ញុំមិនមែនបដិសេធការតស៊ូដោយអាវុធទេ។ រូបភាពតស៊ូនៅប្រទេសកម្ពុជាគឺតស៊ូនយោបាយ សេដ្ឋកិច្ច វប្បធម៌ សង្គមកិច្ច ហើយបើចាំបាច់ត្រូវរួមផ្សំការតស៊ូអាវុធ និងការតស៊ូនយោបាយដោយយកការតស៊ូនយោបាយជាមូលដ្ឋាន ឯការតស៊ូអាវុធគ្រាន់តែដើម្បីពេលនោះ គ្រាន់តែដើម្បីការពារកម្លាំងនៅប្រជាជនមូលដ្ឋាន នៅតាមកន្លែងនីមួយៗទេ។ ដូច្នោះ មិនបដិសេធ ហើយក៏មិនយកការតស៊ូអាវុធធ្វើជាមូលដ្ឋានដែរ នៅតែយកការតស៊ូនយោបាយ។

[១១:៤៤:៤៦]

បញ្ហានេះ មានការវិភាគគ្នានៅក្នុងកងទ័ព។ អ្នកខ្លះនិយាយថា រើសកងទ័ព យកអ្នកណាដែលប៉ិនទាំងតស៊ូ ប៉ិនវ៉ៃ ប៉ិនបាញ់ ប៉ិនអី ប៉ិនអីកាប់ចាក់។ ក៏ប៉ុន្តែខ្ញុំបានសួរវិញ ពីព្រោះកាលណោះខ្ញុំធ្វើគណៈអប់រំ ខ្ញុំថាចុះបើឈ្នះ ហើយបើមកវិញចាប់ជ្រូកប្រជាជន ចាប់មាន់ប្រជាជន រំលោភប្រជាជន តើយ៉ាងម៉េច? តើការតស៊ូអាវុធ ដែលអ្នកឯងតស៊ូឈ្នះហ្នឹង មានតម្លៃប៉ុនណា នេះបានបញ្ហា។

ដូច្នោះ ការតស៊ូអាវុធនេះវាចាំបាច់ណាស់។ ប៉ុន្តែកុំចោលនយោបាយអាវុធ ការតស៊ូអាវុធ ក៏ដើម្បីការពារ ការតស៊ូនយោបាយ ការតស៊ូនយោបាយនេះ វាសំខាន់ជាងការតស៊ូអាវុធ។ ពីព្រោះវាប្រមូលកម្លាំងប្រជាជន ហើយប្រជាជនពេញចិត្តនឹងការតស៊ូនយោបាយជាងការតស៊ូអាវុធ។ បើការតស៊ូអាវុធ វាមិនទាន់ចាំបាច់។

**ស៖** លោក នួន ជា តើមានទំនាក់ទំនងយ៉ាងណារវាងការតស៊ូនយោបាយ ហើយនិងជីវិតនៃចលនានយោបាយនៅក្នុងស្ថាប័នប្រជាធិបតេយ្យដែលចូលរួមនៅក្នុងការបោះឆ្នោត ដែលចូលរួមនៅក្នុងការគោរពរដ្ឋធម្មនុញ្ញនៅពេលដែលលោកនិយាយអំពីការតស៊ូនយោបាយ តើលោកចង់មានន័យថាវាជាការតស៊ូនៅក្នុងចំណោមស្ថាប័នរដ្ឋ ជាលក្ខណៈប្រជាធិបតេយ្យ ឬក៏មានអីខុសប្លែកពីនេះ?

[១១:៤៧:០៣]

**ឆ៖** ខ្ញុំសូមជម្រាប ខ្ញុំស្តាប់សំណួរលោកចៅក្រមមិនបានពេញលេញនោះទេ ប៉ុន្តែខ្ញុំ ដូចដែលខ្ញុំជម្រាបហើយ ការតស៊ូនយោបាយនេះ វាជាមូលដ្ឋាននៃការតស៊ូអាវុធ ឯការតស៊ូអាវុធវាជាបន្ទាប់ទេ។ ពីព្រោះការតស៊ូនយោបាយ ជាការតស៊ូដើម្បីធ្វើឲ្យប្រជាជនភ្ញាក់រឭក ស្រឡាញ់ជាតិ ចុះបើមិនស្រឡាញ់ជាតិ បើមិនទាន់ទៅស្រឡាញ់ជាតិផង ទៅកាន់អាវុធមានតែពួកចោរ។ ពួកចោរវាមានចេះស្រឡាញ់ជាតិអីវា ប៉ុន្តែវាទៅកាន់អាវុធតស៊ូដែរ វាទៅកាន់អាវុធតស៊ូ។ ខ្ញុំលើកតួយ៉ាង ខ្ញុំលើកឧទាហរណ៍ចុះ ឧទាហរណ៍៖ ចលនា សឺង ង៉ុកថាញ់ៗ ថាស្នេហាជាតិ ក៏ប៉ុន្តែពឹងពួកបរទេស។ ស្នេហាជាតិអី? ហើយពេលណាលំបាករត់ទៅបរទេស។ ពេលណាស្រួលត្រឡប់មកប្រទេសវិញ។ បើយ៉ាងនេះ បានតែថាការតស៊ូអីណា អីណាក៏ដោយ នយោបាយវាធំ នយោបាយនេះ វាមានរូបភាពច្រើនដូចជាបំផុសជាបាតុកម្ម ជាកូដកម្ម ជាស្អីៗ ឬតស៊ូនយោបាយនេះតាំងពីរូបភាពតូចទៅ ខ្ញុំសូមលើកឧទាហរណ៍ តាំងពីសាមគ្គីប្រជាជនទៅ តាំងពីធ្វើសមាគមន៍ស្រូវ សមាគមឆ្លងទន្លេ សមាគមប្រវាស់

ដៃគ្នាធ្វើស្រែ។ អានេះសុទ្ធតែនយោបាយហើយនេះ! អ្វីហើយថានយោបាយ? អាហ្នឹងនយោបាយហើយ។

ហើយតាំងពីតូចៗទៅបានវាឡើងទៅសហករណ៍។ សហករណ៍វាមានកម្រិតទៀត សហករណ៍ទាប សហករណ៍ខ្ពស់។ ដូច្នោះបញ្ជាក់ហើយ បញ្ជាក់ទៀតតែដដែលទេ តស៊ូនយោបាយជាមូលដ្ឋានគ្រឹះនៃការតស៊ូអាវុធ។ ការតស៊ូអាវុធគ្រាន់តែជារូបភាព ឯការតស៊ូនយោបាយ គឺតស៊ូខាងសតិអារម្មណ៍ខាងគំនិត។ សំខាន់ណាស់វាយចាញ់មួយសមរភូមិ ពីរសមរភូមិមិនអីទេ ប៉ុន្តែបើចាញ់សមរភូមិគំនិតសមរភូមិសតិអារម្មណ៍ ដេកមិនលក់ទេ អ្នកដឹកនាំ។

**ស៖** លោក នួន ជា នៅក្នុងដំណើរការនៃនយោបាយរបស់លោក ក្នុងចលនាកុម្មុយនីស្តលោកនិយាយអំពីទស្សនៈនៃផ្លូវសភា តាមរយៈលទ្ធិសង្គមនិយម តើលោកមានដែលធ្លាប់ឮគេនិយាយអំពីញត្តិ ឬក៏សំណើដែលត្រូវបានអនុម័តកាលពីឆ្នាំ៦០ បន្ទាប់ពីការស្លាប់របស់ ស្តាលីន។ ហើយបើតាមញត្តិនោះគឺថា វាមិនមានការសំខាន់ទេ ដោយក្នុងការធ្វើតាមរយៈសង្គ្រាមស៊ីវិល ឬក៏ប្រើអាវុធ គឺយើងអាចសម្រេចទៅដល់លទ្ធិសង្គមនិយមបាន តាមរយៈផ្លូវសភា។ គឺថាតាមរយៈស្ថាប័នទូទៅ គឺជាទូទៅតាមរយៈការបោះឆ្នោត។ តើជាអ្វីដែលលោកបានធ្លាប់ស្តាប់ឮ ឬក៏លោកបានគ្រោងទុក?

[១១:៥១:៥០]

**ឆ៖** ជម្រាប រឿងហ្នឹងខ្ញុំមិនដែលឮទេ។ ខ្ញុំយល់ត្រឹមតែបដិវត្តន៍ប្រជាជាតិ ប្រជាធិបតេយ្យ។ ឯនៅកម្ពុជានេះធ្វើបដិវត្តន៍ប្រជាជាតិ ប្រជាធិបតេយ្យមិនទាន់បានសម្រេចផង។ ដូច្នោះ ឈានទៅបដិវត្តន៍សង្គមនិយមយ៉ាងម៉េច? ឈានទៅលទ្ធិកុម្មុយនីស្តយ៉ាងម៉េច? ទៅវាមិនរួចទេ។ ហើយលើសាកលលោកសព្វថ្ងៃនេះ មានប្រទេសណាខ្លះទៅកុម្មុយនីស្តនោះ? វាមិនទាន់មានទេ។ ឯកម្ពុជាពេលនោះទើបនឹងសម្រេចលទ្ធិ ទើបនឹងសម្រេចបដិវត្តន៍ប្រជាជាតិ ប្រជាធិបតេយ្យបានមួយចំណែកណាទេ នៅច្រើនណាស់ដែលធ្វើមិនទាន់អស់។ ដូច្នោះមិនទាន់ឈានទៅសង្គមនិយមអីនឹងគេទេ។

[១១:៥៣:០៣]

**ស៖** បាទ, លោក នួន ជា តើទំនាក់ទំនងរវាងគណបក្សពលករខ្មែរ ហើយនិងក្រុមនយោបាយប្រជាជន ខ្ញុំគិតថាខ្ញុំអានឈ្មោះត្រឹមត្រូវទៅចុះ តើលោកអាចជម្រាបប្រាប់យើងបានទេថា តើមានទំនាក់ទំនងរវាងចលនានយោបាយលួចលាក់នុ៎ង ដែលថាលោកជាសមាជិក ហើយនិងចលនានយោបាយរបស់ក្រុមប្រជាជនដែលជាក្រុមនយោបាយជាចំហ?

**ឆ៖** បញ្ហានេះ វាតែមួយទេ។ ក្រុមប្រជាជនក៏ជាផ្នែកមួយនៃបក្សប្រជាជនបដិវត្តន៍កម្ពុជា មានសមាជិកមួយចំនួនចេញធ្វើសកម្មភាពចំហ ដើម្បីដូចជា ចេញកាសែត ចេញសៀវភៅ ឬក៏បោះឆ្នោតឈរឈ្មោះបោះឆ្នោតអីៗនេះ។ ក្រុមនេះមិនមានទាក់ទងអីជាមួយបក្សសម្ងាត់ទេ បក្សសម្ងាត់វាផ្សេង។ បក្សសម្ងាត់នោះធ្វើការកសាងកម្លាំងប្រជាជន សម្ងាត់ផ្សេង។ ឯក្រុមប្រជាជន ជាក្រុមទេ មិនមែនជាបក្សទេ ជាក្រុម ហើយតាមខ្ញុំចាំមានសមាជិកប៉ុន្មាននាក់ទេ ដូចជា នន់ សួន, កែវ មាស អីៗអស់នេះ ណុប បូផាន់ ដែលជាចាងហ្វាងកាសែត ដែលត្រូវគេបាញ់ស្លាប់ទៅនោះ។ ក្រុមនេះ ធ្វើការភារកិច្ចខុសពីបក្សសម្ងាត់។ បក្សសម្ងាត់ វាដឹកនាំ។ សូមជម្រាបប៉ុណ្ណឹង។

**ស៖** តើសកម្មភាពទាំងអស់នុ៎ង ខុសគ្នា ឬក៏ជាសកម្មភាពបន្ថែម?

**ឆ៖** សកម្មភាពពីរហ្នឹង វាខុសគ្នា។ មួយគេទាក់ទងចំហ គេធ្វើការចំហ ទាក់ទងជាមួយអ្នករាជការ ក្រុមប្រជាជន គេធ្វើសកម្មភាពចំហ។ ឯខាងបក្សធ្វើការសម្ងាត់ ដោយច្រើនណ៎ាទាក់ទងជាមួយកសិករក្រ កម្មករអីៗប្រជាពលករ។ ឯក្រុមប្រជាជនមានលក្ខណៈជារបៀបរណសិរ្សទាក់ទងទៅៗទូទៅ ជាមួយអ្នករាជការ ជាមួយប៉ូលិស ជាមួយទាហានអី ផ្សាយកាសែត ផ្សាយមាគ៌ាអី ផ្សាយមាគ៌ារបស់ក្រុមប្រជាជន មាគ៌ាក្រុមប្រជាជនក៏វាប្រហាក់ប្រហែលគ្នា ស្រដៀងគ្នានឹងមាគ៌ាស្នេហាជាតិ ស្នេហាប្រជាជនអីអ៊ីចឹងដែរ។ វាមិនខុសគ្នាទេ។

[១១:៥៦:៥១]

ប៉ុន្តែក្រុមប្រជាជននេះ វាធ្វើនាទីវាសម្រាប់ទាក់ទងជាមួយរដ្ឋាភិបាល។ ឯបក្សសម្ងាត់នោះវាគ្មានទៅទាក់ទងជាមួយរដ្ឋាភិបាលអីទេ។ ខ្ញុំសូមអស់។

**ស៖** ក្រៅពីក្រុមប្រជាជននេះ មានអ្វីគេហៅថា បញ្ញវន្តចម្រើននិយម ឧទាហរណ៍ដូចជា ហ៊ូ យន់, ហ៊ូ នឹម ព្រមទាំងលោក ខៀវ សំផន ផងដែរ។ តើលោកអាចជម្រាបយើងប្រាប់បានទេ ថាតើមានទំនាក់ទំនងរវាងចលនាកុម្មុយនីស្តលួចលាក់ ឬក៏សម្ងាត់នេះរបស់កម្ពុជា ហើយនិងបញ្ញវន្តចម្រើននិយមនេះ?

[១១:៥៨:០១]

**ឆ៖** ខ្ញុំសូមគោរពលោកប្រធាន! បញ្ហានេះន៎ែ តាមខ្ញុំចាំណ៎ា ប៉ុល ពត មានហៅខ្ញុំទៅប្រាប់ថាមិត្តមិនបាច់ទៅទាក់ទងខាងពួកក្រុមបញ្ញាជនទេ ព្រោះមិត្តអនុវត្តនយោបាយរណសិរ្សមិនសូវផ្ទួរផង់បានសេចក្ដីថា ខ្ញុំនេះមិនសូវចេះនយោបាយការបរទេសទេ។ ដូច្នោះមិត្តគិតតែខាងអប់រំទៅ គិតតែខាង

បក្សយើង ខាងគិតអប់រំកសាងបក្សនេះទៅ ខាងនោះទុកឲ្យគេធ្វើខាងនោះទៅ។ នេះ ប៉ុល ពត ប្រាប់ខ្ញុំច្បាស់អ៊ីចឹង។ ខ្ញុំនឹកក្នុងចិត្តអរម្យ៉ាងដែរ ពីព្រោះខ្ញុំមិនមែនបញ្ញាជនថ្នាក់ខ្ពស់អី ខ្ញុំបញ្ញាជនថ្នាក់បាតក្រោម ហើយគេសុទ្ធតែមកស្រុកបារាំង សុទ្ធតែអីៗ អស់នេះ។

[១១:៥៩:១៣]

ដូច្នោះវាខុស ប៉ុល ពត ប្រាប់ខ្ញុំអ៊ីចឹង។ ប្រាប់ថា ខ្ញុំ-- ព្រោះខ្ញុំមិនចេះនិយាយភាសាបញ្ញាជន។

**ស៖** បើអ៊ីចឹង ខ្ញុំយល់គឺថា ច្បាស់ថា ប៉ុល ពត ប្រាប់ថា លោកមិនត្រូវមានទំនាក់ទំនងជាមួយបញ្ញាជនទាំងអស់នោះទេ។ ក៏ប៉ុន្តែសំណួរខ្ញុំខុសពីនេះ ខ្ញុំចង់ដឹងថា បើតាមលោកដឹងនោះ ចលនាកុម្មុយនីស្តល្បួចលាក់នេះ មានទំនាក់ទំនងជាមួយនឹងបញ្ញាជនចម្រើនទាំងអស់នេះ ឬក៏អត់? ទោះបីថា ប៉ុល ពត ឬក៏អ្នកផ្សេងជាដើមនោះ?

[១២:០០:០៥]

**ឆ៖** ខ្ញុំគ្មានទេ ប៉ុន្តែគេបញ្ញាជនដូចជាមកពីស្រុកបារាំងអីគេមាន គេមានដូច ប៉ុល ពត, សុន សេន, អៀង សារី ដែលជាក្រុមគេហៅថា ក្រុមមកពីស្រុកបារាំងនោះ។ ឯខាងខ្ញុំវាមិនមែនស្រុកបារាំងឯណាខ្ញុំ ខ្ញុំស្រុកខ្មែរ។ ដូច្នោះខ្ញុំទាក់ទងតែជាមួយកសិករប្រជាពលករប៉ុណ្ណឹងទេ។ ឯជាមួយបញ្ញាជនខ្ញុំមិនសូវបានទាក់ទងជាមួយនឹងគេទេ។

**ស៖** លោកអាចជម្រាបយើងបានទេថា តើនៅពេលណាដែលលោកបានជួបជាលើកទីមួយ ស្គាល់ជាលើកទីមួយ ស្គាល់ជនជាប់ចោទរបស់លោកនោះ ឧទាហរណ៍ថា លោក អៀង សារី តើជួបគាត់នៅពេលណានៅលើកទីមួយ ហើយលោកបានជួបលោក ខៀវ សំផន នៅលើកទីមួយហ្នឹងនៅពេលណាដែរ?

**ឆ៖** តាមខ្ញុំចាំពេលដែលមកពីស្រុក-- ពេលដែលរំដោះហើយ។ ហើយ ខៀវ សំផន នោះក៏មិនសូវដែលជួបទេ។ ខ្ញុំមិនដែលជួប ខៀវ សំផន ផង យូរៗបានជួបគ្នាម្តង ប៉ុន្តែគ្រាន់តែជួប ប៉ុន្តែមិនដែលនិយាយអីគ្នាទេ។

**ស៖** ចុះលោក អៀង សារី វិញ?

**ឆ៖** អៀង សារី ធ្លាប់ជួប ព្រោះនៅគណៈអចិន្ត្រៃយ៍ជាមួយគ្នា។

**ស៖** នៅទសវត្សរ៍៥០ ឬក៏៦០ នៅពេលណាទៅឲ្យច្បាស់លាស់មែនទែននោះ?

**ឆ៖** ក្រោយកិច្ចព្រមព្រៀងហ្សឺណែវ។ ហ្នឹងបានជួប អៀង សារី-- ន៎។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ, ខ្ញុំគិតថា ប្រហែលជាដល់ពេលដែលយើងត្រូវសម្រាកហើយ។ លោកប្រធានយល់យ៉ាងម៉េចដែរ?

[១២:០៣:២១]

**ប្រធានអង្គជំនុំ៖**

អរគុណលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍។ ហើយអរគុណលោក នួន ជា។

លោក នួន ជា មុននឹងសម្រាក យើងសួរលោកថា តើរសៀលនេះលោកអាចឆ្លើយនឹងសំណួរបានរយៈពេលប៉ុន្មានដែរនៅរសៀលនេះ?

**លោក នួន ជា៖**

សុខភាពខ្ញុំកាន់តែខ្សោយដែរលោកប្រធាន។ ប៉ុន្តែខ្ញុំខំប្រឹង បើថាអស់ហើយក៏សម្រាក បើថាមិនអស់ទេសួរឱ្យអស់មួយថ្ងៃនេះឱ្យហើយទៅ ប៉ុន្តែកុំសួរវែងពេក។ សួរខ្លីៗដើម្បីខ្ញុំក្តាប់ ព្រោះខួរក្បាលខ្ញុំឥឡូវវាអន់ហើយ តែវែង--

**ប្រធានអង្គជំនុំ៖**

អរគុណ។ អ៊ីចឹងរសៀលនេះលោកអាចបន្តនូវការឆ្លើយបន្តទៀត មែនទេ?

សូមអញ្ជើញលោកមេធាវី!

[១២:០៤:៣០]

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំចង់សូមអនុញ្ញាតពិគ្រោះយោបល់ជាមួយនឹងកូនក្តីរបស់ខ្ញុំសិន ហើយខ្ញុំនឹងឱ្យវេជ្ជបណ្ឌិតធ្វើការពិនិត្យសុខភាពរបស់គាត់មុនពេលដែលខ្ញុំធ្វើការបញ្ជាក់ថាតើជនជាប់ចោទ គាត់មានលទ្ធភាពក្នុងការចូលរួមបន្តឆ្លើយសំណួរទៀតដែរឬទេ។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងមុននឹងសម្រាកនេះ អង្គជំនុំជម្រះជម្រាបទៅលោកវេជ្ជបណ្ឌិតប្រចាំនៅក្នុងសាលសវនាការនេះ ក្នុងការត្រួតពិនិត្យលើបញ្ហាស្ថានភាពសុខភាពរបស់ជនជាប់ចោទទាំងអស់ ហើយនៅចន្លោះពេលនៃការឈប់សម្រាកសូមលោកវេជ្ជបណ្ឌិតធ្វើការពិនិត្យនូវបញ្ហាសុខភាពរបស់លោក នួន ជា ហើយរាយការណ៍មកយើងមកអង្គជំនុំជម្រះឱ្យបានដឹងអំពីស្ថានភាពនេះ មុនពេលចាប់ផ្តើមនៅរសៀលម៉ោង

មួយនឹងសាមសិននាទី។

ឥឡូវនេះពេលវេលា សមល្មមនឹងសម្រាកពិសាអាហារថ្ងៃត្រង់ហើយៗ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការព្រឹកនេះត្រឹមនេះ ហើយសវនាការលើកទៅបន្តនៅរសៀលនេះចាប់ពីម៉ោងមួយនឹងសាមសិបនាទី។

អនុរក្សមន្ទីរឃុំឃាំងឲ្យនាំជនជាប់ចោទទាំងបីរូប ទៅកាន់បន្ទប់រង់ចាំនៅក្រោមសាលសវនាការនេះ ហើយឲ្យនាំពួកគាត់ត្រឡប់មកកាន់សាលសវនាការនេះ ឲ្យបានមុនម៉ោងមួយនឹងសាមសិបនាទី។

សូមអញ្ជើញសម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១២:០៧ នាទី ដល់ម៉ោង ១៣:៣៤ នាទី)*

[១៣:៣៤:៤៤]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅមុនពេលសម្រាកពិសាថ្ងៃត្រង់ អង្គជំនុំជម្រះបានចាត់ឲ្យគ្រូពេទ្យប្រចាំនៅក្នុងសាលសវនាការនេះ ពិនិត្យស្ថានភាព សុខភាពរបស់លោក នួន ជា ហើយតាមរបាយការណ៍នេះគឺការវាយតម្លៃរបស់គ្រូពេទ្យថា មិនមានការប្រែប្រួលអ្វីឡើយ អាចបន្តសវនាការបាន។

ហេតុដូច្នេះអង្គជំនុំជម្រះប្រកាសបន្តក្នុងការសួរចម្លើយជនជាប់ចោទ នួន ជា។

សូមអញ្ជើញ លោក នួន ជា!

**លោក នួន ជា៖**

លោកប្រធាន ខ្ញុំគ្មានកម្លាំងបន្តទៀតទេ សូមផ្អាក សូមសិទ្ធិផ្អាក សុំស្អែកសូមបន្តទៀត ព្រោះអស់កម្លាំងណាស់។

[១៣:៣៦:៤២]

**ប្រធានអង្គជំនុំ៖**

បាទ,ឥឡូវដោយសារគាត់បង្ហាញអំពីភាពនឿយហត់របស់គាត់ ហើយតាមស្ថានភាពវ័យ ហើយអង្គជំនុំជម្រះបានយល់ព្រមតាមសំណើនេះ ដោយនឹងបន្តស្តាប់ចម្លើយលោក នួន ជា នៅថ្ងៃស្អែក ឬក៏

ថ្ងៃបន្ទាប់ទៀត។

ឥឡូវនេះឈានចូលដល់ការស្ដាប់នូវចម្លើយរបស់លោក អៀង សារី ជាបន្ត។

អនុរក្សមន្ទីរឃុំឃាំងនាំលោក អៀង សារី មកកាន់ឈើរាងវង់ក្រចកសេះនៅពីមុខអង្គជំនុំជម្រះនេះ!

*(លោក អៀង សារី ធ្វើដំណើរទៅកាន់ឈើរាងវង់ក្រចកសេះ)*

[១៣:៣៩:០៦]

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** បាទ, សួស្ដីលោក អៀង សារី! តើលោកឈ្មោះ អៀង សារី អ៊ីចឹងពិតមែនដែរទេ?

**លោក អៀង សារី៖**

**ឆ៖** (មិនឮសំឡេង)

**ស៖** ក្រៅពីឈ្មោះ អៀង សារី តើលោកធ្លាប់ដែលបានប្រើឈ្មោះអ្វីផ្សេងទៀតដែរទេ?

**ឆ៖** វ៉ាន់។

**ស៖** ក្រៅពីឈ្មោះ វ៉ាន់ ហ្នឹង តើលោកមានដែលឈ្មោះប្រើឈ្មោះ គឹម ត្រឹង ដែរឬទេ?

**ឆ៖** ស្រុកកំណើតខ្ញុំនៅកម្ពុជាក្រោម ដូច្នេះ ឈ្មោះខ្ញុំមែនទែនហ្នឹងគឺ គឹម ត្រឹង។

[១៣:៤០:០០]

**ស៖** បាទ, អរគុណ។ ហើយតើថ្ងៃខែឆ្នាំកំណើតរបស់លោក លោកកើតថ្ងៃខែឆ្នាំណាដែរ?

**ឆ៖** ថ្ងៃ២៤ ខែតុលា ឆ្នាំ១៩២៥។

**ស៖** បាទ, អរគុណ។ ចុះទីកន្លែងកំណើតរបស់លោក ដែលលោកបានអះអាងអំមិញថា នៅកម្ពុជាក្រោមនោះ តើនៅភូមិស្រុកខេត្តអ្វីដែរ នៅកម្ពុជាក្រោម?

**ឆ៖** នៅភូមិលឿងវ៉ា ស្រុកត្រាវិញ ខេត្តត្រាវិញ។

**ស៖** បាទ, អរគុណ។ ហើយទីលំនៅដ្ឋាន មុនពេលចាប់ឃុំខ្លួន តើលោករស់នៅទីកន្លែងណា?

**ឆ៖** នៅក្រោយស្ថានទូតរុស្ស៊ី នៅជាប់ខាងវត្តស្វាយពពែ។ ខ្ញុំមិនចាំលេខផ្ទះអីទៀតទេ ឥឡូវហ្នឹង។

**ស៖** កាលពីនៅក្នុងអំឡុងពេលស៊ើបសួររបស់ចៅក្រមស៊ើបអង្កេត លោកបានឆ្លើយថា លោកនៅផ្ទះលេខ៤៧B ក្រុមទី៣៦ មណ្ឌល៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន តើត្រឹមត្រូវដែរឬទេ?

[១៣:៤១:២៩]

**ផ៖** ផ្ទះកូនខ្ញុំ ហើយខ្ញុំនៅជាមួយកូនខ្ញុំ។

**ស៖** ចុះ ឪពុករបស់លោកវិញ តើឈ្មោះអ្វីដែរ?

**ផ៖** គឹម រៀម។

**ស៖** បាទ, អរគុណ។ ចុះម្ដាយបង្កើតរបស់លោកឈ្មោះអ្វីដែរ?

**ផ៖** ត្រាន់ ធិឡឹយ។

**ស៖** ចុះប្រពន្ធរបស់លោកវិញ ឈ្មោះអ្វីដែរ?

**ផ៖** ធីរិទ្ធ។

**ស៖** លោកមានកូនប្រុសស្រីប៉ុន្មាននាក់?

**ផ៖** ស្រី៣នាក់ កូនប្រុសម្នាក់។

**ស៖** តើលោកមានបងប្អូនបង្កើតប៉ុន្មាននាក់ដែរ? ហើយលោកជាកូនទីប៉ុន្មាន?

**ផ៖** កូនបង្កើតមាន៣នាក់។ បងប្រុសមួយ, បងស្រីមួយ ហើយខ្ញុំ កូនពៅ។

**ស៖** លោក អៀង សារី តើលោកអាចនិយាយដោយសង្ខេបបានទេ អំពីប្រវត្តិសិក្សាសូត្ររបស់លោកតាំងពីកុមារភាព រហូតដល់ពេលដែលលោកមកធ្វើការងារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ?

**ផ៖** សូមគោរពលោក!

[១៣:៤៣:០៨]

**លោក ម៉ៃខល កាណាវាស៖**

សូមអភ័យទោសលោកប្រធាន លោក លោកស្រីចៅក្រម។ នៅឆ្នាំ២០១១ ខែតុលា យើងបានដាក់នូវពាក្យស្នើសុំមួយគឺ ដែលលោក អៀង សារី គាត់បានបដិសេធ គាត់មិនមានចេតនានឹងឆ្លើយសំណួរនោះទេ។ ហើយចៅក្រម អាចសួរគាត់អំពីអត្តសញ្ញាណបាន ប៉ុន្តែនៅពេលនេះ គឺថាគាត់នឹងអាននូវសេចក្ដីថ្លែងការណ៍ដែលគាត់បានរៀបចំហើយ។ ហើយយើងគិតឃើញថា អង្គជំនុំជម្រះនឹងសួរលោក អៀង សារី ទោះបីជាគាត់បានបោះបង់សិទ្ធិថាមិនឆ្លើយនោះក៏ដោយ។

នេះ ជាសិទ្ធិតាមរដ្ឋធម្មនុញ្ញ ថាគាត់មានសិទ្ធិមិនឆ្លើយតប។ ដូច្នេះ នៅពេលនេះ ខ្ញុំសូមអនុញ្ញាតឱ្យគាត់បានអាននូវសេចក្ដីថ្លែងការណ៍របស់គាត់នៅក្នុងតុលាការនេះ ដើម្បីកត់ត្រា ដើម្បីកុំឱ្យអាចនឹងមានសំណួរចោទសួរគាត់ ដែលថាប៉ះពាល់ទៅនឹងការបោះបង់សិទ្ធិថាគាត់នៅស្ងៀមមិនឆ្លើយតបនេះ។

សូមអរគុណ។

[១៣:៤៤:២៧]

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណ។ ប៉ុន្តែសំណួរនេះ មិនទាន់ត្រូវបានអង្គជំនុំជម្រះជម្រាបទេ ប៉ុន្តែលោកអាចមិនឆ្លើយនឹងសំណួរនេះក៏បាន សំណួរនេះតាមធម្មតា គឺយើងប្រើភាសាមួយ ថាតើកម្រិតសិក្សារបស់លោករៀនសូត្រហ្នឹង ដល់កម្រិតណាដែរ? នេះជាសំណួរទូទៅដែលពាក់ព័ន្ធជាមួយនឹងអត្តសញ្ញាណបុគ្គលមិនទាន់ទងជាមួយនឹងសំណួរដែលសារធាតុនោះទេ។

[១៣:៤៥:០០]

**លោក អៀង សារី៖**

សូមគោរពលោកប្រធាន ខ្ញុំឆ្លើយបានខ្លះអ៊ីចឹងប៉ុណ្ណឹង ក៏ប៉ុន្តែដល់កន្លែងឯទៀតឆ្លើយមិនបានទេ ខ្ញុំសូមអានសេចក្តីព្រាងទុករបស់ខ្ញុំ។

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណ។ ហើយមុននឹងអាន យើងបន្តនូវកិច្ចនីតិវិធីចំពោះមុខអង្គជំនុំជម្រះជាមុនសិន ដើម្បីឲ្យចប់នូវភារកិច្ចនៅក្នុងការអនុវត្តតាមវិធាននៃកិច្ចដំណើរការនីតិវិធី។

លោក អៀង សារី ក្នុងនាមលោកជាជនជាប់ចោទនៅចំពោះមុខអង្គជំនុំជម្រះនេះ ចាប់ពីពេលនេះតទៅ និងសវនាការជាបន្តបន្ទាប់ រហូតដល់កិច្ចពិភាក្សាដេញដោលក្នុងសំណុំរឿង០០២ បានចប់សព្វគ្រប់នោះ លោកមានសិទ្ធិដូចខាងក្រោម៖

សិទ្ធិមានមេធាវីការពារ តាមការជ្រើសរើសរបស់លោក ឬតាមការចាត់តាំងនៅក្នុងគ្រប់ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីរបស់តុលាការ។ សិទ្ធិ អំពីសិទ្ធិនេះអង្គជំនុំជម្រះកត់សម្គាល់ឃើញថា ចាប់តាំងពីដំណាក់ស៊ើបអង្កេតរហូតដល់ពេលនេះ លោកមានមេធាវីការពារក្តីចំនួនពីររូប គឺមានមេធាវីជាតិមួយរូប និងមេធាវីអន្តរជាតិមួយរូប។

[១៣:៤៦:៣៤]

នៅក្នុងគ្រប់ដំណាក់កាលនៃកិច្ចដំណើរការពិភាក្សាដេញដោលរបស់តុលាការ លោកមានសិទ្ធិនៅស្ងៀមមិនឆ្លើយតប។ លោកមានសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ លោកមានសិទ្ធិទទួលដំណឹងពីបទល្មើសដែលបានចោទប្រកាន់ចំពោះរូបលោក។

សំណួរសួរថា តើលោកបានទទួលដំណឹងអំពីបទល្មើសដែលបានចោទប្រកាន់ចំពោះរូបលោកហើយឬនៅ?

**លោក អៀង សារី៖**

បាទ, បានទទួលហើយ។

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណ។ ឥឡូវនេះ តើលោក អៀង សារី រក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតប ឬក៏ឆ្លើយតបនឹងសំណួរដែលអង្គជំនុំជម្រះ ឬក៏ភាគីនឹងសួរលោក?

**លោក អៀង សារី៖**

ខ្ញុំសូមអានសេចក្តីព័ត៌មានរបស់ខ្ញុំ។

លោកប្រធានជាទីគោរព សូមគោរពលោក លោកស្រីចៅក្រមទាំងអស់។ ខ្ញុំបាទសូមប្រើប្រាស់សិទ្ធិរបស់ខ្ញុំ ក្នុងរដ្ឋធម្មនុញ្ញ ដោយរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយនឹងសំណួរទាំងឡាយនាពេលនេះ។ សិទ្ធិនេះមានចែងក្នុងមាត្រា៣១ និង៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

ខ្ញុំបាទមានបំណងប្រើប្រាស់សិទ្ធិនេះនៅក្នុងការជំនុំជម្រះទាំងមូល ហើយមិនមានបំណងឆ្លើយតបនឹងសំណួរណាមួយឡើយ។ សូមអរគុណ។

[១៣:៤៨:៤០]

**ប្រធានអង្គជំនុំ៖**

បាទ,អរគុណលោក អៀង សារី ដែលបានបង្ហាញជំហរច្បាស់លាស់ដូច្នេះ។

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ,សូមអរគុណលោកប្រធាន។ ខ្ញុំសូមធ្វើការបំភ្លឺមួយដើម្បីរំឭក នៅដើមសវនាការគឺថាយើងបានអានផ្នែកពាក់ព័ន្ធនៃដីកាដំណោះស្រាយ ទាក់ទងទៅនឹងបរិបទប្រវត្តិសាស្ត្រ ហើយនិងទាក់ទងទៅនឹងកថាខណ្ឌមួយចំនួនដែលទាក់ទងទៅនឹងតួនាទីរបស់ជនជាប់ចោទ។ ហើយខ្ញុំចង់ដឹងថា តើលោក អៀង សារី មិនត្រឹមតែបដិសេធក្នុងការឆ្លើយទៅនឹងសំណួរទាំងអស់នោះទេ បើសិនជាគាត់ជំទាស់ផងដែរក្នុងការពន្យល់ណាមួយ ឬក៏ការអត្ថាធិប្បាយណាមួយទាក់ទងទៅនឹងនឹងកថាខណ្ឌដែលត្រូវបានអានពីដើមមុននោះ។

**លោក ម៉ៃខល កាណាវាស៖**

មុននឹងគាត់ឆ្លើយ ខ្ញុំនឹងសូមជម្រាបអង្គតុលាការដូចខាងក្រោមនេះ៖

ខ្ញុំបានឮថា ពាក្យថា "បដិសេធ" ខ្ញុំបានឮពាក្យនេះ។ ការប្រើសិទ្ធិរបស់គាត់តាមរដ្ឋធម្មនុញ្ញក្នុងការនៅស្ងៀមមិនឆ្លើយតប មិនអាចចាត់ទុកថាជាការបដិសេធនោះទេ ប៉ុន្តែយើងពិនិត្យមើលបញ្ហាសំខាន់គឺគាត់ប្រើនូវសិទ្ធិតាមរដ្ឋធម្មនុញ្ញរបស់គាត់ទាំងស្រុង គឺគាត់មិនឆ្លើយតបនឹងសំណួរណាមួយគ្រប់ដំណាក់កាលនីតិវិធីទាំងអស់ រួមទាំងចំណុចទាំងឡាយនៅក្នុងដីកាបញ្ជូនរឿងមកជំនុំជម្រះនោះផងដែរ។ ដូច្នេះ គាត់បានជូនជាលាយលក្ខណ៍អក្សររួចហើយ ឥឡូវនេះគាត់ទើបតែបានអានដោយផ្ទាល់មាត់។

ដូច្នេះហើយគាត់នឹងមិនសួរ មិនឆ្លើយនូវសំណួរណាមួយទេ ហើយការប្រើសិទ្ធិតាមរដ្ឋធម្មនុញ្ញទាំងស្រុងរបស់គាត់នេះ គឺមានលក្ខណៈច្បាស់បែបនេះ។ សូមអរគុណ។

[១៣:៥១:០៣]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ, គឺយើងនឹងជំទាស់ថាលោក អៀង សារី អាចបដិសេធក្នុងការឆ្លើយនឹងសំណួរនោះទេ គ្រាន់តែយើងត្រូវតែច្បាស់ថា សព្វថ្ងៃនេះក្នុងសវនាការនេះ គឺជាឱកាស ការផ្តល់ឱកាសមួយទៀតដល់ជនជាប់ចោទក្នុងការចេញបញ្ចេញប្រតិកម្ម ឬក៏ការធ្វើអត្ថាធិប្បាយទាក់ទងទៅនឹងអំនាននៃវគ្គមួយចំនួននៃដីកាដំណោះស្រាយ ហើយអ៊ីចឹងហើយយើងត្រូវយល់ច្បាស់ផងដែរថា បើគាត់មិនចង់ធ្វើការអត្ថា-ធិប្បាយទេ។ នេះជាសំណួររបស់ខ្ញុំ តើគាត់មិនចង់ ឬក៏យ៉ាងម៉េច? គាត់អាចឆ្លើយនឹងសំណួរនេះ។

**លោក អៀង សារី៖**

សូមគោរពលោកប្រធាន សូមគោរពលោកចៅក្រម។ ខ្ញុំមិនមានបំណងនឹងឆ្លើយនឹងសំណួរដូចខ្ញុំបានធ្វើសេចក្តីប្រកាសអម្បាញ់មិញ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះដោយជនជាប់ចោទ បានបង្ហាញជំហរច្បាស់លាស់ក្នុងការលះបង់សិទ្ធិឆ្លើយតបនឹងសំណួរទាំងឡាយដែលនឹងសួរដោយអង្គជំនុំជម្រះនិងភាគី។ ដូច្នេះ អនុរក្សមន្ទីរឃុំឃាំងឲ្យនាំខ្លួនជនជាប់ចោទ អៀង សារី ទៅកាន់កៅអីដែលរៀបចំសម្រាប់គាត់នៅពីក្រោយមេធាវីរបស់គាត់វិញចុះ។

[១៣:៥៣:១៧]

**លោក អាកទូរ វែកគែន៖**

បាទ ខ្ញុំឆ្លៀតឱកាសនៃការផ្អាកនេះ ព្រោះថាបន្តិចទៀតវាអាចដល់វេនលោក ខៀវ សំផន ហើយខ្ញុំចង់បំភ្លឺគោលជំហរបស់គាត់ដែលសំណួរដែលបានចោទអម្បាញ់មិញនេះ ខ្ញុំចង់ចង្អុលបង្ហាញថាទោះបីតែលើកលែងមានការប្រែប្រួល ប្តូរគំនិតរបស់គាត់ទេគឺថា គោលជំហររបស់លោក ខៀវ សំផន មានដូចតទៅនេះ៖ បើដូចចៅក្រមលើកឡើងអម្បាញ់មិញអ៊ីចឹងគឺថា គាត់ចង់បញ្ចេញប្រតិកម្ម ហើយនិងធ្វើការអត្ថាធិប្បាយទៅលើកថាខណ្ឌនៃដីកាដំណោះស្រាយ ដែលអង្គជំនុំជម្រះបានលើកឡើង ដែលជា-- ដែលស្ថិតនៅក្នុងក្រុមខណ្ឌនៃរឿងក្តីទីមួយនេះ។ ក៏ប៉ុន្តែផ្ទុយទៅវិញ គាត់ចង់ពាក់ព័ន្ធនឹងសំណួរដែលថាចោទសួរទៅគាត់នេះ គាត់ចង់ប្រើសិទ្ធិរក្សាភាពស្ងៀមស្ងាត់មិនឆ្លើយ ហើយចង់ឲ្យខាងសហព្រះរាជអាជ្ញាផ្តល់ភស្តុតាងទាក់ទងទៅនឹងប្រធានបទសវនាការក្នុងដំណាក់កាលនេះ។ អ៊ីចឹងគឺបានន័យថាគាត់នឹងឆ្លើយតបទៅនឹងសំណួរនៅពេលក្រោយ។ ហើយឥឡូវនេះ គាត់គ្រាន់តែឆ្លើយតបទៅនឹងកថាខណ្ឌនៅក្នុងដីកាដំណោះស្រាយតែប៉ុណ្ណោះនោះទេ។

[១៣:៥៤:៥៣]

**ប្រធានអង្គជំនុំ៖**

អនុរក្សមន្ទីរឃុំឃាំងនាំ ខៀវ សំផន មកកាន់ឈើរាងរង្វង់ក្រចកសេះនៅមុខអង្គជំនុំជម្រះនេះ។

[១៣:៥៥:០០]

*(លោក ខៀវ សំផន ធ្វើដំណើរទៅកាន់ឈើរាងរង់ក្រចកសេះ)*

**សួរដោយប្រធានអង្គជំនុំ៖**

សូមៗអញ្ជើញអង្គុយចុះសិនលោក ខៀវ សំផន អង្គុយចុះ!

ឥឡូវនេះអង្គជំនុំជម្រះសួបញ្ជាក់អំពីអត្តសញ្ញាណរបស់លោកដូចជាប់ចោទដទៃទៀតដែលយើងបានធ្វើ ហើយនិងប្រាប់សិទ្ធិ និងបទចោទជាមុនសិន មុននឹងពាក់ព័ន្ធដល់ការប្រើសិទ្ធិនៅស្ងៀមមិនឆ្លើយតប ឬក៏ធ្វើសក្ខីកម្មផ្សេងៗនោះ។

**ស៖** តើលោកឈ្មោះ ខៀវ សំផន អ៊ីចឹងពិតមែនដែរទេ?

[១៣:៥៦:៣០]

**លោក ខៀវ សំផន៖**

**ឆ៖** មានឈ្មោះ ខៀវ សំផន ជាផ្លូវការតាមសំបុត្រកំណើត។

**ស៖** ក្រៅពីឈ្មោះ ខៀវ សំផន ហ្នឹង តើលោកមានឈ្មោះហៅក្រៅផ្សេងអ្វីដែរឬទេ?

**ផ៖** បាទ, ខ្ញុំមានឈ្មោះហៅក្រៅមួយ ហៅថា ហែម ក្រៅពីនោះអត់មានឈ្មោះហៅក្រៅអីទៀតទេ។ ខ្ញុំគ្មាន-- សូមឆ្លៀតឱកាសនេះជម្រាបលោកប្រធាន និងលោក លោកស្រីចៅក្រមថា ខ្ញុំគ្មានឈ្មោះហៅក្រៅថា ខាង នោះទេ គឺ ឌុច ទេ ដែលនិយាយយ៉ាងនេះ។ ឯ ឌុច ខ្លួនឯងគាត់ក៏បានទទួលស្គាល់ហើយ ថាគាត់មិនដែលជួបខ្ញុំសោះក្នុងរយៈបីឆ្នាំនៃរបបកម្ពុជាប្រជាធិបតេយ្យនេះ។

ដូច្នេះខ្ញុំសូមបញ្ជាក់យ៉ាងនេះថា ខ្ញុំគ្មានឈ្មោះក្រៅហៅថា ខាង ទេ។ បាទ សូមអស់។

**ស៖** ចុះឈ្មោះ ណន ដែលមានហៅក្រៅឈ្មោះ ណន ទេ?

**ផ៖** ប៉ុន្តែឈ្មោះ ណន ហ្នឹង គឺតាំងពីខ្ញុំនៅនិរតី ដល់មកខ្ញុំនៅខាងស្ទឹងជីនិត អ្នកខ្លះក៏នៅចាំដែលធ្លាប់ស្គាល់ខ្ញុំនៅនិរតី ក៏នៅចាំ ហៅខ្ញុំ ណន។ បើមកស្ទឹងជីនិត ជាទូទៅគេស្គាល់ខ្ញុំតែ ហែម ទេ។ បាទ ហើយក្រោយៗមកក៏អ៊ីចឹងដែរ ក្រោយឆ្នាំ១៩៧០-៧៥ ហ្នឹង គឺគេស្គាល់ខ្ញុំឈ្មោះ ហែម ទទូទៅ ឯ ណន នុ៎ង អង្កាល់ខ្ញុំនៅនិរតី បាទ។

**ស៖** ចុះថ្ងៃខែឆ្នាំកំណើតរបស់លោក តើលោកកើតនៅថ្ងៃខែឆ្នាំណាដែរ?

[១៣:៥៨:៣២]

**ផ៖** នែ៎ ថ្ងៃ២៧ កក្កដា ឆ្នាំ១៩៣១។

**ស៖** ទីកន្លែងកំណើតរបស់លោកនៅកន្លែងណាដែរ?

**ផ៖** នៅស្វាយរៀង ស្រុករំដួល ឃុំចេក។

**ស៖** ឃុំចេក ឬក៏ឃុំរំចេក?

**ផ៖** បើតាមខ្ញុំចាំ គេថាឃុំចេក ប៉ុន្តែកន្លែងឈ្មោះជាផ្លូវការរបស់រដ្ឋ អាចរំចេកក៏មិនដឹង តែចាំខ្លួនឯងថា ឃុំចេកអ៊ីចឹង។

**ស៖** បាទ, អរគុណ។ ទីលំនៅមុនពេលចាប់ឃុំខ្លួនលោក តើលោករស់នៅទីកន្លែង?

**ផ៖** ខ្ញុំធ្លាប់ថា ឮគេហៅថា អូរតាវ៉ៅ ប៉ុន្តែមិនដឹងកន្លែងហ្នឹងមែន អីមិនមែនទេ នៅប៉ៃលិន បាទ។ ជួនណាឈ្មោះកន្លែងពិតប្រាកដរបស់គេផ្សេងក៏មិន ប៉ុន្តែខ្លួនខ្ញុំចាំថា អូរតាវ៉ៅ។

**ស៖** បាទ, អរគុណ។ ចុះឪពុកបង្កើតរបស់លោកឈ្មោះអ្វីដែរ?

**ផ៖** ខៀវ ឡុង។

**ស៖** ចុះម្តាយបង្កើតរបស់លោកឈ្មោះអី?

**ឆ៖** (មិនឮសំឡេង)។

**ស៖** លោកឆ្លើយម្តងទៀត ម្តាយរបស់លោកឈ្មោះអ? ចាំៗមើលភ្លើងសិន ភ្លើងមិក្រូក្រហមចាំឆ្លើយ បាទ។

**ឆ៖** បាទ ឈ្មោះ ប៉ោ គង់។

[១៤:០០:០០]

**ស៖** អ៊ីចឹង ប៉ោ គង់ មិនមែន លី គង់ ទេ? អង្គាល់ពីនៅក្នុង-- នៅដំណាក់កាលស៊ើបអង្កេតគេចៅក្រមស៊ើបអង្កេតបានរកឃើញថា ឈ្មោះ លី គង់ តើ លី និង ប៉ោ ហ្នឹងខុសគ្នាយ៉ាងម៉េចទៅត្រកូលហ្នឹង? ឈប់លោក ខៀវ សំផន ចាំៗមើលភ្លើងសិន ភ្លើងក្រហម។

**ឆ៖** បាទ, ប្រហែល លី ដែរមើលទៅ ពីព្រោះមាខ្ញុំគេហៅ លី វ៉ាៗ ដូច្នេះម្តាយខ្ញុំអាច លី ដែរមើលទៅ។ ប៉ុន្តែខ្លួនឯងចាំថា ប៉ោ។

[១៤:០០:៥៩]

**ស៖** លោកមានប្រពន្ធទេ ហើយប្រពន្ធរបស់លោកឈ្មោះអី?

**ឆ៖** ប្រពន្ធខ្ញុំនែ៎ ឈ្មោះ សូ សុជាតិ។

**ស៖** តើលោកមានកូនប៉ុន្មាននាក់? ប្រុសប៉ុន្មាន? ស្រីប៉ុន្មាន?

**ឆ៖** កូនបួននាក់។ កូនបងបង្អស់ប្រុស បន្ទាប់មកកូនស្រី បន្ទាប់មកនែ៎កូនស្រីទៀត បន្ទាប់មកកូនប្រុសពៅ។ ដូច្នេះរួមទាំងអស់បួននាក់។

**ស៖** បាទ, អរគុណ។ តើលោកមានបងប្អូនបង្កើតប៉ុន្មាននាក់? ប្រុសប៉ុន្មាន? ស្រីប៉ុន្មាន? ហើយលោកជាកូនទីប៉ុន្មានដែរ?

**ឆ៖** មែនទែនទៅ ខ្ញុំម្តាយខ្ញុំមានកូនដល់១២ ប៉ុន្តែស្លាប់អស់ វាទៅជាខ្ញុំទៅជាបងគេទៅវិញ ហើយសព្វថ្ងៃនេះនៅសល់បងប្អូនបង្កើតហ្នឹងបួននាក់។ ខ្ញុំ ហើយប្អូនបន្ទាប់នោះស្រី ហើយបន្តបន្ទាប់ទៅទៀតប្រុសទាំងពីរ។

[១៤:០២:១៨]

**ស៖** អ៊ីចឹងបានន័យថាមានបងប្អូនបួននាក់ ប្រុសបី ស្រីមួយ ហើយលោកក្លាយទៅជាកូនប្រុសច្បងគេបង្អស់។ លោក ខៀវ សំផន តើអាចរៀបរាប់ដោយសង្ខេបអំពីប្រវត្តិសិក្សារបស់លោកជូនដល់អង្គសវនាការស្តាប់បានដែរឬទេ?

**ឆ៖** បាទ, ដូចមេធាវីខ្ញុំបានជម្រាបអម្បាញ់មិញ។ ខ្ញុំមានសំណូមពរជម្រាប។

**ស៖** ឥឡូវនេះលោកអាចឆ្លើយនឹងសំណួរយើងអំមិញ ពីព្រោះយើងសួរថាបានដែរឬទេ? បើមិនបានទេ យើងនឹងបន្តតាមលំដាប់នៃកិច្ចសំណួរដែលយើងនឹងបន្តទៀត។

សំណួរយើងចុងក្រោយអំមិញថា តើលោកអាចរៀបរាប់ប្រាប់អង្គសវនាការអំពីប្រវត្តិសិក្សារបស់លោកជូនដល់អង្គសវនាការបានដែរឬទេ?

[១៤:០៣:៤៧]

**ឆ៖** បាទ, សូមជម្រាបលោកប្រធានថា បានទាន។

**ស៖** បើបានសូមអញ្ជើញបាទ!

**ឆ៖** បាទ, ខ្ញុំរៀនបឋមសិក្សានៅកំពង់ចាម ហើយរួចមកចូលរៀននូវអនុវិទ្យាល័យព្រះសីហនុនៅកំពង់ចាម។ រួចមកខ្ញុំមករៀននៅភ្នំពេញក្រោយពីបានជាប់សញ្ញាបត្រឌីប្លូម ខ្ញុំរៀននៅភ្នំពេញ នៅសាលាលីសេស៊ីសុវត្ថិ រហូតដល់ជាប់បានសញ្ញាបត្រទុតិយភូមិនៅឆ្នាំ១៩៥១ ប៉ុន្តែខ្ញុំត្រូវការធ្វើការចិញ្ចឹមម្តាយនិងប្អូនៗខ្ញុំពីរឆ្នាំសិនបានខ្ញុំទៅស្រុកបារាំងខាងក្រោយទៀត។ ប៉ុន្តែនៅចន្លោះពេលនោះ ខ្ញុំរៀនច្បាប់នៅភ្នំពេញបាទ។ ហើយដល់ឆ្នាំ៥៣ បានខ្ញុំទៅស្រុកបារាំង។ ដល់ចុងឆ្នាំ៥៨ បានខ្ញុំចប់ ខ្ញុំត្រឡប់មកស្រុកវិញ។ បាទ មានប៉ុណ្ណឹងបាទ។

**ស៖** បាទ, អរគុណ។ តើលោកទៅរៀននៅស្រុកបារាំងហ្នឹង រៀនមុខវិជ្ជាអីដែរ? ជំនាញអីដែរនៅឯស្រុកបារាំងពី៥៣ដល់៥៨?

**ឆ៖** នៅស្រុកបារាំងហ្នឹង ខ្ញុំទៅរៀនបន្តរៀនច្បាប់ៗ ប៉ុន្តែទៅរៀនម៉ុងប៉ូលីយេឯនោះទេ។ បីឆ្នាំក្រោយមកបានមកប៉ារីស។ បាទលោកប្រធានន៎ ខ្ញុំ-- រឿងហ្នឹងវាជាប់ ខ្ញុំចង់ជម្រាបល្អិតទៅតាមន័កថាខណ្ឌ ដែលលោកប្រធានបានអានកាលពីថ្ងៃ៥ ធ្នូ។

[១៤:០៦:០៤]

**ប្រធានអង្គជំនុំ៖**

អរគុណ អង្គជម្រះនឹងអនុញ្ញាតឲ្យលោកអាននូវសេចក្តីថ្លែងការណ៍របស់លោក។

លោក ខៀវ សំផន ក្នុងនាមលោកជាជនជាប់ចោទនៅចំពោះមុខអង្គជម្រះ ចាប់ពីពេលនេះតទៅនិងសវនាការជាបន្តបន្ទាប់រហូតដល់ចប់កិច្ចដំណើរការសវនាការ ពិភាក្សាដេញដោលលើសំណុំរឿង ០០២នេះ។ លោកមានសិទ្ធិដូចខាងក្រោម៖

សិទ្ធិមានមេធាវីការពារតាមការជ្រើសរើសរបស់លោក ឬតាមការចាត់តាំងនៅក្នុងគ្រប់ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីរបស់តុលាការ។ សិទ្ធិនេះអង្គជម្រះកត់សម្គាល់ឃើញថា ចាប់តាំងពីដំណាក់កាលស៊ើបអង្កេតរហូតមកដល់ពេលនេះ គឺនៅដំណាក់កាលស៊ើបអង្កេតលោកមានមេធាវីចំនួនបីរូប គឺមេធាវីជាតិមួយរូប និងមេធាវីអន្តរជាតិចំនួនពីររូប ហើយនៅដំណាក់កាលជំនុំជម្រះនេះគឺលោកបានមានមេធាវីបន្ថែមម្នាក់ទៀតគឺ មេធាវីអន្តរជាតិ។ ដូច្នេះ គឺមេធាវីរបស់លោកគឺមេធាវីជាតិមួយរូប និងមេធាវីអន្តរជាតិចំនួនបីរូប។

[១៤:០៧:១១]

នៅក្នុងគ្រប់ដំណាក់កាលនៃកិច្ចដំណើរការពិភាក្សាដេញដោលរបស់តុលាការ លោកមានសិទ្ធិនៅស្ងៀមមិនឆ្លើយតប។ លោកមានសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ លោកមានសិទ្ធិទទួលដំណឹងអំពីបទចោទប្រកាន់ប្រឆាំងនឹងរូបលោក។ លោក ខៀវ សំផន តើលោកបានទទួលដំណឹងអំពីបទចោទប្រកាន់ចំពោះរូបលោកហើយឬនៅ?

**លោក ខៀវ សំផន៖**

បាទ, បានទទួលហើយ។

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណ ហើយតើឥឡូវនេះលោកប្រើរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតប ឬក៏លោករក្សាសិទ្ធិនៅក្នុងការឆ្លើយតបនឹងសំណួរ ដែលសួរដោយអង្គជំនុំជម្រះ និងភាគីនានានៅក្នុងកិច្ចដំណើរការសវនាការសម្រាប់ពេលនេះ ក៏ដូចជាសម្រាប់ពេលដំណើរការនៅថ្ងៃខាងមុខដែរ?

[១៤:០៨:១៤]

**លោក ខៀវ សំផន៖**

មានសំណូមពរចង់ធ្វើអត្ថាធិប្បាយ លើកថាខណ្ឌនៃដីកាដំណោះស្រាយ ដែលត្រូវបានអានកាលពីថ្ងៃចន្ទ ទី៥ ធ្នូ។ ប៉ុន្តែខ្ញុំមិនភ្លេចទេ ថានេះជាសវនាការកាត់ទោសខ្ញុំ។ លោកសហព្រះរាជអាជ្ញា លោកមានទស្សនៈរបស់លោកលើកថាខណ្ឌទាំងនេះ និងបរិបទជាប្រវត្តិសាស្ត្រនៅពេលនោះ។ ខ្ញុំមិនយល់ស្របជាមួយទស្សនៈគាត់ទេ។ គាត់ទេដែលត្រូវផ្តល់ភស្តុតាងអំពីអ្វីដែលគាត់បានអះអាង។ ដូច្នេះហើយបានជាខ្ញុំមានសំណូមពរ បើសិនជាអនុញ្ញាត បើសិនជាអស់លោកចៅក្រមអនុញ្ញាត ចង់ជម្រាបអំពីទស្សនៈរបស់ខ្ញុំលើព្រឹត្តិការណ៍ក្នុងបរិបទប្រវត្តិសាស្ត្រពេលនោះ ហើយខ្ញុំនឹងឆ្លើយសំណួរតែនៅពេល

ណាដែលខ្ញុំបានពិនិត្យភស្តុតាង ដែលលោកសហព្រះរាជអាជ្ញាបានបង្ហាញ ដើម្បីគាំទ្រទស្សនៈរបស់គាត់លើអ្វីដែលខ្ញុំបាននិយាយនៅក្នុងពេលនេះ។ តើលោកប្រធាន និងអស់លោកចៅក្រមអនុញ្ញាត ឬមិនអនុញ្ញាត?

[១៤:១០:១៦]

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ លោកបានបង្ហាញឲ្យបានច្បាស់លាស់ ពីព្រោះសំណួរនឹងសួរ អាចសួរលោកដេញដោលលោកដោយចៅក្រម ដោយអង្គជំនុំជម្រះ នេះជាសំណួរដែលអាចមានសិទ្ធិនៅក្នុងការសួរដេញដោលចំពោះរូបលោកនៅគ្រប់អង្គហេតុដែលបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ ហើយបន្ទាប់មក គឺភាគីផ្សេងទៀតនៅក្នុងនោះមានទាំងសហព្រះរាជអាជ្ញា មានទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មានទាំងមេធាវីការពារក្តីជនជាប់ចោទ និងជនជាប់ចោទក្រុមផ្សេងទៀត ហើយនិងមេធាវីរបស់លោកខ្លួនឯង នៅក្នុងការសួរទៅតាមមុខងារ តួនាទី ភារកិច្ចក្នុងការចូលរួមនៅក្នុងកិច្ចដំណើរការសវនាការរបស់តុលាការ។

ហើយការបង្ហាញរបស់លោក គឺអង្គជំនុំជម្រះមិនទាន់ច្បាស់លាស់ ថាតើលោករក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតប ហើយរង់ចាំឆ្លើយតបនៅពេលណាដែលសហព្រះរាជអាជ្ញាបង្ហាញភ័ស្តុតាងដាក់បន្ទុកលើរូបលោក ឬមួយក៏យ៉ាងដូចម្តេច? ឬមួយក៏លោកថារក្សាសិទ្ធិមិនឆ្លើយតបទាំងអស់? ទោះបីតែអង្គជំនុំជម្រះក៏ដោយ ហើយភាគីដទៃទៀតក៏ដោយ ក៏លោករក្សាសិទ្ធិមិនឆ្លើយតបទាំងអស់ដែរ។ តែអាចឆ្លើយតបនៅក្នុងករណីដែលមានការបង្ហាញភស្តុតាងដោយសហព្រះរាជអាជ្ញា ដែលមាន ដែលជាអ្នកមានបន្ទុកក្នុងការបង្ហាញភ័ស្តុតាងដាក់បន្ទុកចំពោះរូបលោក។ ទាំងភ័ស្តុតាងជាឯកសារ ទាំងភ័ស្តុតាងជាសាក្សី។

[១៤:១២:១៥]

នេះសូមឲ្យលោកបញ្ជាក់ឲ្យបានច្បាស់លាស់ ដើម្បីយើងធ្វើការកត់ត្រាចូលទៅប្រតិចារឹក។ ចៀសវាងមានការភាពដោះស្រាយមិនច្បាស់លាស់ វានាំឲ្យមានការមន្ទិល និងកើតឡើងនូវស្ថានភាពបែបនេះជាច្រើនលើកច្រើនសា ពីព្រោះសវនាការនេះ គឺរឿងក្តីធំ ដែលត្រូវធ្វើរយៈពេលយូរនៅក្នុងកិច្ចពិភាក្សាដេញដោល។

**លោក ខៀវ សំផន៖**

លោកប្រធាន លោកស្រីចៅក្រមជាទីគោរព! ខ្ញុំបាទមានសំណូមពរចង់ធ្វើអត្ថាធិប្បាយជម្រាបលើកថាខណ្ឌនៃដីកាដំណោះស្រាយទាំងអស់ដែលលោកប្រធានបានអានកាលពីថ្ងៃចន្ទ ថ្ងៃ០៥ ធ្នូ ប៉ុន្តែខ្ញុំសូមថាមិនទាន់ឆ្លើយនឹងសំណួរនៅពេលនេះទេ។ នូវសំណួរអ្វីៗពីសំណាក់ខាងណាក៏ដោយ ក៏មិនទាន់ឆ្លើយទេ ពីព្រោះខ្ញុំរង់ចាំដល់លោកព្រះរាជអាជ្ញាផ្តល់នូវភ័ស្តុតាង ដល់អ្វីលោកគាំទ្រសិន ពីព្រោះទស្សនៈរបស់លោក វាខុសពីទស្សនៈរបស់ខ្ញុំ។ ខ្ញុំមិនយល់ស្របទស្សនៈរបស់លោកទេ។

[១៤:១៣:៤៥]

អ៊ីចឹងខ្ញុំមែនថា នែ៎ខ្ញុំមានសំណូមពរតែប៉ុណ្ណឹង គឺថាប៉ុណ្ណឹង ចង់អានក្រដាសដែលខ្ញុំសរសេរនេះដើម្បីអត្ថាធិប្បាយលើកថាខណ្ឌទាំងអស់ដែលលោកប្រធានបានអានកាលពីថ្ងៃចន្ទ ០៥ ធ្នូ នោះ។ ប៉ុន្តែនៅពេលចំពោះមុខនេះ មិនទាន់ឆ្លើយនឹងសំណួរផ្សេងៗនៅឡើយទេ ដោយសំអាងថាសំខាន់គឺព្រះរាជអាជ្ញាទេ ដែលត្រូវផ្តល់ភ័ស្តុតាង មិនមែនខ្ញុំទេ ដែលខ្ញុំត្រូវដោះសារ ផ្តល់ភស្តុតាងដោះសារខ្លួនខ្ញុំ។

ដូច្នេះបានជាខ្ញុំមិនទាន់ឆ្លើយឥឡូវ។ ព្រោះឆ្លើយឥឡូវនេះ ទោះបីឆ្លើយជាសំណួរណាក៏ដោយ ក៏វាអាចពាក់ព័ន្ធទៅដល់នឹងលោកសហចៅក្រមដែរ។

ដូច្នេះ ខ្ញុំរង់ចាំលោកសហព្រះរាជអាជ្ញាដែរ។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតរង់ចាំស្តាប់លោកសហព្រះរាជអាជ្ញាសិន បានខ្ញុំនឹងឆ្លើយក្រោយ បាទ។

បាទ, ប៉ុណ្ណឹងច្បាស់ទេ ហើយលោកប្រធានអនុញ្ញាតទេទាន?

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:១៦:០៨]

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ លោកមិនរក្សាសិទ្ធិក្នុងការមិនទាន់ឆ្លើយតបនោះទេ។ ប៉ុន្តែលោកស្នើសុំធ្វើការ សង្កេត ឬក៏ថ្លែងការណ៍ទៅលើខ្លឹមសារនៃបណ្តាកថាខណ្ឌដែលក្រឡាបញ្ជីរបស់អង្គជំនុំជម្រះបានអាន កាលពីថ្ងៃចន្ទ ខែធ្នូ កាលពីសប្តាហ៍មុនកន្លងមកហើយនេះ។ អ៊ីចឹង ពិតមែនដែរឬទេ លោក ខៀវ សំផន?

**លោក ខៀវ សំផន៖**

បាទ។

**ប្រធានអង្គជំនុំ៖**

បើដូច្នោះមែន អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

[១៤:១៦:៤៨]

**លោក ខៀវ សំផន៖**

សូមអរគុណលោកប្រធាន បាទ។

សូមគោរពអស់លោក លោកចៅក្រម។ សូមគោរពអស់លោក លោកស្រីទាំងអស់ ដែលមានមុខនៅទីនេះ។ ព្រះសង្ឃគ្រប់ព្រះអង្គជាទីសក្ការៈ។ បងប្អូនរួមជាតិជាទីស្នេហា។

ជាដំបូង ខ្ញុំសូមបញ្ជាក់ជាថ្មីឡើងវិញ ថាខ្ញុំមិនមានឈ្មោះហៅថា ឈ្មោះក្រៅហៅថា ខាង ដូចបានឡើងក្នុងកថាខណ្ឌ១១២៦ និង១៥៩៨ នៃដីកាដំណោះស្រាយទេ។ សហចៅក្រមស៊ើបអង្កេតសំអាងទៅលើសម្តីរបស់ ឌុច។ បើទោះជា ឌុច បានទទួលស្គាល់រួចហើយ ថាមិនដែលបានជួបខ្ញុំសោះ ក្នុងអំឡុងពេលនៃរបបបីឆ្នាំនេះឡើយ។ បាទ សូមអនុញ្ញាតបញ្ជាក់ថែមជាថ្មីប៉ុណ្ណឹងហើយ ដើម្បីឲ្យច្បាស់លាស់ ខ្ញុំបាទនឹងចូលទៅអត្ថាធិប្បាយអំពីកថាខណ្ឌដែលលោកក្រឡាបញ្ជីបានអានកាលពីថ្ងៃចន្ទ ៥ ធ្នូ។

[១៤:១៨:៤៤]

មួយ អំពីសកម្មភាពរបស់ខ្ញុំ។ ពេលខ្ញុំរៀន ឯស្រុកបារាំង កថាខណ្ឌ១១២៦ និង១១៥៩ នៃដីកាដំណោះស្រាយ។ ខ្ញុំបាទបានជាប់សញ្ញាបត្រទុតិយភូមិនៅឆ្នាំ១៩៥១។ ប៉ុន្តែ ខ្ញុំត្រូវធ្វើការដើម្បីសន្សំទុនទុកជូនម្តាយខ្ញុំ ដើម្បីគាត់ចិញ្ចឹមជីវិតខ្លួនគាត់និងប្អូនៗខ្ញុំសិន។ ដោយខ្ញុំធ្វើជាសាស្ត្រាចារ្យនៅអនុវិទ្យាល័យបច្ចេកទេស និងទន្ទឹមនឹងនេះ ខ្ញុំក៏រៀនច្បាប់នៅភ្នំពេញ។ ដូច្នេះ ដល់ឆ្នាំ១៩៥៣ ទើបខ្ញុំទៅដល់បារីស។ ខ្ញុំមិនបានជួប សាឡុត ស ដែលថ្ងៃក្រោយនឹងទៅជា ប៉ុល ពត នោះទេ។ ពីព្រោះគាត់ត្រឡប់មកក្នុងប្រទេសវិញហើយ ខ្ញុំជួបតែលោក អៀង សារី។

ខ្ញុំទៅប៉ារីសបានពីរ ឬបីខែ ក៏មានមិត្តភក្តិខ្ញុំមួយនាក់ស្គាល់គ្នាកាលនៅវិទ្យាល័យស៊ីសុវត្ថិ ឈ្មោះ ឱក សុគន្ធ បានមកនិយាយស្នើខ្ញុំឲ្យចូលរួមក្នុងរង់ម៉ាក្សស៊ីស។ ខ្ញុំក៏បានឆ្លើយតបគាត់វិញថា ខ្ញុំចង់បានឯករាជ្យជាតិ តែខ្ញុំមិនយល់អ្វីពីកុម្មុយនីស្ត ពីម៉ាក្សស៊ីសអីទេ។ គាត់ក៏និយាយមកខ្ញុំវិញថា ហ្នឹងហើយ បានជារង់ម៉ាក្សស៊ីស មានទិសដៅឲ្យយើងបានយល់ដឹងបានទូលាយ ដើម្បីយើងអាចរកផ្លូវឈានឲ្យបានទៅដល់ឯករាជ្យ ដោយគាត់និយាយហើយនិយាយទៀត។ ខ្ញុំក៏មិនចង់ឲ្យគាត់មើលមកខ្ញុំថា ជាមនុស្សកំសាកញី ខ្ញុំក៏យល់ព្រមទទួល។ ប៉ុន្តែ ខ្ញុំក៏បានឃើញបរិយាកាសនៅប៉ារីស មានលក្ខណៈនយោបាយ

ខ្លាំង។ ដូច្នេះ ខ្ញុំត្រូវការដកឃ្លាឆ្ងាយបន្តិច ដើម្បីខ្ញុំមានពេលពិនិត្យ សង្កេត ហើយត្រិះរិះពិចារណា។

ខ្ញុំក៏សម្រេចទៅម៉ុងប៉ូលីយេ នៅខាងត្បូងស្រុកបារាំង ដោយសំអាងលេសថា នៅខាងត្បូងស្រុកបារាំងធាតុអាកាសសមស្របដល់ខ្ញុំជាងគេ។

[១៤:២២:៣៩]

នៅទីនោះ ខ្ញុំបន្តរៀនច្បាប់ ហើយក៏ចុះឈ្មោះរៀនសាលាពាណិជ្ជកម្ម។ នៅពេលវិស្សមកាលរដូវក្តៅ ខ្ញុំក៏ឡើងមកប៉ារីស ចូលរួមបានមួយលើកក្នុងរង់ម៉ាក្សស៊ីស ហើយក៏ចេញទៅជាមួយនឹងសិស្សទាំងអស់ អ្នកសមាជិករង់ ទាំងអ្នកដែលមិនសមាជិកទៅបោះជំរំរង់ ដែលរង់រៀបចំនៅឆ្នេរសមុទ្រ។ តាមវិធីនេះ ខ្ញុំអាចនៅឆ្ងាយពីរង់ ហើយក៏ចូលរួមដើម្បីយល់ថា តើគេធ្វើអីខ្លះនៅក្នុងរង់នេះ។ ដល់បីឆ្នាំក្រោយមក ទើបខ្ញុំឡើងមកនៅប៉ារីស ដើម្បីរៀនចំនិក្ខេបទរបស់ខ្ញុំខាងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

ពេលនោះ ខ្ញុំក៏ត្រូវតែចូលរួមប្រជុំជាទៀងទាត់នៅក្នុងរង់ម៉ាក្សស៊ីស។ ប៉ុន្តែបរិបទប្រវត្តិសាស្ត្របានប្រែប្រួលថ្មីស្រឡះហើយ កិច្ចព្រមព្រៀងហ្សឺណែវបានទទួលស្គាល់ឯករាជ្យកម្ពុជាហើយ។ ដូច្នេះមិនដូចជំនាន់ សាឡុត ស, យុន សឿន, រ័ត្ន សាមឿន អីទៀតទេ។ ពេលនោះគេនាំគ្នាត្រៀមខ្លួនចូលរួមតស៊ូ ប្រឆាំងអាណានិគមនិយមបារាំង ពេលនោះ គឺគេសង្កត់លើស្មារតីស្នេហាជាតិ ដែលត្រូវរួមចំណែក-- ពេលនេះពេលដែលខ្ញុំមកចូលរួមកាលដែលខ្ញុំមកប៉ារីសនេះ គឺគេសង្កត់លើស្មារតីស្នេហាជាតិដែលត្រូវរួមចំណែកពង្រឹងពង្រីក និងការពារឯករាជ្យជាតិ។ ប៉ុន្តែ រង់នៅតែបន្តជំរុញឲ្យសមាជិកចូលបក្សកុម្មុយនីស្តបារាំង។

[១៤:២៥:២៧]

មុននឹងគាត់ចេញដំណើរត្រឡប់ទៅប្រទេសវិញ អៀង សារី ក៏បានប្រគល់ភារកិច្ចគ្រប់គ្រង រង់មកឲ្យខ្ញុំ។ តាមមើលទៅគាត់អស់ជម្រើសហើយ។ អ្នកដែលជឿជាក់ ហើយសកម្មៗដូចជា ឱក សុគន្ធ, សុន សេន ជាដើម បានត្រឡប់ទៅប្រទេសវិញអស់ហើយ។ សមាជិកជើងចាស់ដែលនៅសល់ គឺ អ៊ិន សូកាន ក៏ត្រូវបញ្ចប់វិជ្ជាពេទ្យរបស់គាត់នៅទីក្រុងរ៉ាស។ ម្យ៉ាងទៀតគាត់ចូលចិត្តសប្បាយ គាត់ជាអ្នកមានមិត្តភក្តិនារីច្រើន ហើយចូលចិត្តរាំបារាំងណាស់។

ដូច្នេះ មានតែខ្ញុំ ហើយខ្ញុំក៏សុខចិត្តទទួល ដោយខ្ញុំឃើញថា ខ្ញុំក៏អាចធ្វើការមានប្រយោជន៍បាននៅក្នុងរង់នេះ គឺបំផុសស្មារតីស្នេហាជាតិដល់សមាជិកជានិស្សិត។ នៅពេលនោះ ខ្ញុំយល់ថាសម្តេចសីហនុ ដោយនយោបាយអព្យាក្រឹតរបស់លោក លោកប៊ានបដិសេធសេចក្តីប្រកាសដែលឯកតោភាគី

របស់អង្គការសេអាតូ អង្គការនៃសន្ធិសញ្ញាប្រទេសអាស៊ីអាគ្នេយ៍ បញ្ចូលកម្ពុជាទៅក្រោមម្លប់ឆ័ត្រការពាររបស់ខ្លួន ដោយលោកបានយកគំនិតផ្តើម ដោយអង់អាចក្លាហានខាងផ្លូវទូតទាក់ទងជាមួយប្រទេសខាងប្លុកសង្គមនិយម។

ដូច្នេះ ខ្ញុំគិតថា លោកអាចយកគំនិតផ្តើមកែទម្រង់សេដ្ឋកិច្ចនិងសង្គមដើម្បីបោះមូលដ្ឋានមួយសម្រាប់សេដ្ឋកិច្ចឯករាជ្យមួយរបស់ប្រទេសយើងដូចធ្លាប់បានធ្វើរួចមកហើយនៅប្រទេសជប៉ុន។ ប៉ុន្តែគ្រាន់តែមានខ្នាតតូចជាង។ ដូច្នេះហើយបានជាខ្ញុំជ្រើសរើសយកប្រធាននិក្ខេបទរបស់ខ្ញុំ គឺបញ្ហានៃឧស្សាហូបនីយកម្មកម្ពុជា។

[១៤:២៨:៣៩]

ខ្ញុំមានជំនឿជឿថាឲ្យតែមានវិធានការឲ្យបានសមស្រប នាយទុនជាតិមួយនឹងអាចរីកលូតលាស់បាន។ សំណួរសំខាន់នៅក្នុងនិក្ខេបទនោះ គឺថាតើហេតុអ្វីបានជារចនាសម្ព័ន្ធសេដ្ឋកិច្ចពេលនោះមិនអាចឲ្យមានការអភិវឌ្ឍប្រទេសកម្ពុជា? ចម្លើយគឺថា ទំនិញឧស្សាហកម្មរបស់បារាំងបានមកប្រកួតប្រជែងជាមួយនឹងសិប្បកម្មខ្មែរ។ ដូច្នេះ ធ្វើឲ្យសិប្បកម្មខ្មែរត្រូវរួញក្ដោបងើបមិនរួច នេះហើយដែលនាំឲ្យសេដ្ឋកិច្ចកម្ពុជាទៅជាសេដ្ឋកិច្ចកសិកម្មអន់ថយទៅវិញ។

ខ្ញុំគិតថា រដ្ឋត្រូវតែកាន់កាប់ពាណិជ្ជកម្មក្រៅប្រទេស ជាឧបករណ៍សម្រាប់ជួយដល់ការរីកលូតលាស់នៃសិប្បកម្ម ហើយតម្រង់ការងារទៅខាងផលិតកម្ម តម្រង់កម្លាំងការងារទៅខាងពាណិជ្ជកម្ម។ លើចំណុចនេះ ខ្ញុំផ្អែកលើទ្រឹស្តីអ្នកសេដ្ឋសាស្ត្រជាតិអេសកូស ឈ្មោះ អាដាំ ស្មីស។ ក្នុងនិក្ខេបបទរបស់ខ្ញុំៗមិនបានថាឲ្យត្រូវលុបបំបាត់ប្រើលុយនោះទេ ហើយក៏មិនបានស្នើឲ្យបំបាត់កម្មសិទ្ធិឯកជនទេ ហើយក៏មិនបាននិយាយពីការបំបាត់ទីក្រុងដែរ។

ទម្រង់សេដ្ឋកិច្ចដែលខ្ញុំបានស្នើ គឺប្រហាក់ប្រហែលនឹងរយៈកាលបដិវត្តន៍ឧស្សាហកម្មនៅអឺរ៉ុបគ្រាន់តែក្នុងបរិបទប្រវត្តិសាស្ត្រខុសគ្នាតែប៉ុណ្ណោះ។ ខ្ញុំក៏សូមជម្រាបបន្ថែមផងដែរថា ខ្ញុំបានចូលរួមបក្សកុម្មុយនីស្តបារាំងនៅឆ្នាំ១៩៥៥ មូលហេតុគឺមកពីបក្សនេះប្រឆាំងនឹងអាណានិគម គាំទ្រការតស៊ូរបស់ប្រជាជនដែលនៅក្រោមការជិះជាន់ដើម្បីឯករាជ្យជាតិ និងអធិបតេយ្យជាតិរបស់គេ ហើយបំផុសឲ្យប្រជាជននៅក្នុងសកលលោករួបរួមសាមគ្គីគ្នា។

[១៤:៣២:០៣]

បក្សនេះបានប្រមូលកម្លាំងរៀបចំបាតុកម្មប្រឆាំងសង្គ្រាមវៀតណាម ហើយកំពុងរៀបចំបាតុកម្ម

ជាបន្តបន្ទាប់ទៀត ប្រឆាំងនឹងសង្គ្រាមនៅអាល់ហ្សេរី ។ល។ ខ្ញុំក៏បានចូលរួមជាបន្តបន្ទាប់ដែរជាមួយនឹងបាតុកម្មទាំងអស់នោះ។ ខ្ញុំគិតថាការតស៊ូរបស់ប្រជាជនដែលនៅក្រោមនឹមអាណានិគមនិយម និងធ្វើឲ្យអាណានិគមនិយមចុះខ្សោយ ហើយបានជួយជំរុញឲ្យកម្ពុជាប្រទេសខ្ញុំ បានឯករាជ្យបានឆាប់រហ័ស។ ហើយតាមការពិតទៅវាអ៊ីចឹងមែន។ ខ្ញុំយល់ឃើញថា ភោជ ព្រះរាជព្រះភោជនីយកិច្ចរបស់សម្តេច សីហនុ ដែលសម្រេចបាននោះគឺដោយសារការតស៊ូរបស់ប្រជាជននៅក្នុងសកលលោក ប៉ុន្តែពិសេសការតស៊ូរបស់ប្រជាជនវៀតណាម។ ពិសេសនៅពេលចំរយៈពេលដែលកងកម្លាំងប្រដាប់អាវុធវៀតណាមរំដោះ ហ៊ុមព័ទ្ធ ឌៀន-បៀន-ហ្វ៊ូ។

[១៤:៣៣:៣៨]

ក្រៅពីនេះ សូមជម្រាបថាសាខារបស់ខ្ញុំជាសាខានិស្សិត ដែលផ្ទុយពីសាខារបស់ ប៉ុល ពត, អៀង សារី, វ័ត្ត សាមឿន ។ល។ ដែលជាសាខាកម្មករ។ សាខាខ្ញុំប្រជុំនៅមជ្ឈមណ្ឌលសាកលវិទ្យាល័យនៅតាមមហាវិថីហ្សក់ដង់ សង្កាត់១៤ នៃទីក្រុងប៉ារីស។ ប្រជុំនៅផ្ទះនិស្សិតអន្តរជាតិ។ ប៉ុន្តែបានតែមួយឆ្នាំ ខ្ញុំក៏ឈប់យកប័ណ្ណបក្សរបស់ខ្ញុំទៅដូរយកប័ណ្ណថ្មី ដោយគេប្រជុំពិភាក្សាតែបញ្ហារបស់បារាំងមិនសូវបានប្រយោជន៍អ្វីដល់ខ្ញុំទេ។

ដូច្នេះ ខ្ញុំគ្មានចំណងជាអាថ៌កំបាំងអ្វីលាក់លៀមនៅពេលដែលខ្ញុំបានត្រឡប់មកប្រទេសវិញនៅចុងឆ្នាំ១៩៥៨ ហើយខ្ញុំក៏គ្មានទាក់ទងអ្វីជាមួយបក្សកុម្មុយនីស្តកម្ពុជានោះដែរ។ ទាក់ទងធ្វើម៉េចកើតបើគិញសម្ងាត់យាមខ្ញុំជាប់ ពេលខ្ញុំធ្វើកាសែត ឡូបសែរវ៉ាទ័រ រហូតដល់ខ្ញុំបានជាប់ជាតំណាងរាស្ត្រក៏គេនៅតែ-- ក៏នៅមានតែគិញយាមតាមជាប់។ បើកឡានពីក្រោយ-- ជិះម៉ូតូពីក្រោយឡានខ្ញុំហ្នឹង ជាចំហតែម្តង។ ធ្វើរដ្ឋមន្ត្រីហើយហ្នឹង ឡានតាម ឡានតាមគិញតាមរដ្ឋមន្ត្រី អ៊ីចឹង។

បើដូច្នេះឲ្យខ្ញុំទៅមានការទាក់ទងជាមួយបក្សកុម្មុយនីស្តកម្ពុជាម៉េចកើត? វានាំឲ្យមានគ្រោះថ្នាក់ដល់ខ្ញុំខ្លាំងណាស់ ខ្ញុំមិនទៅទេ។ នេះ ខ ទីមួយ សូមជម្រាបអំពីសកម្មភាពរបស់ខ្ញុំ កាលខ្ញុំទៅរៀននៅស្រុកបារាំង គឺយ៉ាងនេះ។

[១៤:៣៦:២០]

ទីពីរ នៅពេលត្រឡប់មកក្នុងប្រទេសនៅចុងឆ្នាំ១៩៥៨។ ក) កាសែតឡូបសែរវ៉ាទ័រៈ កថាខណ្ឌ ១១២៧ នៃដីកាដំណោះស្រាយ។ មិត្តភក្តិខ្ញុំដែលខ្ញុំបានស្គាល់នៅស្រុកបារាំង ហើយដែលបានចូលមកក្នុងស្រុកមុនខ្ញុំ។ ដូចជា ហ៊ូ យន់, ហ៊ូ នឹម និងមិត្តភក្តិផ្សេងទៀត ដែលខ្ញុំស្គាល់តាមរយៈគាត់បានស្នើ

ឲ្យខ្ញុំចេញកាសែតមួយ ដើម្បីជាសំឡេងរបស់បញ្ញាជន សាស្ត្រាចារ្យ អ្នករដ្ឋការ។ នេះហើយដែលបាននាំឲ្យខ្ញុំមានគំនិតចេញកាសែតឡុបសែរវ៉ាទ័រ ជាកាសែតចេញពីរដងក្នុងមួយអាទិត្យ ជាភាសាបារាំង គោលជំហររបស់កាសែតខ្ញុំ គឺគាំទ្រដាច់ខាតនយោបាយអព្យាក្រឹតរបស់សម្តេចនរោត្តម សីហនុ។ ប៉ុន្តែគូសបញ្ជាក់ ចំពោះអ្នកដឹកនាំខ្មែរនូវការចាំបាច់ឲ្យមានវិធានការកែទម្រង់ប្រជាធិបតេយ្យខ្លះ ក្នុងទិសដៅធ្វើឲ្យមានតុល្យភាពខ្លះក្នុងសង្គម។ កុំឲ្យមានការខុសគ្នាខ្លាំងពេករវាងអ្នកមាននិងអ្នកក្រ ហើយឲ្យស្រទាប់ក្រោមនៃសង្គមបានទទួលផលពីនយោបាយអព្យាក្រឹតផង ដើម្បីពង្រឹកមូលដ្ឋាននយោបាយនៃនយោបាយនេះ ទប់នឹងការប្រឆាំងរបស់ លន់ នល់ និងបក្សពួក។ គឺខ្ញុំសំដៅអ្នកដឹកនាំកម្ពុជា។

[១៤:៣៨:៥៣]

ដូច្នេះហើយបានជាខ្ញុំសរសេរជាភាសាបារាំង ពីព្រោះពេលនោះអ្នកដឹកនាំកម្ពុជាមិនសូវអានកាសែតខ្មែរទេ។ អ៊ីចឹង ដែលនាំឲ្យខ្ញុំសរសេរកាសែតជាបារាំង ហើយដែលខ្ញុំសរសេរកាសែតជាបារាំងក៏សំដៅទៅតែអ្នកដឹកនាំ។ អ្វីដែលខ្ញុំនិយាយនេះ ខ្ញុំចង់និយាយទៅអ្នកដឹកនាំ។ ក្នុងកាសែត អត្ថបទដែលអ្នកនិយមចូលចិត្តជាងគេ គឺកៀនកោះភ្នំពេញ ដែលរៀបរាប់យ៉ាងរស់រវើកអំពីជីវភាពប្រចាំថ្ងៃរបស់ប្រជាជនសាមញ្ញ ដូចជាអ្នក ធាក់ស៊ីក្លូ អ្នកអូសទឹកលក់ អ្នកបរទេះសេះដឹកបន្លែទៅផ្សារនៅពេលព្រឹកព្រលឹម ការកម្សាន្តរបស់ពលករក្នុងទីក្រុង ដែលតែងតែនាំគ្នាមកអង្គុយជុំៗគ្នាជាក្រុមតូចៗ ហូប ទឹកត្នោតជូរ ក្តែមសាច់បបែល ក្រោយពន្លឺទៀន ដង្ហែគ្នាជុំវិញសួនច្បារខាងកើតវិមានឯករាជ្យ។ល។

គឺជាកាសែតមួយដែលចេញមួយលេខៗត្រឹមតែ ៣០០ច្បាប់ប៉ុណ្ណោះ។ អ្នកជាវខ្លះបង់ថ្លៃលើសដើម្បីសម្តែងនូវការជួយឧបត្ថម្ភដល់កាសែត។ ឃើញថា កាសែតខ្ញុំនេះច្បាស់ណាស់មិនមែនជាកាសែតកុម្មុយនីស្តទេ ហើយក៏មិនមែនឧបត្ថម្ភដោយពួកកុម្មុយនីស្តដូចដែលកថាខណ្ឌ១៦២៧ បានបានអះអាងនោះដែរ។ អ្នកដែលឧបត្ថម្ភដល់កាសែតខ្ញុំភាគច្រើន មិនមែនជាជនកុម្មុយនីស្តទេ ទោះបីមានអ្នកកុម្មុយនីស្តខ្លះក៏ដោយ តែភាគច្រើនគេជាតំណាងរាស្ត្រនៃសភាជាតិ ដូចជា ហ៊ូ យន់, ហ៊ូ នឹម, អ៊ុច វ៉េន, សឺ ណែម ជាដើម។

[១៤:៤១:៤៧]

អ្នកទាំងពីរដែលខ្ញុំរាប់ឈ្មោះខាងក្រោយនេះ ពីមុនគាត់ធ្វើជាសាស្ត្រាចារ្យ ហើយគាត់ទើបតែជាប់ឆ្នោតជាតំណាងរាស្ត្រ។ ដែលនាំឲ្យគេហៅខ្ញុំថា “កាសែតក្រហម កាសែតកុម្មុយនីស្ត កាសែតក្រហមអីនោះ” គឺមកពីសម្តេច សីហនុ ពេលនោះលោកភ័យព្រួយអំពីគំនិតឯករាជ្យរបស់ខ្ញុំ។ ហើយ

ដើម្បីឲ្យឃើញច្បាស់ពីរឿងនេះ ខ្ញុំសូមជម្រាបរឿងមួយដូចតទៅ៖

ថ្ងៃមួយ ខ្ញុំបានត្រូវកោះហៅឲ្យទៅក្រសួងប៉ូលិសពិសេស ពេលដែលខ្ញុំចេញកាសែតហ្នឹង គឺរដ្ឋមន្ត្រីក្រសួងមហាផ្ទៃឈ្មោះ គូ រុន ផ្ទាល់ដែលជាមកសួរចម្លើយខ្ញុំ។ ភ្លើងហ្វាបាញ់ចំមុខខ្ញុំ និងចំភ្នែកខ្ញុំសួរហើយ ពេលត្រឡប់ទៅកន្លែងវិញ ខ្ញុំសរសេរភ្លាមរៀបរាប់ឲ្យអស់អំពីហេតុការណ៍ដែលកើតឡើងនៅពេលគេសួរនោះ ហើយតើសំណួរនោះស្អីខ្លះ? ខ្ញុំឆ្លើយថាម៉េចខ្លះ ខ្ញុំសរសេរអស់ទាំងស្រុង ដើម្បីទុកឆ្លើយ ទុកផ្សាយនៅក្នុងកាសែតខ្ញុំពេលក្រោយ លេខក្រោយ។

[១៤:៤៤:១២]

នៅទីនេះ ខ្ញុំយល់ឃើញថាមានសំណួរពីរ ដែលគួរយកមកជម្រាបលោកប្រធាន អស់លោកលោកស្រីចៅក្រម។ សំណួរទីមួយ គឺហេតុអ្វីបានជាអ្នកឯងស្អប់វាំងម្ល៉េះ? ខ្ញុំភ្ញាក់ព្រឺត កាលបើបានឮសំណួររបៀបនេះ ខ្ញុំក៏ឆ្លើយវិញថា ខ្ញុំមិនយល់ពីឯកឧត្តមចង់មានប្រសាសន៍ពីរឿងអីសោះ។ ទើបរដ្ឋមន្ត្រីនោះ គាត់បង្ហើបពីការដែលខ្ញុំមានជជែកគ្នាជាមួយនិស្សិតគ្នាឯង។ នៅពេលប្រជុំនិស្សិតមួយ នៅម៉ុងព័រឡេ។ គាត់បង្ហើបយ៉ាងនេះ ខ្ញុំគិតមួយសន្ទុះ ទើបខ្ញុំនឹកឃើញពីការប្រជុំមួយនោះ គឺជាការប្រជុំពិភាក្សាគ្នា អំពីថាតើយើងគួរអ្វីនៅលើរនាំងដែលត្រូវដាក់ពីក្រោយឆាក ដែលយើងនឹងសម្តែងសិល្បៈជូនមិត្តភក្តិបារាំង គេមើល ហើយនិងមិត្តភក្តិបរទេសផ្សេងទៀតផងដែរក្នុងឱកាសបុណ្យចូលឆ្នាំខ្មែរយើង។ នៅពេលប្រជុំនោះ និស្សិតដែលជាកូននាម៉ឺនធំម្នាក់បានស្នើឲ្យគូរ ចាន់ ឆាយយ៉ា ខ្ញុំក៏មានមតិថាយើងគួរគូរទេសភាពជនបទខ្មែរវិញ គឺទេសភាពដោយមានដើមត្នោត ហើយមានកសិករកំពុងតែឡើងដោយមានបំពង់ទឹកត្នោតមួយចង្កោមចងជាប់នឹងចង្កេះគាត់។ អ៊ីចឹង ទើបជាប់ចិត្តមិត្តភក្តិបរទេសជាងព្រោះប្លែកភ្នែកគេខ្លាំងជាង។ និស្សិតភាគច្រើនបានយល់ស្របតាមខ្ញុំ។

[១៤:៤៧:២៣]

សំណួរទីពីរ គឺសួរអំពីហេតុអ្វីបានជាខ្ញុំមិនចូលធ្វើការរាជការ ក្រោយពីបានរៀនចប់ហើយហើយបែរជាទៅធ្វើកាសែតវិញ? សំណួរនេះ មានថែមទាំងពាក្យថា តើខ្ញុំចង់ឡើងសោយរាជ្យ? ធ្វើកាសែតហ្នឹង ចង់ឡើងសោយរាជ្យ? នែ៎ បើចង់ឡើងសោយរាជ្យអ្ហ៎ះ! ចង់ដេកមុងឈើទេ? មុងឈើគឺក្តារមឈូស។ ខ្ញុំវាហួសចិត្តហ្មង។

ប៉ុន្តែខ្ញុំនិយាយអំពីសំណួរទីមួយវិញ សំណួរនេះ នាំឲ្យឃើញថាមានការតាមឃ្លាំមើលនិស្សិតនៅស្រុកបារាំងជាប់។ រឿងតូចមួយសោះ ក៏ត្រូវបានរាយការណ៍ទៅក្រសួងប៉ូលិសពិសេស ហើយរាយ-

ការណ៍ដោយលម្អៀងទៀត ដើម្បីគេទុកប្រើប្រឆាំងនឹងអ្នកណាដែលបានបង្ហាញនូវគោលជំហរឯករាជ្យ។ ក្រៅពីការកោះហៅខ្ញុំទៅប្រជុំនេះ-- ទៅសួរនេះ បានរយៈប្រហែលជាពីរ ឬបីខែ ខ្ញុំក៏ត្រូវបានគេវាយដំច្រំផាក់ ហើយសម្រាតនៅចំកណ្ដាលថ្នល់ទាំងថ្ងៃត្រង់។ បន្ទាប់មក ខ្ញុំក៏ត្រូវបានគេចាប់ខ្លួនទៅឃុំអស់រយៈជាងមួយខែ ដោយគ្មានឃើញដីកាចោទប្រកាន់ពីរឿងអ្វីទាំងអស់ ហើយកាសែតខ្ញុំក៏ត្រូវបិទ។

**ប្រធានអង្គជំនុំ៖**

លោក ខៀវ សំផន តើសេចក្ដីថ្លែងការណ៍របស់លោកនៅវែងទេ?

**លោក ខៀវ សំផន៖**

បាទ, នៅលោកប្រធាន។ ពីកាលដែលខ្ញុំនៅធ្វើតំណាងរាស្ត្រ ហើយខ្ញុំធ្វើដល់--

[១៥:៥០:១២]

**ប្រធានអង្គជំនុំ៖**

អរគុណច្រើនអ៊ំ។ អរគុណដោយសារពេលវេលាសមល្មមនឹងសម្រាក អ៊ីចឹងបានយើងសួរ។ ឥឡូវហ្នឹង ដោយសារបើនៅថ្លែងការណ៍របស់លោកនៅវែងទៀត ដូច្នេះ អង្គជំនុំជម្រះយល់ថា ពេលវេលាសមល្មមនឹងសម្រាកណាស់ហើយ។ ដូច្នេះ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះទៅរហូតដល់ម៉ោងបីដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

អនុរក្សមន្ទីរឃុំឃាំង នាំខ្លួនគាត់ទៅកាន់កៅអីដែលរៀបចំទុកសម្រាប់ខ្លួនគាត់នៅពីក្រោយមេធាវីរបស់គាត់ចុះ ហើយឲ្យនាំគាត់មកកន្លែងនេះវិញ ឲ្យបានមុនពេលអង្គចៅក្រមជំនុំជម្រះចូលកាន់អសនៈ។ សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៥០ នាទី ដល់ម៉ោង ១៥:១៨ នាទី)*

[១៥:១៨:៥៣]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ! អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

សូមអញ្ជើញលោកមេធាវីការពារក្ដីឲ្យលោក អៀង សារី!

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន! ដោយសារតែលោក អៀង សារី បានទ្រាំអង្គុយយូរពេក ហើយពេល

នេះគាត់មានបញ្ហាឈឺចង្កេះ ហើយទ្រាំលែងបាន ហើយពេទ្យទើបតែពិនិត្យអំមិញថាគាត់ ហើយបានបង្កឲ្យមានសម្ពាធឈាមឡើងខុសពីធម្មតាខ្លះ។ អ៊ីចឹងសូមអនុញ្ញាតលោកប្រធានឲ្យគាត់ចូលរួមសវនាការនៅបន្ទប់ជាន់ក្រោមសម្រាប់ពេលរសៀលសល់ថ្ងៃនេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បានស្តាប់នូវសំណើសុំរបស់លោក អៀង សារី តាមរយៈមេធាវីរបស់គាត់ សុំលះបង់សិទ្ធិមិនចូលរួមនៅក្នុងសវនាការផ្ទាល់នាពេលនេះ ដោយទៅតាមដានសវនាការពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍នៅបន្ទប់មួយខាងក្រោមសវនាការនេះ ដែលបានរៀបចំរួចជាស្រេចនូវឧបករណ៍សោតទស្សន៍ ដោយមូលហេតុមានបញ្ហាសុខភាព។ ដូច្នេះគឺជាមូលហេតុសមរម្យ អង្គជំនុំជម្រះអនុញ្ញាតយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ ដែលស្នើសុំតាមរយៈមេធាវី ដោយលះបង់សិទ្ធិក្នុងការចូលរួមក្នុងកិច្ចដំណើរដោយផ្ទាល់នៅក្នុងសវនាការនេះ ទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយនៅបន្ទប់ខាងក្រោមបន្ទប់សវនាការតាមរយៈឧបករណ៍សោតទស្សន៍។ ប៉ុន្តែបង្គាប់ឲ្យក្រុមមេធាវីការពារក្តីជនជាប់ចោទ អៀង សារី ប្រគល់ជូនមកអង្គជំនុំជម្រះភ្លាមៗ នូវលិខិតលះបង់សិទ្ធិក្នុងការចូលរួមដោយផ្ទាល់នេះ ដោយមានហត្ថលេខា ឬក៏ស្នាមមេដៃជាក់លាក់ពីលោក អៀង សារី ផង។ ទីបី បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំលោក អៀង សារី ទៅកាន់បន្ទប់ខាងក្រោមដែលរៀបចំនូវឧបករណ៍សោតទស្សន៍សម្រាប់ជនជាប់ចោទ។ ហើយទីបួន បង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។

[១៥:២១:១៣]

ម៉េចទៅលោកមេធាវី អាចមានឯកសារអីភ្លាមៗនៃលិខិតលាយលក្ខណ៍រៀបចំទេ ដើម្បីដាក់មកអង្គជំនុំជម្រះ?

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន។ សូមអនុញ្ញាតមួយនាទីដើម្បីឲ្យគាត់ចុះហត្ថលេខាលើលិខិត។

**ប្រធានអង្គជំនុំ៖**

លោក ផារី យកឯកសារកំណត់ហេតុពិនិត្យសុខភាពរបស់គ្រូពេទ្យពិនិត្យសុខភាពជនជាប់ចោទទាំងបីរូបនៅក្នុងអំឡុងពេលនៃសម្រាកអាហារអម្បាញ់មិញនេះដាក់ចូលនៅក្នុងសំណុំរឿង។

អនុរក្សមន្ទីរឃុំឃាំងនាំគាត់ទៅចុះ!

លោក ឌុច ផារី ទុកឯកសារនេះបញ្ចូលនៅក្នុងសំណុំរឿង!

សូមអញ្ជើញ លោក កាណាវាស!

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំមានបញ្ហាបច្ចេកទេសមួយលោកប្រធាន គឺខ្ញុំសូមឲ្យខ្យល់ម៉ាស៊ីនត្រជាក់នេះបក់ឡើងទៅកន្លែងទិសដៅផ្សេងទៅ ប្រសិនបើដាក់មកចំខ្ញុំនេះ វាពិបាក ប៉ុន្តែអ្នកភាគីផ្សេង គឺប្រហែលជាអាចចង់បានម៉ាស៊ីនត្រជាក់។ អ៊ីចឹងបើសិនដាក់មកចំខ្ញុំពេកអ៊ីចឹង គឺខ្ញុំត្រជាក់ពេក ខ្ញុំទ្រាំអត់បានទេ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការអាចរៀបចំសម្រួលទៅ! បើមានបញ្ហា នៅតែបញ្ហាទៀតផ្តាច់បិទចោលទៅជាការងាយជាង។

មុននឹងប្រគល់វេទិកាជូនទៅជនជាប់ចោទ ខៀវ សំផន អង្គជំនុំជម្រះសូមជម្រាបអំពីគម្រោងផែនការសវនាការដែលអង្គជំនុំជម្រះរៀបចំធ្វើនៅថ្ងៃស្អែក គឺការបន្តការស្តាប់សក្ខីកម្មសាក្សី ឡុង នរិន្ទ តាមមធ្យោបាយសោតទស្សន៍ដែលអាចប្រព្រឹត្តទៅពេញមួយថ្ងៃ។ លើកលែងតែមានបញ្ហាសុខភាព ឬបច្ចេកទេសសោតទស្សន៍ជាយថាហេតុដែលមិនអាចដំណើរការបាន ក្នុងករណីចុងក្រោយនេះគើតមានអង្គជំនុំជម្រះរក្សាសិទ្ធិក្នុងការបន្តសួរជនជាប់ចោទជាជំនួស។ ហេតុដូច្នេះសូមភាគី និងសាធារណជនជ្រាប។ ជាបន្តអង្គជំនុំជម្រះ សូមប្រគល់វេទិកាទៅលោក ខៀវ សំផន ដើម្បីបន្តនៃការធ្វើសេចក្តីថ្លែងការណ៍របស់លោក។ សូមអញ្ជើញ!

**លោក ខៀវ សំផន៖**

បាទ, សូមអរគុណលោកប្រធាន។

ខ្ញុំសូមជម្រាបបន្ត មុននឹងសម្រាកអម្បាញ់មិញ ខ្ញុំចូលដល់ចំណុច(ខ) ដែលនិយាយអំពីខ្ញុំបានធ្វើជាតំណាងរាស្ត្រ ហើយក្រោយមកធ្វើជារដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម។ នៅឆ្នាំ១៩៦២ ខ្ញុំក៏បានជាប់ឆ្នោតជាតំណាងរាស្ត្រសង្គមរាស្ត្រនិយម ជាចលនាដែលសម្តេចនរោត្តម សីហនុ បានបង្កើតឡើងក្នុងឱកាសបោះឆ្នោតទូទៅកាលពីឆ្នាំ១៩៥៥។ ហើយខ្ញុំមកក៏ត្រូវបានចាត់តាំងជារដ្ឋលេខាធិការក្រសួងពាណិជ្ជកម្មភ្លាម។

ខ្ញុំសូមជម្រាបលោកប្រធាន និងអស់លោក លោកស្រីចៅក្រមថា បំណងពិតរបស់សម្តេច សីហនុ គឺលោកចង់ទិញទឹកចិត្តខ្ញុំ។ ប៉ុន្តែខ្ញុំៗឆ្លៀតឱកាសនេះធ្វើការដើម្បីមានប្រយោជន៍ដល់លោកផង

និងដល់ប្រទេសទាំងមូលផង។ ខ្ញុំមិនបានភ្លេចគម្រោងរបស់ខ្ញុំចង់កែទម្រង់សេដ្ឋកិច្ច ដើម្បីរៀបចំឱ្យមានគ្រឹះមួយជាបណ្តើរៗនៃសេដ្ឋកិច្ចមួយឯករាជ្យនោះទេ។

[១៥:២៧:៣០]

តាំងពីខ្ញុំនៅផ្សាយកាសែត ឡុបសែរវ៉ាទ័រ ម្ល៉េះ។ ខ្ញុំឧស្សាហ៍ជួបពិគ្រោះ ពិភាក្សាជាមួយឥស្សរជនចាស់ៗដែលមាននយោបាយសមរម្យដូចជា ឯកឧត្តម សឺន សាន ពេលនោះលោកធ្វើជាចាងហ្វាងធនាគារជាតិ។ ឯកឧត្តម មាជ គុណ ប្រធានសភាសហករណ៍ហៅកាត់ជាភាសាបារាំងថា *"អូរ៉ុប"* សម្តេច ប៉ែន នុត ទីប្រឹក្សាចាស់ទុំមួយរបស់សម្តេចនរោត្តម សីហនុ ។ល។ ដើម្បីស្ទាបស្ទង់អំពីលទ្ធភាពលោកជួយឧបត្ថម្ភគំនិតរបស់ខ្ញុំនេះ។

ការតែងតាំងខ្ញុំជារដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម បើកឱកាសឱ្យខ្ញុំមានលទ្ធភាពពិគ្រោះពិភាក្សាបានជាខ្សែសង្វាក់ជាមួយឯកឧត្តម សឺន សាន ពីគម្រោងរបស់ខ្ញុំ។ ពេលនោះ ឯកឧត្តមកំពុងតែបារម្ភពីការលួចរូបិយប័ណ្ណបរទេសយកទៅលក់ទីផ្សារងងឹត ដែលនាំឱ្យប្រាក់រៀលចុះថ្លៃ។ អ្នកដែលតាំងខ្លួនគេថាជាអ្នកឧស្សាហកម្មកសុំរូបិយប័ណ្ណពីក្រសួងពាណិជ្ជកម្ម ដោយសំអាងលេសថា ត្រូវការទិញគ្រឿងចក្រ គ្រឿងបន្លាស់ ឬវត្ថុធាតុដើមសម្រាប់រោងចក្ររបស់គេ។ តាមពិត នេះគ្រាន់តែជាលេសដើម្បីបានរូបិយប័ណ្ណទៅលក់នៅផ្សារងងឹត។

[១៥:២៩:៤៥]

នៅពេលនោះ តាមផ្លូវការ ៣០រៀល ដូរបានមួយដុល្លារអាមេរិក។ នៅផ្សារងងឹតមួយដុល្លារលក់បានជាងពីររយរៀល។ ដូច្នេះតាមការលក់-ដូរតាមផ្សារងងឹតយ៉ាងនេះ ឃើញថា បានចំណេញច្រើនសន្ធឹកសន្ធាប់ណាស់។ នេះហើយដែលផ្សារងងឹតរីកលូតលាស់សម្បើម។ ខ្ញុំជម្រាបជូនឯកឧត្តម សឺន សាន ថាបាតុភូតនេះ ទាក់ទងជាប់ស្អិតល្មួតជាមួយនឹងទម្រង់នៃសេដ្ឋកិច្ចយើង ហើយសកម្មភាពខុសច្បាប់នេះធ្វើទៅបានដោយមានធនាគារចូលរួមផង។

វិធានការត្រួតពិនិត្យតាមផ្លូវរដ្ឋបាល ឬតាមផ្លូវគណនេយ្យចូលទៅឆែកឆេរយ៉ាងណាក៏រកមិនឃើញដែរ ចាប់មិនបានដែរ។ ពីព្រោះក្រុមហ៊ុនអាហារ័ណនីហរ័ណ នៅស្រុកខ្មែរ និងនៅបរទេស តាមពិតទៅជាក្រុមរបស់ឈ្មួញតែម្នាក់ឬតែមួយក្រុមទេ។ អាចប្រៀបបានទៅនឹងហោប៉ៅពីរនៃអាវតែមួយ។

ក្រុមហ៊ុននៅស្រុកខ្មែរចេះតែខាត ឬចំណេញបានតិចតួច ឯក្រុមហ៊ុនបរទេសចំណេញជាប់ជានិច្ច។ ហោប៉ៅឆ្វេងចេះតែអស់លុយ តែលុយវាចូលហោប៉ៅស្តាំ។ ឯការពិត ឈ្មួញដែលពាក់ហោប៉ៅ

ពីរនេះ គេចំណេញជាប់ មានបានឡើងជានិច្ច។ បាតុភាពនេះបំបាត់ទៅបាន ឬបន្ថយទៅបានលុះត្រាតែរដ្ឋក្តាប់ពាណិជ្ជកម្មក្រៅប្រទេសលើផលិតផលសំខាន់ៗ ដូចជា ស្រូវ ដូចជា អង្ករ ពោត កៅស៊ូ និងក្តាប់ធនាគារ ដែលសហការជាមួយពាណិជ្ជកម្មក្រៅប្រទេស។

ក្រោយពីពិភាក្សាអស់ច្រើនលើកច្រើនសា ឯកឧត្តម សឺន សាន ក៏យល់ស្របជាមួយខ្ញុំ។ ឯកឧត្តមក៏ស្នើឲ្យខ្ញុំធ្វើគម្រោង កែទម្រង់មកជូនលោក ដើម្បីឲ្យលោកយកទៅថ្វាយសម្តេច។ ឯសម្តេចនរោត្តម សីហនុ ពេលនោះក៏លោកព្រួយបារម្ភពីការដែលកម្ពុជាកាន់តែរណបជំនួយអាមេរិកកាន់តែខ្លាំងឡើងៗ។ ឯអាមេរិកចេះតែគំរាមកាត់ជំនួយ។

[១៥:៣៤:០២]

អ៊ីចេះ ជំនួយអាមេរិកប្រៀបបានទៅនឹងកាំបិតភ្ជង់កកម្ពុជាជាប់។ គម្រោងរបស់ខ្ញុំនេះក៏ត្រូវបានសម្តេចសព្វព្រះទ័យយ៉ាងឆាប់រហ័ស។ ប៉ុន្តែជាការគួរឲ្យស្តាយ ខ្ញុំក៏ត្រូវធ្លាក់ពីតំណែង ដោយមូលហេតុសាច់គោឡើងថ្លៃ។ រឿងនេះ វាគួរឲ្យអស់សំណើចពេកទៅ នាំឲ្យចាស់ៗអាយុរវាង៦០ឆ្នាំឡើងទៅ នៅចាំរហូតមកដល់សព្វថ្ងៃ គេហៅថារឿង និន និរ៉ុម ដោយឈ្មោះ និន និរ៉ុម នេះហើយដែលជាអ្នកដេញដោលទម្លាក់ខ្ញុំនៅសមាជសង្គមរាស្ត្រនិយម។

ផ្ទាល់ខ្លួនខ្ញុំ ខ្ញុំមិនជឿថាសម្តេច សីហនុ មិនមែនមិនយល់ថានេះជាល្បិចកលដើម្បីទម្លាក់ខ្ញុំចេញពីតំណែងទេ ព្រោះលោកក៏ជ្រាបដែរ ថាខ្មែរភាគច្រើនមិនហូបសាច់គោរាល់ថ្ងៃទេ តែគេហូបត្រី។ ការពិតគឺសម្តេចខ្លួនលោក លោកត្រូវតែកៀសខ្ញុំចេញ ដើម្បីអី? កុំឲ្យខ្ញុំបានទទួលផលចំណេញខាងនយោបាយ ក្នុងឋានៈខ្ញុំជាអ្នកផ្តើមគំនិតកែទម្រង់ ហើយដើម្បីឲ្យមតិជាតិឃើញថា ខ្ញុំជាខ្មែរក្រហមជាកុម្មុយនីស្តអាក្រក់ គ្មានសមត្ថភាព ចាំតែទិតៀនមួលបង្កាច់សង្គមរាស្ត្រនិយម។

[១៥:៣៦:៣១]

ភស្តុតាង គឺកែទម្រង់ដែលធ្វើទៅតាមគម្រោងរបស់ខ្ញុំនេះ បានទទួលលទ្ធផលល្អនៅមួយឆ្នាំពីរឆ្នាំដំបូង មុននឹងរលាយទៅវិញដោយសារអំពើពុករលួយ។ ទោះបីខ្ញុំត្រូវធ្លាក់ពីតំណែងក៏ដោយ ក៏ខ្ញុំរីករាយដែលសម្តេចបានសព្វព្រះទ័យតែតាំងឯកឧត្តម សឺន សាន ឲ្យទទួលខុសត្រូវកែទម្រង់សេដ្ឋកិច្ចតាមគម្រោងដែលខ្ញុំបានស្នើ។ ជាលើកដំបូងហើយតាំងពីឆ្នាំ១៩៥៥មក ដែលជញ្ជីងទូទាត់លុយកាក់ជាមួយបរទេសទទួលបានតុល្យភាព គេហៅថា *ប៉ាឡង់ ដឺប៉័រឡេម៉ង់ អារិច ឡិចស្ទែរីយែរ អេគីលីប្រេ* (និយាយភាសាបារាំង)នៅឆ្នាំ១៩៦៥ និងមួយឆ្នាំតមកទៀត។

ក្នុងរយៈពេលដូចគ្នានេះដែរ រូបិយប័ណ្ណដែលរក្សាទុកបម្រុងនៅធនាគារជាតិ ក៏បានកើនឡើងវិញដែរ។

គ) មូលហេតុអ្វីដែលនាំឱ្យខ្ញុំរត់ចូលព្រៃនៅឆ្នាំ១៩៦៧ កថាខណ្ឌ១១២៨ និង១៦០០ នៃដីកាដំណោះស្រាយ។ ដែលនាំឱ្យខ្ញុំរត់ចូលព្រៃនេះ គឺជាការបង្ខំចិត្ត ចិត្តខ្ញុំ ខ្ញុំចង់បន្តធ្វើការងាររបស់ខ្ញុំជាតំណាងរាស្ត្រ។ ប៉ុន្តែខ្ញុំគ្មានផ្លូវឯណាផ្សេងទៀតទេ ក្រៅពីរត់ចេញពីភ្នំពេញ ពីព្រោះសន្តិសុខខ្ញុំលែងធានាបានទៀតហើយ។ ខ្ញុំត្រូវគេគំរាមចាប់ ហើយនាំខ្លួនទៅតុលាការសឹក ក្រោមលេសថាខ្ញុំជាមេនាំឱ្យកសិករបះបោរនៅសំឡូត។

ការពិតខ្ញុំមិនទាំងស្គាល់សំឡូតនៅឯណាផងអង្កាល់នោះ ហើយខ្ញុំក៏មិនជឿថាកសិករនាំគ្នាបះបោរ ដោយសារតែកាសែតខ្ញុំញុះញង់គេនោះឡើយ ព្រោះគេមិនចេះអានអក្សរបារាំងទេ។ ការពិតគឺចាប់តាំងពីក្រោយការបោះឆ្នោតឆ្នាំ១៩៦៦ មកម្ល៉េះ។ សម្ដេច សីហនុ ត្រូវបានកម្លាំងខាងស្ដាប់របស់លោក លន់ នល់ ដែលស្និទ្ធិជាមួយអាមេរិកហ៊ុមព័ទ្ធជាប់ហើយ។ ដែលជាហេតុនាំឱ្យលោកគិតគូរខិតខំតែជួសជុលរៀបចំការទាក់ទងជាមួយសហរដ្ឋអាមេរិកឡើងវិញជាសំខាន់។ នេះហើយ ដែលនាំឱ្យលោកបែរមកវាយខាងឆ្វេង ហើយបណ្ដោយឱ្យ លន់ នល់ ធ្វើការរាតត្បាតចាប់ចងតាមចិត្ត។ នេះហើយ ដែលនាំឱ្យមានការចោទប្រកាន់ខ្ញុំ ទាំងច្រងាង១កណ្ដាលថ្ងៃត្រង់នេះ និងការគំរាមកំហែងខ្ញុំដូចខ្ញុំបានជម្រាបហើយ។

[១៥:៤០:៣៥]

ដូច្នេះខ្ញុំក្លាយទៅជារបស់មួយដែលមានតម្លៃ ដែលធ្លាក់ទៅលើដៃរបស់បក្សកុម្មុយនីស្ដកម្ពុជា។ ការដែលខ្ញុំត្រូវបង្ខំចិត្ត រត់ចេញពីភ្នំពេញបានក្លាយទៅជាឱកាសមួយរបស់គេ ដើម្បីយកខ្ញុំទៅជាមួយគេ។

ឃ) ក្រោយផ្ទុះរដ្ឋប្រហារឆ្នាំ១៩៧០ កថាខណ្ឌ២៥ និង១១២៩ នៃដីកាដំណោះស្រាយ។ នៅទីនេះខ្ញុំមានសំណូមពរចង់ជម្រាបលម្អិត ជុំវិញការរៀបចំការចាត់តាំងរណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា។ ជាពិសេសជុំវិញសេចក្ដីអំពាវនាវថ្ងៃ២៣ មីនា ១៩៧០ របស់សម្ដេច សីហនុ។ តាមការពិត សេចក្ដីអំពាវនាវនេះ មិនមែនជាស្នាព្រះហស្ដរបស់សម្ដេចទាំងស្រុងទេ គម្រោងរបស់លោកត្រូវបានប្រគល់ជូនទៅលោក ជូ អេនឡាយ រដ្ឋមន្ត្រីទីមួយចិន។ ហើយលោក ជូ អេនឡាយ ក៏បានយកទៅបង្ហាញ សាឡុត ស។ សាឡុត ស ក៏បានកែសម្រួលខ្លះៗ ជាពិសេសលុប

ចំណុចណាដែលនិយាយដល់សង្គមនិយម ក៏ប៉ុន្តែ សាឡុត ស មិនទៅជួយសម្តេច សីហនុ តាមការស្នើរបស់លោក ជូ អេនឡាយ ទេ គាត់បែរទៅជាសរសេរសំបុត្រគាំទ្ររណសិរ្សរួបរួមជាតិកម្ពុជា ដែលដាក់ឈ្មោះខ្ញុំ ហ៊ូ យន់, ហ៊ូ នឹម ទៅវិញ។ ហើយថាសំបុត្រនេះផ្ញើចេញពីមូលដ្ឋានមួយ នៃការតស៊ូនៅក្នុងប្រទេស។ គេមិនបានឲ្យសម្តេចសីហនុ ដឹងថា សាឡុត ស នៅប៉េកាំងនៅពេលនោះ នោះទេ។ ឯខ្ញុំពេលនោះ ខ្ញុំនៅឯភ្នំឱរ៉ាល់ ឯនោះទេគឺនៅនឹងទីបញ្ជាការរបស់តា ម៉ុក ជាមួយ ហ៊ូ យន់, ហ៊ូ នឹម និង ប៉ុក ដឹសកុមារ ហើយសេចក្តីអំពាវរបស់សម្តេចក្តី សេចក្តីប្រកាសចាត់តាំងរដ្ឋាភិបាលរួបរួមជាតិកម្ពុជាក្រោយមកទៀតក្តី គឺខ្ញុំបានដឹងឮដោយសារតែស្តាប់វិទ្យុផ្សាយសំឡេងតែប៉ុណ្ណោះ។ ហើយនៅក្នុងរដ្ឋាភិបាលរួបរួមជាតិកម្ពុជានេះ ខ្ញុំត្រូវ សាឡុត ស ចាត់តាំងជានាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការពារប្រទេស អគ្គបញ្ជាការកងកម្លាំងប្រដាប់អាវុធរំដោះជាតិអីៗតាមវិទ្យុទេ។ ខ្ញុំឮតែតាមវិទ្យុទេ។

[១៥:៤៦:៣៦]

ខ្ញុំសូមអនុញ្ញាត កត់សម្គាល់លើបញ្ហាសំខាន់មួយទៀត។ ទីមួយ បានជា ប៉ុល ពត មិនព្រមជួបសម្តេច នរោត្តម សីហនុ ពីព្រោះគាត់ជាលេខាបក្សកុម្មុយនីស្តកម្ពុជា ជាបក្សរបស់កសិករ ពលករកម្ពុជា តស៊ូវាយរំលំរបបសក្តិភូមិដែលមានសម្តេច សីហនុ ជាមេ។ ដូច្នេះ គាត់មិនអាចទៅក្រាបថ្វាយបង្គំសម្តេច នរោត្តម សីហនុ ទេ។ ហើយក៏មិនអាចនៅក្រោមការដឹកនាំរបស់សម្តេច សីហនុ បានដែរ។

ទីពីរ ឯសម្តេចវិញ លោកជាម្ចាស់ផែនដី ជាបិតាជាតិ ជាសម្តេចឪ លោកមានឋានៈខ្ពស់ជាងអ្នកណាៗទាំងអស់។ ដូច្នេះលោកត្រូវតែធ្វើប្រធានរណសិរ្សរួបរួមជាតិកម្ពុជា។ ឃើញថា របាំងដែលឃាំងអ្នកទាំងពីរនេះ មិនអាចអ្នកណាលើកចេញបានទេ។ ដូច្នេះ ភារកិច្ចតម្រូវឲ្យខ្ញុំធ្វើជាស្ពានរវាង ប.ក.ក បក្សកុម្មុយនីស្តកម្ពុជា និងសម្តេចសីហនុ ដើម្បីបើកផ្លូវឲ្យមានការបង្រួមបង្រួមកម្លាំងជាតិទាំងអស់ទូទាំងប្រទេស ដោយមិនប្រកាន់ពណ៌សម្បុរនយោបាយ ឬជំនឿអ្វីទាំងអស់ ធ្វើការតស៊ូសង្គ្រោះជាតិមាតុភូមិ ដែលកំពុងត្រូវឆាបឆេះ រោលរាល ដោយភ្លើងសង្គ្រាមវៀតណាម នៅពេលក្រោយរដ្ឋប្រហាររបស់ លន់ នល់ ភ្លាម។ តើនេះជាឧក្រិដ្ឋកម្មឬ? មិនមែនទេ។ គឺច្បាស់ជាមិនមែនទេ។

[១៥:៤៩:៤៥]

ម៉្យាងទៀត ដូចដែលខ្ញុំបានជម្រាបមកនេះ ច្បាស់ហើយគឺ ប៉ុល ពត ដែលបានចាត់តាំងខ្ញុំឲ្យទទួលមុខតំណែងដែលខ្ញុំមិនបានដឹងសោះនោះ ជាឧបនាយកខ្យល់ រដ្ឋមន្ត្រីការពារប្រទេសខ្យល់ អគ្គបញ្ជាការខ្យល់។ល។ នៅពេលដែលបក្សកុម្មុយនីស្តកម្ពុជាឯណោះទេ ដែលជាអ្នកដឹកនាំការតស៊ូ

តាំងពីសង្គ្រាមឈ្លបឆ្នាំ១៩៦៨,៦៩ មករហូតដល់មានជាកងពលក្នុងសង្គ្រាមពីឆ្នាំ១៩៧០ ទៅ៧៥។ បើដូច្នេះ តើគេនៅអះអាងថា ខ្ញុំអ្នកមានអំណាចធំ សម្បើមណាស់ យ៉ាងនេះយ៉ាងនោះ បានទៀតទេ? អត់ទេ វាទៅមិនរួចទេ បើឧបនាយកខ្យល់ រដ្ឋមន្ត្រីការពារប្រទេសខ្យល់ អគ្គបញ្ជាការទ័ពខ្យល់។ ការពិត ខ្ញុំគ្មានឥទ្ធិពលអ្វីតែបន្តិចក៏គ្មានដែរ ទៅលើកងទ័ព សូម្បីតែអង្គភាពតូចមួយ ក៏គ្មាននៅក្រោមបង្គាប់របស់ខ្ញុំដែរ។ ផ្ទុយទៅវិញ ខ្ញុំត្រូវលះបង់អត្តិភាពរបស់ខ្ញុំ កិត្តិយសរបស់ខ្ញុំ ដើម្បីខ្ញុំអាចបំពេញភារកិច្ចជូនមាតុភូមិរបស់ខ្ញុំ ដែលកំពុងត្រូវរងគ្រោះថ្នាក់ដល់អាយុជីវិត។

[១៥:៥២:២៤]

នៅពេលនោះ ខ្ញុំមានអារម្មណ៍ប្រហាក់ប្រហែលអ្វី ដែលលោក នួន ជា បាននិយាយពីថ្ងៃចន្ទទី០៥ ធ្នូ មុននោះដែរ។ ខ្ញុំមិនអាចសុខចិត្តឲ្យប្រទេសរបស់ខ្ញុំ ដែលទើបនឹងបានផុតពីកណ្តាប់ដៃបារាំងហើយ ហើយច្បាស់ជានឹងបានរំដោះផុតពីកណ្តាប់ដៃអាមេរិក នៅពេលខាងមុខនេះហើយ បែរជាធ្លាក់ទៅក្នុងកណ្តាប់ដៃកុម្មុយនីស្តវៀតណាមនោះទេ។

ឥឡូវនេះ ខ្ញុំចូលមកជម្រាបលោកប្រធាន អស់លោក លោកស្រីចៅក្រម អំពីតួនាទីរបស់ខ្ញុំនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា។

ក) អំពីការចូលជាសមាជិកបក្សកុម្មុយនីស្តកម្ពុជា គឺដល់ឆ្នាំ១៩៦៩ នៅលើភ្នំឱរ៉ាល់ ទើបខ្ញុំបានចូលបក្សជាមួយ ហ៊ូ យន់, ហ៊ូ នឹម, ប៉ុក ដឹសកុមារ ដែល តាម៉ុក ជំនួសមុខឲ្យបក្សកុម្មុយនីស្តកម្ពុជាជាអ្នកបញ្ចូល។ ចំពោះបក្សកុម្មុយនីស្តកម្ពុជា ការដែលខ្ញុំបានចូលបក្សបារាំង មិនមានន័យអ្វីទេ ពីព្រោះលក្ខខណ្ឌរបស់គេ តឹងរ៉ឹងជាងបក្សបារាំងឆ្ងាយណាស់។ ទីមួយ ត្រូវមានសកម្មភាពប្រយុទ្ធ ហើយត្រូវបានឆ្លងកាត់លត់ដំកសាងសាកល្បងក្នុងការតស៊ូបដិវត្តន៍សាចុះសាឡើង។

[១៥:៥៤:៤៦]

ទីពីរ ខ្ញុំត្រូវមានវណ្ណភាពល្អ។ ខ្ញុំមិនមានវណ្ណភាពល្អទេ ពីព្រោះខ្ញុំជាបញ្ញាជនថ្នាក់ខ្ពស់ រៀនសូត្រនៅបារីស ដែលហៅថាវណ្ណភាពល្អហ្នឹង ទាល់តែវណ្ណភាពកសិករ ហើយកសិករក្រទៀត។ ដូច្នេះសូម្បីតែថាហៅថាការតស៊ូលត់ដំ សាកល្បងសាចុះសាឡើងក៏ខ្ញុំមិនដែល។ ដូច្នេះបានន័យថាខ្ញុំមិនបានបំពេញលក្ខណៈសម្បត្តិទាំងពីរនេះទេ។ ហើយម្យ៉ាងទៀត ខ្ញុំមិនបានចូលរួមតស៊ូដោយជំនឿជឿជាក់របស់ខ្ញុំទេ គឺដោយខ្ញុំទាល់ច្រក ត្រូវបង្ខំចិត្តការពារសន្តិសុខផ្ទាល់ខ្លួន រត់មកជ្រកក្រោមម្លប់បក្សកុម្មុយនីស្តកម្ពុជាឲ្យជួយការពារខ្ញុំទៅវិញទេ។ ខ្ញុំមិនបានបោះបង់ចោលតំណែងខ្ញុំជាតំណាងរាស្ត្រដោយ

ខ្លួនឯងទេ គឺដោយបង្ខំចិត្ត។ នេះ មិនហៅថាជាចូលរួមតស៊ូបដិវត្តន៍ទេ ចំណុចនេះហើយដែលជិតដាមជាប់ប្រវត្តិរូបរបស់ខ្ញុំ។

ខ)ការចូលជាសមាជិកគណៈមជ្ឈិម កថាខណ្ឌ២៩ និង១១៣០នៃដីកាដំណោះស្រាយ។ ខ្ញុំត្រូវបានចូលជាសមាជិកត្រៀមនៃគណៈមជ្ឈិមនៅឆ្នាំ១៩៧១។ ខ្ញុំសូមបញ្ជាក់ថាក្នុងឋានៈជាសមាជិកត្រៀម ខ្ញុំគ្មានសិទ្ធិចូលរួមការសម្រេចអ្វីទាំងអស់។ ការដែលគេអនុញ្ញាតឲ្យខ្ញុំចូលជាសមាជិកគណៈមជ្ឈិមក្នុងឋានៈជាសមាជិកត្រៀម មូលហេតុគឺមកពីខ្ញុំមានភារកិច្ចដើរតួជាស្ពានភ្ជាប់ការទាក់ទងរវាងបក្សកុម្មុយនីស្តកម្ពុជា និងសម្តេចសីហនុ។ ដូច្នេះ គេត្រូវបង្ហាញឲ្យមហាជនឃើញថាខ្ញុំជាមេដឹកនាំកម្លាំងតស៊ូនៅក្នុងប្រទេស។ បើទុកឲ្យខ្ញុំនៅជាបេក្ខជនធម្មតានោះ ហាក់ដូចជាមិនសមទេ។

ដូច្នេះហើយ បានជាគេលើកស្ទួយឲ្យខ្ញុំមានតួនាទីជារូបភាពខ្លះៗនៅក្នុងបក្សទៅ។ នេះហើយដែលប៉ុល ពត និងបក្សកុម្មុយនីស្តកម្ពុជា តាមការពិតទៅនៅតែចាត់ទុកខ្ញុំជាមនុស្សរណសិរ្ស មិនមែនជាមនុស្សរបស់បក្សទេ។

ឧទាហរណ៍ជាក់ស្តែង សមាជិកមជ្ឈិមផ្សេងទៀតទាំងអស់ គេសុទ្ធតែទទួលខុសត្រូវភូមិភាគ ឬតំបន់ ឬអង្គភាពទ័ពធំៗជាកងពល។ ឯខ្ញុំសមាជិកគណៈមជ្ឈិមនឹងគេដែរ តែខ្ញុំគ្រាន់តែមានភារកិច្ចសរសេរសេចក្តីរាយការណ៍ ឲ្យបានញឹកញាប់ទៅសម្តេច សីហនុ តែប៉ុណ្ណោះ។

[១៦:០០:១០]

ឃើញថាតួនាទី និងឋានៈរបស់ខ្ញុំនៅក្នុងបក្សកុម្មុយនីស្តកម្ពុជាប្រហាក់ប្រហែលនឹងតួនាទីនិងឋានៈរបស់តស្សូរជននៃរណសិរ្សរំដោះជាតិវៀតណាមខាងត្បូងដែរ។ ដូចជាលោក ង្វៀង ភូ ថ និងលោក វិន តាន់ហ្វាត់ ជាដើម។ ង្វៀង ភូ ថ ជាមេធាវីមួយរូបល្បីឈ្មោះនៅព្រៃនគរ ហើយលោកជាប្រធានរណសិរ្សរំដោះជាតិវៀតណាមខាងត្បូង ហើយលោក វិន តាន់ហ្វាត់ ជាវិស្វករ ហើយមានតួនាទីជារដ្ឋមន្ត្រីទីមួយ នៃរដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្នវៀតណាមខាងត្បូង។ តែក្រោយពីវៀតណាមខាងត្បូងត្រូវបានរំដោះបាត់ឈ្មោះលោកទាំងពីរនេះរហូត។

បញ្ហាមួយទៀតដែលខ្ញុំសូមជម្រាប គឺវគ្គ១១២៩ នៃដីកាដំណោះស្រាយអះអាងថា ក្រោយពីការផ្តួលរំលំសម្តេច នរោត្តម សីហនុ នៅឆ្នាំ១៩៧០ ហើយនៅពេលរណសិរ្សរួបរួមជាតិកម្ពុជាត្រូវបានបង្កើត ខៀវ សំផន បានចូលរួមជាមួយ ប៉ុល ពត, នួន ជា និងអ្នកដឹកនាំផ្សេងទៀតនៃបក្សកុម្មុយនីស្តនៅទីស្នាក់កណ្តាលរបស់បក្សនេះ។

និយាយយ៉ាងនេះ មិនត្រឹមត្រូវទេ ពីព្រោះមិនមែនខ្ញុំទេ ពីព្រោះខ្ញុំមិនមែននៅក្នុងក្រុមដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជាទេ ហើយមិនមែនខ្ញុំទេដែលមកនៅកន្លែងដឹកនាំរបស់បក្សនោះ គឺ ប៉ុល ពត ទេដែលហៅខ្ញុំឱ្យទៅទីនោះ ដើម្បីចូលរួមស្តាប់ពេលគាត់ធ្វើការជាមួយកម្មាភិបាលយោធា ដែលមកពីសមរភូមិផ្សេងៗទូទាំងប្រទេសរាយការណ៍ជូនគាត់ និងស្តាប់ការណែនាំរបស់គាត់ទៅគេវិញ។ ស្តាប់ហើយ យល់សភាពការណ៍នៃការតស៊ូវិវត្តន៍ដល់ណាៗហើយ ទើបខ្ញុំអាចសរសេរសេចក្តីរាយការណ៍ថ្វាយសម្តេចបាន។

ដូច្នេះខ្ញុំសង្ឃឹមថា លោកប្រធាន អស់លោក លោកស្រីចៅក្រម អស់លោក លោកស្រីទាំងអស់ដែលមានមុខនៅទីនេះ ព្រះសង្ឃ បងប្អូនរួមជាតិទាំងអស់ ជ្រាបច្បាស់ហើយ ឃើញច្បាស់ហើយដោយគ្មានអ្វីសង្ស័យបានទៀតទេ អំពីតួនាទី និងឋានៈរបស់ខ្ញុំនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា។ ជាពិសេសតាមការជ្រាបអំពី ប៉ុល ពត ចាត់ចែងលើរូបខ្ញុំ តាំងពីប៉េកាំងមក ក្នុងខណៈដែលខ្ញុំនៅភ្នំឱរ៉ាល់ សរសេរសំបុត្រជំនូសខ្ញុំ គាំទ្ររណសិរ្សរួបរួមជាតិកម្ពុជារបស់សម្តេច សីហនុ។ ចាត់តាំងខ្ញុំជានាយករដ្ឋមន្ត្រីខ្យល់ រដ្ឋមន្ត្រីការពារប្រទេសខ្យល់ អគ្គបញ្ជាការនៃកងកម្លាំងប្រដាប់អាវុធខ្យល់ ។ល។ ហើយដោយខ្ញុំមិនដឹងខ្លួនសោះ។

[១៦:០៥:០៣]

ដូច្នេះបើយល់ច្បាស់ហើយថា ហេតុអ្វីបានជាខ្ញុំដែលមើលពីក្រោមកឃើញថា កាន់តំណែងខ្ពស់ហើយបែរជាមិនបានចូលរួមក្នុងការសម្រេចអ្វីធំដុំនៃការកិច្ចរបស់បក្ស ឬក៏កិច្ចការរបស់ប្រទេសនោះ។ គឺមកពី ប៉ុល ពត និងបក្សកុម្មុយនីស្តកម្ពុជាចាត់ទុកខ្ញុំជាបញ្ញាជន រត់មករស់នៅជាមួយបក្សកុម្មុយនីស្តកម្ពុជា មិនមែនជាមនុស្សរបស់បក្សទេ។ នេះជាការពិត នៅមុនឆ្នាំ១៩៧៥ ហើយនៅថ្ងៃតៗមកក្រោយទៀតក៏នៅតែយ៉ាងនេះ។ ប៉ុន្តែបញ្ហាទាំងអស់នេះនឹងត្រូវពិនិត្យថែមទៀត នៅពេលសវនាការក្រោយៗទៀត។

មុននឹងបញ្ចប់ ខ្ញុំសូមអនុញ្ញាតនិយាយអំពីចំណុចមួយដូចតទៅ៖

ខ្ញុំយល់ឃើញថា គួរតែជម្រាបអំពីហេតុអ្វីបានជាប្រជាជនកម្ពុជាភាគច្រើនលើសលប់ ផ្តល់ការគាំទ្ររបស់គេដល់ចលនាតស៊ូក្រោមការដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា។ តាមខ្ញុំយល់ គឺមកពីគេអស់សង្ឃឹមខ្លាំងពីរបប លន់ នល់ ដែលពុករលួយដល់ឆ្អឹង ហើយជាបរិវារដាច់ថ្លៃរបស់សហរដ្ឋអាមេរិក។ តែបើមើលមកខាងចលនាតស៊ូវិញ គេឃើញមនុស្សដែលគេស្គាល់ច្បាស់ថា ជាមនុស្សស្អាតស្អំ ហើយ

ការពារឯករាជ្យ និងអធិបតេយ្យភាពជាតិដាច់ខាត។ គេនឿយណាយដោយឃើញតែអំពើពាលាអាវាសែ អំពើឧក្រិដ្ឋ និងអាណាធិបតេយ្យនៅក្នុងរបប លន់ នល់។ ឯខាងការតស៊ូគេឮថា វិន័យតឹងរ៉ឹងណាស់ ប៉ុន្តែគេត្រៀមខ្លួននឹងទទួលគោរពតាម។ ពីព្រោះគេស្រេកឃ្លានចង់បាននូវសង្គមមួយ ដែលប្រកបទៅដោយគុណធម៌ និងសីលធម៌។

លោកប្រធាន អស់លោក លោកស្រីចៅក្រម អស់លោក លោកស្រីទាំងអស់ដែលមានមុខនៅទីនេះ ព្រះសង្ឃ បងប្អូនរួមជាតិជាទីគោរពស្នេហា ខ្ញុំបានជម្រាបជូនអស់ហើយនូវអ្វីដែលខ្ញុំចង់ជម្រាបនៅថ្ងៃនេះ។ សូមអរព្រះគុណ អរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណ នូវសេចក្តីថ្លែងរៀបរាប់ដ៏ក្បោះក្បាយរបស់លោក ខៀវ សំផន។

ឥឡូវនេះ ដល់ពេលសមល្មមនឹងសម្រាកហើយ ប៉ុន្តែមុននឹងប្រកាសសម្រាកអង្គជំនុំជម្រះសូមជម្រាបជូនដល់ភាគី សាធារណជន ការិយាល័យរដ្ឋបាល ព្រមទាំងបុគ្គលិកនៃអង្គជំនុំជម្រះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលមានភារកិច្ចពាក់ព័ន្ធនឹងកិច្ចដំណើរការគាំទ្រកិច្ចដំណើរការសវនាការរបស់អង្គជំនុំជម្រះសាលាដំបូងជ្រាបថា អង្គជំនុំជម្រះសាលាដំបូងមានបំណងធ្វើសវនាការបន្តការសួរចម្លើយជនជាប់ចោទនៅព្រឹកថ្ងៃសុក្រ ទី១៦ ធ្នូ ឆ្នាំ២០១១ ពេញមួយព្រឹកទៀត។

អាស្រ័យហេតុនេះ សូមភាគី សាធារណជន និងការិយាល័យរដ្ឋបាល ព្រមទាំងបុគ្គល មន្ត្រីរាជការដែលមានភារកិច្ចពាក់ព័ន្ធនឹងកិច្ចដំណើរការសវនាការសូមជ្រាប។

ឥឡូវនេះដល់ពេលសមល្មមនឹងឈប់សម្រាកហើយៗ អង្គជំនុំជម្រះសាលាដំបូងប្រកាសផ្អាកកិច្ចដំណើរសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការនឹងលើកបន្តទៅព្រឹកថ្ងៃស្អែក ចាប់ផ្តើមពីម៉ោងប្រាំបួន។

អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទាំងបីរូប ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ ហើយនិងឲ្យនាំខ្លួនគាត់ត្រឡប់មកកាន់បន្ទប់សវនាការវិញនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនជាកំណត់៕

សម្រាកចុះ!

*(សវនាការផ្អាកនៅម៉ោង ១៦:១១ នាទី)*